**សម្ភាសន៍ជាមួយឈ្មោះ អោម អាន ភេទប្រុស អាយុ ៧៨ ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ លេខាតំបន់ ៤១ (ភូមិភាគកណ្តាល)**

**មុខងារបច្ចុប្បន្ន ៖ កសិករ**

**ស្រុកកំណើតនៅភូមិតាំងស្វាយ ឃុំពាម ស្រុកសាមគ្គីមានជ័យ(អតីតកំពង់ត្រឡាចលើ)**

**ខេត្តកំពង់ឆ្នាំង**

**សព្វថ្ងៃរស់នៅភូមិអូរគគី ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង**

**ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា**

**០៣:០៣:០៣**

**៦៤ទំព័រ**

ដានី ៖ ដំបូងបងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះពេញ ឈ្មោះអីដែរ?

អាន ៖ អោម អាន ។

ដានី ៖ ចុះអ៊ំមានឈ្មោះពីដើម ឈ្មោះកំណើតអ៊ំ?

អាន ៖ មាន ។

ដានី ៖ ឈ្មោះអី?

អាន ៖ ប៉ុន្តែ ដែលគេនិយមប្រើនឹង មាន ។

ដានី ៖ ពីដើមមកអ៊ំឈ្មោះអី?

អាន ៖ អោម យឿន ។

ដានី ៖ អោម យឿន?

អាន ៖ បាទ!

ដានី ៖ អត់មានឈ្មោះអីទៀតទេ?

អាន ៖ អត់ទេ ។

ដានី ៖ ឈ្មោះតែពីរនឹង ឈ្មោះ អោម អាន ហើយនឹងឈ្មោះ អោម យឿន?

អាន ៖ បាទ!

ដានី ៖ អោម យឿននឹង ឈ្មោះអ៊ំតាំងពីអន្លាល់មក?

អាន ៖ តាំងពីកំណើត ។

ដានី ៖ ឈ្មោះកំណើតអ៊ំមកឈ្មោះ អោម យឿន?

អាន ៖ បាទ!

ដានី ៖ ដល់ពេលអ៊ំមកប្រែឈ្មោះមក អាន វិញ ចាប់ពីឆ្នាំណាមក?

អាន ៖ ចាប់ពីឆ្នាំខ្ញុំសឹកពីបួស១៩៦០ ។

ដានី ៖ ឆ្នាំ១៩៦០ អ៊ំប្រែឈ្មោះនឹង?

អាន ៖ បាទ! ខ្ញុំសឹកពីបួស ដល់អីចឹងទៅ ខ្ញុំបេះថ្នាំ បេះសន្លូវ បុសឈើ បុសអីនឹង ស្តោះផ្លុំខ្លុះ ក្មេងយំ ក្មេងអីនឹង ។ ដល់ចឹងទៅគេប្រៀបធៀបខ្ញុំ គេសម័យនោះ គេលេងរឿងលោកគ្រូ អាន នៅបាត់ដំបង ពោធិ៍ក្នុង ស្តោះព្រួសរដូង១ ។ គេលេងរឿងនឹង ដល់ចឹងទៅ ខ្ញុំបេះខាងនឹងទៅ គេហៅខ្ញុំគ្រូ អាន ចឹងទៅ ។ ជាប់រហូតតាំងពីឆ្នាំ១៩៦០ ឈ្មោះកំណើតវាអត់ដែលអ្នកណាហៅ អ្នកណាប្រើអីទេ អត់ទេ គេហៅចឹងទៅ ។ រហូតមកគ្មានអ្នកណាស្គាល់ទេ ឈ្មោះកំណើតនោះ ។

ដាវ៉ា ៖ រហូតមកដល់ឆ្នាំនេះ អ៊ំមានព្រះជន្មប៉ុន្មានហើយអ៊ំ?

អាន ៖ ខ្ញុំ ៧៨ ។

ដាវ៉ា ៖ អ៊ី! យូ ៧៨ ។

ដានី ៖ អ៊ំ ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

អាន ៖ ឈ្មោះ ឌិ គាត់ស្លាប់យូរហើយ តាំងខ្ញុំអាយុ១២ឆ្នាំ ខ្ញុំកំព្រា ។

ដានី ៖ ឪពុកឈ្មោះ ឌិ?

អាន ៖ បាទ!

ដានី ៖ ចុះអ៊ំដាក់ត្រកូលឈ្មោះ អោម?

អាន ៖ អោម ជីតា ។

ដានី ៖ ចឹងឪពុកអ៊ំឈ្មោះ ឌិ ទេ តែ អោម ជីតាអ៊ំ?

អាន ៖ ត្រកូលតែយកជីតា ។

ដានី ៖ គាត់ស្លាប់តាំងពីឆ្នាំណាទៅ?

អាន ៖ អូ! តាំងពីខ្ញុំអាយុ១២ ហើយខ្ញុំ៧៨ហើយ ខ្ញុំអត់ចាំទេ តូចណាស់១២ឆ្នាំ កំព្រាឪពុកស្លាប់ ។

ដានី ៖ ចុះម្តាយអ៊ំ គាត់ឈ្មោះអីដែរ?

អាន ៖ ម្តាយឈ្មោះ នុន ។

ដានី ៖ ឈ្មោះ នុន?

អាន ៖ បាទ!

ដានី ៖ ម្តាយអ៊ំគាត់ស្លាប់តាំងពីអង្កាល់ទៅ?

អាន ៖ ស្លាប់ពីឆ្នាំ៧៩ យើង ។

ដានី ៖ ឆ្នាំ៧៩?

អាន ៖ បាទ!

ដានី ៖ ចុះអ៊ំបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ទៅ?

អាន ៖ ខ្ញុំ៥នាក់ ប៉ុន្តែស្លាប់អស់២ ស្រី១ ប្រុស១ ខ្ញុំជាទី២ ។

ដានី ៖ ចឹងទី១ឈ្មោះអីទៅអ៊ំបង?

អាន ៖ ទី១បងប្រុសឈ្មោះ យ៉ុង, អោម យ៉ុង នឹងណា៎ ។

ដានី ៖ អោម យ៉ុង?

អាន ៖ បាទ!

ដានី ៖ សព្វថ្ងៃគាត់នៅរស់ដែរ?

អាន ៖ អត់ទេ ស្លាប់ ខ្ញុំនេះវាទៅទី១ ។

ដានី ៖ គាត់ស្លាប់តាំងពីអង្កាល់ទៅ បងប្រុសទី១?

អាន ៖ ស្លាប់ពីឆ្នាំ៧០ ។

ដានី ៖ ចឹងទី២អ៊ំ?

អាន ៖ បាទ! ទី២ខ្ញុំ ។

ដានី ៖ គាត់ស្រី ឬប្រុស?

អាន ៖ ប្រុស ។

ដានី ៖ ចឹងទី៣?

អាន ៖ ទី៣ក៏ស្លាប់ ស្រី ។

ដានី ៖ ទី៣ ស្រី?

អាន ៖ បាទ!

ដានី ៖ គាត់ឈ្មោះអីទៅ?

អាន ៖ ឈ្មោះ ណាន ។

ដានី ៖ អោម ណាន?

អាន ៖ បាទ!

ដានី ៖ គាត់ស្លាប់ឆ្នាំណាដែរ?

អាន ៖ ឆ្នាំ៦៩ ។

ដានី ៖ ស្លាប់ឆ្នាំ៦៩?

អាន ៖ បាទ!

ដានី ៖ គាត់ស្លាប់ដោយសារមូលហេតុអីដែរ?

អាន ៖ ជម្ងឺចាស់ បងខ្ញុំបងប្រុសធ្លាក់ឈាម ។

ដានី ៖ ម៉េចបានគាត់ធ្លាក់ឈាម?

អាន ៖ ក្អួតធ្លាក់ឈាម, ជម្ងឺស្ងួត ។

ដានី ៖ ចុះទី៤អ៊ំ?

អាន ៖ ទី៤ អោម នឿន ។

ដានី ៖ អោម នឿន ស្រី ប្រុស?

អាន ៖ ស្រី ។

ដានី ៖ អោម នឿន គាត់នៅណាដែរ សព្វថ្ងៃ?

អាន ៖ នៅជិតខ្ញុំហ្នឹង ។

ដានី ៖ នៅជិតផ្ទះអ៊ំ នៅភូមិអូរគគីរនឹង?

អាន ៖ បាទ!

ដានី ៖ ភូមិអូរគគី ឃុំអូរដា?

អាន ៖ បាទ!

ដានី ៖ ចុះទី៥?

អាន ៖ ទី៥ ប្រុស អោម សុវ៉ាត ។

ដានី ៖ ប្រុសឈ្មោះ អោម សុវ៉ាត?

អាន ៖ បាទ! ប៉ុនមិនដឹងគេដាក់ត្រកូលដាក់យ៉ាងម៉េចទេ ។

ដានី ៖ ចុះ អោម សុវ៉ាត គាត់នៅឯណាដែរ?

អាន ៖ នៅអន្លង់វែង ។

ដានី ៖ ចុះសព្វថ្ងៃអ៊ំរស់នៅភូមិ ឃុំអីដែរ?

អាន ៖ ភូមិ អូរគគី ។

ដានី ៖ ភូមិអូរគគី ។

អាន ៖ ឃុំ អូរដា

ដានី ៖ ស្រុក?

អាន ៖ ស្រុក កំរៀង ។

ដានី :	ខេត្ត?

អាន :	ខេត្តបាត់ដំបង ។

ដារ៉ា :	ចុះស្រុកកំណើតរបស់អ៊ំវិញ?

អាន :	ស្រុកកំណើត នៅភូមិតាំងស្វាយ

ដារ៉ា :	ឃុំអីដែរ?

អាន :	ឃុំពាម ។

ដានី :	ស្រុកអីដែរ?

អាន :	ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ដានី :	ហ្នឹងគេហៅកំពង់ត្រឡាចលើ?

អាន :	ឥឡូវពិបាក ។ កាលមុនកំពង់ត្រឡាចលើ ។ ឥឡូវ ខ្ញុំអត់ដឹងទេ ។

ដានី :	កំពង់ឆ្នាំង?

អាន :	បាទ ។

ដានី :	ចុះអ៊ំ ប្រពន្ធអ៊ំ គាត់ឈ្មោះអីដែរ?

អាន :	ឈ្មោះ ព្រំ វ៉ាន ។

ដានី :	គាត់អាយុប៉ុន្មាន សព្វថ្ងៃ?

អាន :	អាយុ ៦០ ហើយ ។

ដារ៉ា :	ឆ្នាំអី ជាឆ្នាំសត្វអី?

អាន :	សត្វពស់ ។

ដារ៉ា :	រោង

ដានី :	អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

អាន :	កូន ២ ។

ដានី :	យ៉ាងម៉េច, កូនពីរនាក់ហ្នឹង?

អាន :	ប្រុស១ ស្រី១ ។

ដានី :	ធំៗហើយ?

អាន :	នេះ, ប៉ុន្តែខ្ញុំជិវាបអីចឹងណា ព្រោះនេះជាកូនគ្រួសារខ្ញុំ គាត់មេម៉ាយ ហើយខ្ញុំក៏មេម៉ាយ ។ អីចឹងកូនដើម ។ ហើយខ្ញុំបានគាត់ បានកូនស្រី ។

ដានី :	កូនស្រីអ៊ំឈ្មោះអីដែរ?

អាន :	នាងៗ គេហៅ នាង ។

ដានី ៖ គាត់ឈ្មោះ អោម នាង អីចឹង?

អាន ៖ បាទ

ដាវ៉ា ៖ គ្រួសារអឹមុន គាត់ឈ្មោះអីដែរ?

អាន ៖ ហ្នឹងស្លាប់ហើយ ។

ដាវ៉ា ៖ អីចឹងបានអឹស្រីនេះ ក្រោយមកទេអីចឹង?

អាន ៖ បាទ

ដានី ៖ ហើយដែលគ្រួសារអឹមុននឹងបានកូនប្រុស១?

អាន ៖ អត់ទេ ។

ដាវ៉ា ៖ គ្រួសារអឹមុន ស្រុកកំណើតជាមួយអីដែរ?

អាន ៖ អត់ទេ ។ ស្រុកកំណើតនៅខាងកំពត ខេត្តកំពត ។

ដាវ៉ា ៖ គាត់មានបញ្ហាអី?

អាន ៖ ស្លាប់

ដានី ៖ ស្លាប់ឆ្នាំណា?

អាន ៖ មិនដឹងស្លាប់ឆ្នាំទេ ។

ដានី ៖ អឹអត់មានកូនទៅ?

អាន ៖ មានទេ ។ មុនអត់ ។

ដានី ៖ គាត់ឈ្មោះអីដែរគ្រួសារអឹ?

អាន ៖ ឈ្មោះ កាន ។

ដានី ៖ ត្រកូលគាត់?

អាន ៖ អត់ដឹងទេ ។ ដឹងតែឈ្មោះឪពុក ។ ឪពុកឈ្មោះ បាន ។ ម្ដាយឈ្មោះ គៀន ។ ដាក់ បាន កាន អីចឹងទៅ ។ អត់បានស្គាល់ជីតាជីអីទេ ។

ដានី ៖ អីចឹងគាត់ស្លាប់កាលពីឆ្នាំ៧៩?

អាន ៖ បាទ ។ ពេលដែលសង្គ្រាមផ្ទុះឡើង សង្គ្រាមរបស់រដ្ឋាភិបាលសព្វថ្ងៃហ្នឹង អីចឹងទៅរត់ព្រាត់ប្រាស់គ្នានៅក្នុងព្រៃ ស្លាប់បាត់ទៅ ។

ដានី ៖ អីចឹង ខ្ញុំចង់ឲ្យអឹរៀបរាប់ជីវិតអឹតាំងក្មេងមោ ដូចថា តាំងពីក្មេងមោ អឹធ្លាប់បានរៀនសូត្រអីនៅណា ហើយបន្ទាប់ពីរៀនសូត្រមោ អឹធ្វើអីទៀត?

អាន ៖ ខ្ញុំកាលនៅពីក្មេង ដូចខ្ញុំជំរាប កាលនៅពីក្មេង កូនកំព្រាឪពុកតាំងពីអាយុ ១២ឆ្នាំ ។ ខ្ញុំអត់

មានឪពុក ដូច្នេះ ខ្ញុំអត់បានសិក្សា រៀនសូត្រខាងផ្នែកសាលា កូនសិស្សកូនអីទេ។ ដល់ក្រោយមកបានជីតាខាងម្ដាយ គាត់បានបំបួសខ្ញុំទៅ។ ដល់បួសហ្នឹង ខ្ញុំមិនបានរៀនជ្រៅជ្រះអីទេ។ ធម៌អារ្យ សិក្ខាវិន័យអី ខ្ញុំជាមនុស្សធម្មតា។ អត់បានរៀនសូត្រខ្ពង់ខ្ពស់អីហ្នឹងគេទេ។ ដល់ឆ្នាំ១៩៦០ ខ្ញុំមានជំងឺ។ ដល់មានជំងឺអីចឹង ខ្ញុំក៏ត្រូវម្ដាយឲ្យចាកសិក្ខាបទទៅ ឆ្នាំ១៩៦០ហ្នឹង។ ដល់អីចឹង ឈឺរយៈកាល៣ឆ្នាំ។ ម្ដាយខំថែ ខំទាំ ខំមើលទៅ។ ដលអីចឹង រយៈកាល៣ឆ្នាំបានជានាហើយ បានប្រកបរបររកស៊ីធ្វើស្រែ ចំការ អត់មានធ្វើអីក្រៅពីស្រែចំការនោះទេ។ ហ្នឹងសុំជម្រាបប៉ុននឹង។

ដាវ៉ា : កាលហ្នឹងក្នុងឆ្នាំ៦០អីចឹង?

អាន : បាទ, ១៩៦០ ខ្ញុំចាកសឹក្ខាបទ។ ចាប់ពី១៩៦០ ដល់៦៣ ខ្ញុំជាពីឈឺ។ ៣ ឆ្នាំ។

ដានី : អីចឹងអ៊ំបួសតាំងពីអាយុ ១២ ឆ្នាំ?

អាន : អត់ទេ អាយុប៉ុន្មានទេ ភ្លេចហើយ អត់ចាំបានទេ។

ដានី : អ៊ំបួសបាន៦ឆ្នាំហើយទើបសឹក អីចឹងឬ?

អាន : បាទ។

ដានី : អ៊ំបួសនៅវត្តណា?

អាន : នៅតាំងខ្មៅ ឃុំពាម ស្រុកកំពង់ត្រឡាចកំពង់ឆ្នាំង។

ដានី : កាលហ្នឹងអ៊ំបួសដល់ណា ដូចថា ជាភិក្ខុ?

អាន : ភិក្ខុ។ បំពេញបានចាភិក្ខុ។

ដានី : កាលហ្នឹងអត់មានបានជាចៅអធិការអីទេ?

អាន : អត់ទេ។

ដាវ៉ា : កាលហ្នឹង ចៅអធិការឈ្មោះអីដែរ?

អាន : ព្រះនាម វ៉ាយ, មេគុណ។

ដានី : កាលហ្នឹងជំនាន់អ៊ំបួស ចៅអធិការឈ្មោះ លោកតា វ៉ាយ។

អាន : គ្រូឧបជ្ឈា។ ១២០ ព្រះជន្ម។ បួសតាំងពីក្មេង។

ដានី : កាលអ៊ំបួស អ៊ំរៀនសូត្រនៅវត្តហ្នឹងដែរ?

អាន : ខ្ញុំទៅរៀននៅខាងជើងពោធិ៍ចិនតុងនៅវត្តអង្គជុំ ឃុំគោករការ។

ដាវ៉ា : រៀនអីដែរ?

អាន : ខ្ញុំរៀនខាងធម៌វិន័យ។

ដាវ៉ា : អត់មែនរៀនសាលាថ្នាក់ទី១ ទី២អីទេ?

អាន :	ធម៌វិន័យមានទី១ ទី២ ។

ដានី :	រៀនខាងធម៌, ពុទ្ធិកៈ?

អាន :	បាទ ។ ពុទ្ធិកៈបឋមសិក្សា ខាងបាលី ។ ខាងខ្ញុំនេះ រៀនខាងធម្មវិន័យ ។

ដានី :	រៀននៅវត្តណា កាលហ្នុង?

អាន :	នៅអង្គជុំ ។

ដារ៉ា :	រៀនបានប៉ុន្មានឆ្នាំ?

អាន :	ទល់នឹងឆ្នាំ៦០ បានខ្ញុំសឹក ។

ដានី :	បានប៉ុន្មានឆ្នាំនៅវត្តអង្គជុំនឹង?

អាន :	ខ្ញុំរៀនទល់នឹងខ្ញុំសឹកហ្នឹងឯង ។

ដានី :	អ៊ំសឹកឆ្នាំ៦០ ហើយអ៊ំថា ឈឺឆ្នាំ៧០...

អាន :	អត់ទេ ។ ឆ្នាំ៦០ ខ្ញុំសឹក ឈឺហើយ មកដល់៦៣បានជា ។

ដានី :	អ៊ីចឹងអ៊ំបួសក្លាមនៅវត្តតាំងខ្មៅ អ៊ំទៅរៀននៅវត្តអង្គជុំក្លាម ឬក៏បានប៉ុន្មានឆ្នាំបានអ៊ំទៅរៀន?

អាន :	ខ្ញុំនៅវត្តហ្នឹងបាន២ឆ្នាំ បានខ្ញុំទៅរៀន ។

ដានី :	អ៊ីចឹងបួសបាន២ឆ្នាំ បានអ៊ំទៅរៀនរហូតដល់ឆ្នាំ៦០ ។

អាន :	បាទ ។

ដានី :	កាលហ្នឹងទៅរៀនធម្មហ្នឹងរៀនបានចប់អីដែរ?

អាន :	ទី៣ ។

ដានី :	ថ្នាក់ទី៣?

អាន :	បាទ ។ ត្រី ទោរ ឯក ។

ដានី :	កាលហ្នឹងរៀនមានកូនសិស្សប៉ុន្មាននាក់?

អាន :	អូ, អត់ចាំទេ ។ កាលហ្នឹងគ្រូឈ្មោះ អាចារ្យ អ៊ូ ។

ដានី :	គាត់ធ្វើអីដែរអាចារ្យ អ៊ូ ក្រោយៗមក?

អាន :	គ្រូ ។

ដានី :	ប៉ុន្តែក្រោយមក?

អាន :	អត់ដឹងទេ ព្រោះឆ្ងាយពីគ្នាណាស់ ។ ខ្ញុំសឹកទៅ ខ្ញុំមកស្រុក ។

ដានី :	កាលហ្នុងមិត្តភ័ក្តិអ៊ំម៉ារៀនស្របាលគ្នា អ៊ំមានចាំឈ្មោះពីណាដែរ?

អាន :	ដូចពិបាករកនឹកដែរ ។

ដានី ៖ អ៊ីរៀនជាមួយពីណាខ្លះដែរកាលហ្នុង?

អាន ៖ មានច្រើនដែរ។ ជំនាន់ខ្ញុំថ្នាក់ដូចគ្នា មាន សុក សាន់។ សាន់ហ្នឹងពីរ។ ឈ្មោះ សាន់ សាន់ទៀត ឈ្មោះ សម ឈ្មោះ ម៉េត។ ថ្នាក់ដូចគ្នាហ្នឹង អត់ចាំទេក្មួយ ច្រើនណាស់។

ដានី ៖ ចុះសុក សាន់ ក្រោយៗគាត់បានធ្វើការអីដែរ?

អាន ៖ អត់ទេ ក្មួយ។ គេនៅមាដុំកូនចៅស្រុកគេជគេនៅហ្នុង។ ហើយខ្ញុំអ្នកចំណូលទៅរៀន។ កាលហ្នុងកូនចៅគេដើរវត្តនៅភូមិព្រៃខ្លា នៅភូមិព្រៃមូល នៅភូមិពុទ្រា នៅភូមិបែកបក។

ដានី ៖ អីចឹងដល់ពេលរៀនដល់ឆ្នាំ៦០ទៅ អ៊ីមានជំងឺអីគេទៅអ៊ី?

អាន ៖ ឈឺរួញដៃ រួញជើងអីចេះ កាញ៉ើកាញោរអីចេះ។

ដានី ៖ គេហៅជំងឺអីទៅ?

អាន ៖ អត់ដឹងទេ។ កាលហ្នុងមានពេទ្យឯណា ខ្ញុំមោផ្ទះ ម៉ែយកទៅមើលគ្រូបូរាណ។ មិនជំងឺអី គេលាដៃ លាជើងក៏មិនរួច។

ដានី ៖ កាលហ្នុងគេអត់ដឹងហៅជំងឺអីទេ?

អាន ៖ បាទ, គ្រូបូរាណដាក់ថ្នាំ។

ដានី ៖ អីចឹងចាប់ពីឈឺឆ្នាំ៦០ អ៊ីចាប់លាសិក្ខាបទ?

អាន ៖ បាទ។

ដានី ៖ នៅវត្តអង្គជុំ ឬក៏មកវត្ត?

អាន ៖ មកវត្តកំណើត។

ដានី ៖ មកវត្តតាំងខ្មៅវិញ?

អាន ៖ បាទ។ មោហ្នឹង លោកគ្រូយល់ព្រមឲ្យចាកសិក្ខាបទទៅ។

ដានី ៖ កាលហ្នុងខែប៉ុន្មានដែរ អ៊ីលាចាកសិក្ខាបទ?

អាន ៖ អត់ចាំទេ។

ដានី ៖ ដូចជាខែប្រាំង ឬខែវស្សា ឆ្នាំ៧០ហ្នឹង?

អាន ៖ ខែប្រាំង។ អត់ចាំទេក្មួយប្រុស វែងណាស់។

ដារ៉ា ៖ កាលអ៊ីបានជាជំងឺឈឺថ្កាត់ពីឆ្នាំ៦៣មក អ៊ីប្រកបរបរ

អាន ៖ ប្រកបរបរធ្វើស្រែ។

ដារ៉ា ៖ នៅឯណា?

អាន ៖ នៅភូមិកំណើតដដែល។

ដារ៉ា ៖ ធ្វើស្រែបានប៉ុន្មានឆ្នាំអីប៉ុន្មានឆ្នាំទៀត?

អាន ៈ ប៉ុន្មានឆ្នាំបានម៉ាហូបគ្រប់គ្រាន់ ។

ដានី ៈ អ៊ំធ្វើស្រែបានប៉ុន្មានឆ្នាំទៀតបានអ៊ំមានការទៅណាមកណាបន្តទៀត?

អាន ៈ អត់ទៅណាផង ។

ដារ៉ា ៈ នៅតែក្នុងភូមិស្រុកកំណើត?

អាន ៈ បាទ ។

ដារ៉ា ៈ ចុះកាលហ្នឹងដូចថា មានសភាពការណ៍អីយ៉ាងម៉េចនៅស្រុកភូមិអ៊ំក្នុងឆ្នាំហ្នឹង យ៉ាងម៉េចដែរអ៊ំ?

អាន ៈ ឆ្នាំ៦០, អត់មានស្អីទេ ។ ១៩៦០ រហូតមក៦៣ អត់មានអីទេ ។

ដានី ៈ ចាប់ពីឆ្នាំ៦០ដាង វាមានចលនាតស៊ូ កាលហ្នឹងមានការតស៊ូនៅខាងក្នុងស្រុកអីចឹង អ៊ំចាប់ផ្ដើមចូលតស៊ូពីពេលណាដែរ?

អាន ៈ ខ្ញុំធ្វើការតស៊ូឆ្នាំ១៩៧០ ។

ដានី ៈ អីចឹងពីឆ្នាំ៦៣ អ៊ំនៅធ្វើស្រែជាមួយឪពុកម្ដាយ?

អាន ៈ បាទ ។

ដានី ៈ កាលហ្នុងអ៊ំអត់ទាន់មានគ្រួសារទេ?

អាន ៈ នៅ ។

ដានី ៈ ពេលចេញតស៊ូឆ្នាំ៧០ អ៊ំអាចរៀបរាប់មូលហេតុថាយ៉ាងម៉េច បានចេញតស៊ូពីជំនាន់ហ្នឹង?

អាន ៈ មូលហេតុគឺសំខាន់ថ្ងៃ១៨ ខែ៣ ឆ្នាំ៧០ ហ្នឹង ។ ឯកឧត្ដម លន់ នល់ កាលហ្នឹងធ្វើរដ្ឋប្រហារសម្ដេច ។ កាលហ្នុងសម្ដេចយាងទៅព្យាលបាលព្រះរោគនៅប្រជាមានិតចិនប៉េកាំង ។ អីចឹងទៅ លន់ នល់ធ្វើរដ្ឋប្រហារខាងក្រោយហ្នឹងដោយមិនឲ្យសម្ដេចវិលត្រឡប់ ។ ដល់អីចឹងសម្ដេចបានធ្វើសេចក្ដីប្រកាសនៅប៉េកាំង ប្រកាសថា កូនចៅអើយ កូនចៅទាំងអស់ត្រូវចូលព្រៃម៉ាកគីដើម្បីតស៊ូ ធ្វើម៉េចឲ្យឪបានវិលត្រឡប់មកមាតុប្រទេស ។ ដល់ក្រោយមកមហាបាតុកម្មបានផ្ទុះឡើង ។ ទាំងគេទាំងខ្ញុំទាំងអស់ធ្វើការតស៊ូ ។ រួមធ្វើការតស៊ូដោយក្នុងពេលនោះ មានអ្នកដឹកនាំគឺគេហៅថា តា ១៥ ។ ដល់ក្រោយមកបានដឹងថាឈ្មោះ តា ម៉ុក នេះឯង ។ កាលណោះ អត់មានដឹងអីទេ តា ម៉ុក តាអីទេ គេហៅ តា ១៥ ហ្នឹងដែលនាំធ្វើមហាបាតុកម្មអីហ្នឹង ។ ហ្នឹងមូលហេតុគឺអីចឹង ។

ដារ៉ា ៈ ចុះមុនឆ្នាំ៧០ដែលមានរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ មុនហ្នឹងស្ថានភាពក្នុងភូមិអ៊ំអីមានអ្នកមកធ្វើការឃោសនា រឿងចូលបដិវត្តខ្មែរក្រហមអីទេអ៊ំ?

អាន ៖ ពូមាន ប៉ុន្តែ មិនដឹងពីណាខ្លះទេ ។ ខ្ញុំសុំជម្រាបថា ខ្ញុំក៏ចោទបញ្ហាមួយចំនួនដែរក្នុងព្រឹត្តិការណ៍ដែលពូនោះណា ។ ដែលពូហ្នឹងគេចោទខ្ញុំផ្នែករដ្ឋការ លន់ នល់ ក៏គេចោទខ្ញុំដែរ ។ គេចោទខ្ញុំថា ខ្ញុំហ្នឹងធ្វើសមាគមខ្មែរក្រហម រហូតគេយកខ្ញុំទៅដាក់នៅគុលាការសឹកបន្ទាយត្រែង ហៅបន្ទាយត្រែង ។ កាលហ្នុងគេចោទខ្ញុំអីចឹងដែរ ។ ពេលខ្ញុំត្រឡប់មកពតស្រែពេលស្ងាច ស្រាប់តែកម្លាំងរដ្ឋការទាហានឈ្មោះ សក្តិ៣ លឹម ហេងទស្សនិទ្ទិស ។ ខ្ញុំមកដល់ផ្ទះ ស្រាប់តែគេឲ្យទម្លាក់គោចោល ។ ខ្ញុំថា ទម្លាក់នេះ ផ្ទះខ្ញុំ មានការងាររអី ខ្ញុំយកគោខ្ញុំទៅចងសិន ។ បើយ៉ាងម៉េចយ៉ាងម៉ាទៅវ៉ានែ៎ៗ ស៊ីដំណាំដាំផ្ទុះគេ ។ ដល់អីចឹងខ្ញុំយកគោទៅចង ។ ចងហើយគេទាញខ្សែមកប្រឹប ឲ្យខ្ញុំលើកដៃ ហើយចង ។ ខ្ញុំថា ចងខ្ញុំបាញ់ឥឡូវហ្នឹង? បាញ់ចោល? ខ្ញុំថាអីចឹង ។ ចងខ្ញុំបាញ់ចោល? ឈ្មោះសែប ប៉ក់ ទៅពីព្រះវិហារទៅ គេថា អញ់មានមេមានកើយរបស់អញ់ ។ ខ្ញុំថា បើមានមេមានកើយ មិនបាច់ទេ មិនបាច់មករកចងខ្ញុំទេ ។ មេកើយលោកនៅឯណា? ខ្ញុំទៅជួបដើម្បីដោះសាយ ។ ដល់អីចឹងគេអត់ចងទេ ។ អីចឹងគេជូនទៅដល់កន្លែងផ្ទះផ្នែកសឹករងឈ្មោះ លឹម ហេង ។ គេយកទៅដាក់អត់បាយម៉ាថ្ងៃវល់ល្ងាច ទឹកក៏មិនឲ្យផឹក ។ ដល់អីចឹង មានអាមួយធ្លាប់បួសជាមួយខ្ញុំរាប់រៀប រៀនជាមួយខ្ញុំឈ្មោះ សម ។ ខ្ញុំរៀបរាប់ឲ្យវែងណាក្លាយ ។ ។

ដានី ៖ បាទ ។

អាន ៖ ឈ្មោះ សម មកឃើញខ្ញុំនៅហ្នឹង គេដាក់អីចឹងត្រង់មាត់ទ្វារ៤ ចុងកាំភ្លើងគេដាក់ដួង់ទាំងអស់ ។ ខ្ញុំនឹកថា ខ្ញុំស្លាប់ហើយ បាយគេមិនឲ្យស៊ី ទឹកគេមិនផឹក ។ អា សម គេធ្លាប់រៀនសូត្រជាមួយគ្នា គេមោ ។ ដល់គេមោគេថា ម៉េចឯងមកនៅហ្នឹង! គេថាប៉ុនហ្នឹង ខ្ញុំមិនទាន់ឆ្លើយនឹងគេទេ ។ គេថាយ៉ាងម៉េចទេ ស្រាប់តែមួយសន្ទុះគេថា អឹស! អីចឹងហើយឯងល្មើសលោក ។ ដល់ពាក្យល្មើសលោក ខ្ញុំតបណ្តោយ ។ ខ្ញុំថា សម! លោកមុខឯងនេះយកអញ់មកបង្អត់បាយ ទឹកក៏អស់ដែរ ហើយឯងដឹងហើយផ្ទះសម្បែងអញ់ ស្រូវមានទាំងជង្រុក ស្រែមាន គោមាន ផ្ទះសម្បែងអញ់រស់នៅ បាយអញ់មានហូប ទឹកអញ់មានផឹក តែលោកឯងនេះយកអញ់មកបង្អត់បាយ លោករបស់ឯងល្មើសអញ់ណា, អាចោរម្រ៉ាយ ខ្ញុំថាអីចឹង ។ ខ្ញុំជេរម្រ៉ាយ ។ ដល់អីចឹងពូដល់សក្តិ៣ លឹម ហេង ។ គាត់ថា អាសម ឯងទៅធ្វើតុលាការកាត់ក្តីអីចាមួយអាហ្នឹង, អាល្អិតហ្នឹង ។ ខ្ញុំថា បើមិនមានសមត្ថភាពខាងតុលាការទេ យកអញ់មកបង្អត់បាយធ្វើអី, ខ្ញុំថាអីចឹង ។ រួចបានម៉ោង៣រសៀលហៅខ្ញុំយកទៅសួរ ។ គេថា អាអូនឯងឆ្លើយឲ្យត្រង់ណា ។ ខ្ញុំថា បាទ ខ្ញុំអត់ចេះវាចវេរអីទេ ។ គេថា ប្អូនឯងបានធ្វើប្រធានសមាគមខ្មែរក្រហមមែនទេ? ព្រះបាទ

អត់ទេ ។ ខ្ញុំមិនបានធ្វើទេ ។ អេ៎ គេថាច្បាស់ណាស់ ។ ខ្ញុំថា អត់ទេ ។ ខ្ញុំថា អត់ពីរបីដងនៅតែច្បាស់ ខ្ញុំថា ព្រះតេជគុណ ការពិតរបស់ខ្ញុំវាមិនមែន រួចព្រះតេជគុណ មកសន្កត់ខ្ញុំចង់ឲ្យខ្ញុំថាតាមព្រះតេជគុណឬយ៉ាងម៉េច ។ ខ្ញុំដឹងថា ព្រះតេជគុណរកយុត្តិធម៌ឲ្យខ្ញុំ មកសន្កត់ខ្ញុំអីចឹង តើឲ្យខ្ញុំថាយ៉ាងម៉េចទៅវិញ ឲ្យថាតាមព្រះតេជគុណថាខ្ញុំបានធ្វើមែនអីចឹងឬ? ហេស! គ្មានអាណាគេថាអីចឹងទេ ។ បើមិនថាអីចឹង បើខ្ញុំវាអត់ ។ ចុះអាណាធ្វើប្រធានសមាគម? ខ្ញុំថា សមាគមខ្ញុំដែលដឹងដែរ សមាគមហ្នឹងគេធ្វើបុណ្យ គេទិញកន្ទេល ខ្នើយ ចាន ឆ្នាំង ស្លាបព្រា ចង្កៀងម៉ាសុង គឺសម្រាប់យកទៅធ្វើបុណ្យ មានអ្នកណាខ្ចីយកទៅធ្វើបុណ្យ ខ្ញុំដឹងដែរ ។ គេថា ចុះនរណា? ខ្ញុំថា មែន សុះ ។ ប្រាប់តែខ្មោចសាប់ សាប់ពីរបីថ្ងៃមុននឹងអី ។ គាត់ហ្នឹងឯងប្រធាន ខ្ញុំថាអីចឹង ។ ដល់រួចបានថា អូនឯងឆ្លើយត្រង់, ថាត្រង់ហើយ ខ្ញុំនិយាយអីចឹង ។ រួចបានថា ហ៊ានទៅផ្ទះទេ? ខ្ញុំថា ធម្មតាផ្ទះ តេជគុណអើយ នៅដល់ណាក៏ហ៊ានទៅដែរ ខ្ញុំនិយាយអីចឹង ។ ទេ អត់ទៅទេ ខ្ញុំថា ។ ម៉េច? ធ្វើសំបុត្រឲ្យខ្ញុំ បានខ្ញុំទៅ ។ ចុះម៉េច? ខ្ញុំថាទេ ទៅដល់ណោះ ទាហាន ព្រះតេជគុណនឹងចាប់គាពាស ចាប់ហើយសួរខ្ញុំថា មានអាតូមិច? ចុះអាតូមិចណា ខ្ញុំមិនដែលស្គាល់ឈ្មោះដងនោះ ។ នេះខ្ញុំជម្រាបពីប្រវត្តិខ្ញុំអីចឹងណា ។

ដារ៉ា : អីចឹងក្រោយមក បានដោះលែងអីដែរ?

អាន : លែង, ធ្វើសំបុត្រឲ្យមក ។ ខ្ញុំថា ព្រះតេជគុណ ធ្វើរបៀបនេះបែកខ្មាយកម្លាំងអស់ហើយ ព្រះតេជគុណ, ខ្ញុំថាអីចឹង ។ ដូច្នេះ ការធ្វើរបៀបនេះ គឺព្រះតេជគុណ កំចាយ ឬបំផ្លាញ កម្លាំងអស់ហើយ ។ ពលរដ្ឋ រាស្ត្រចេញពីសម្តេច, ខ្ញុំនិយាយអីចឹង ឲ្យតែធ្វើរបៀបនេះ អស់ហើយកម្លាំង ដោយពុថា ខ្មែរក្រហមនៅព្រៃនៅផ្សែងដង អស់ហើយកម្លាំង ។

ដានី : ចុះអ៊ំថា មានមហាបាតុកម្ម អ្នកដឹកនាំគឺតា ១៥ កាលហ្នឹងបាតុកម្មនៅខែណាឆ្នាំណា?

អាន : នៅថ្ងៃ១៨ ខែ ៣ ឆ្នាំ៧០ហ្នឹង ក្រោយមកប៉ុន្មានថ្ងៃ, អត់ចាំទេ ។

ដានី : ក្រោយមកប៉ុន្មានថ្ងៃឬ?

អាន : បាទ ។

ដានី : ក្នុងខែ៣ ហ្នឹងដែរ?

អាន : បាទ ។

ដានី : ក្នុងបាតុកម្មគេរៀបចំអីយ៉ាងម៉េច? ធ្វើនៅកន្លែងណា?

អាន : ហ្វូ គេធ្វើហែរគគ្រឹកគគ្រេង គេធ្វើនៅតាមបន្ទាយ នៅតាមស្អី ៗ ខាងផ្នែករដ្ឋបាល ។

ដានី ៖ កាលពីមុនរដ្ឋប្រហារ ដូចថាខាងតា ១៥ មេដឹកនាំផ្សេងៗគាត់មានមកស្រុកភូមិមកឃោសនាអីដែរទេ?

អាន ៖ អត់ដែលឃើញទេ។ ទាល់តែរដ្ឋប្រហារហ្នឹងបានគេចេញមុខប្រកាស ហើយលើកទង់រណសិរ្សដោយមានសម្ដេចជាប្រធាន។

ដានី ៖ កាលហ្នុងមានតា ១៥ មានពីណាទៀត?

អាន ៖ ខ្ញុំអត់ទេក្មួយ មានច្រើន។

ដានី ៖ ចុះខាង លន់ នល់ដែលចាប់អ៊ំទៅបន្ទាយត្រែង ចាប់ឆ្នាំណាខែណា?

អាន ៖ ឆ្នាំ៦៩ ។

ដានី ៖ អ៊ីចឹងចាប់មុនពេលព្រឹត្តិការណ៍ហ្នឹងទៀត?

អាន ៖ បាទ។

ដានី ៖ ចាប់៦៩ ខែណា?

អាន ៖ អត់ចាំ។

ដានី ៖ កាលហ្នុង យើងខែប្រាំងឬខែវស្សា ខែយើងស្ទូងស្រូវឬខែយើងច្រូតស្រូវ?

អាន ៖ អូ, ខែវស្សា។ ខ្ញុំមកពីស្រែ។

ដានី ៖ ខែវស្សា?

អាន ៖ បាទ។

ដានី ៖ ប្រហែលជាខែប៉ុន្មានទៅ?

អាន ៖ ខ្ញុំមកពីស្រែ ខែអសាធ។ ខ្ញុំមកពីស្រែស្ទូង។

ដានី ៖ ប្រហែលជាខែនេះ?

អាន ៖ បាទ ខែនេះឯង។

ដានី ៖ ខែ៧ ខែ៨?

អាន ៖ បាទ។

ដានី ៖ កាលហ្នុងគេចាប់តែអ៊ំម្នាក់ឯង ឬមានចាប់អ្នកណាផ្សេងទៀត?

អាន ៖ ម្នាក់ឯង។ ទៅដល់កន្លែងនោះ ប្រហែលខ្ទង់ ប៉ែតសិបជាងនាក់ ទាំងចាស់ ទាំងក្មេង ទាំងស្រី អីៗ។

ដានី ៖ កាលណោះ អ៊ំមានស្គាល់ពីណាខ្លះ?

អាន ៖ អត់តែគាចាស់ស្អីទេ ភ្លេចហើយក្មួយ ព្រោះខ្ញុំអត់បានទៅអាកន្លែងគេនោះផង។ រោងគេវែងដាក់អីចេះទៅ ខ្ញុំនៅរោងមួយម្នាក់ឯង ហ្នឹងហើយដែលខ្ញុំថា ងាប់។

ដានី :	ចុះ សម ដែលបួសរៀនជាមួយអ៊ីគេធ្វើទាហាន?

អាន :	ធ្វើទាហាន។គេសឹកហើយបានគេទៅធ្វើទាហាន។

ដានី :	កាលអ៊ីគេដោះលែងមកវិញ អ៊ីចាប់ផ្ដើមតស៊ូជាមួយខាងខ្មែរក្រហម ឬមិនទាន់ទេ?

អាន :	អត់ទេ។ ទល់មកថ្ងៃនេះឯង។

ដានី :	ថ្ងៃរដ្ឋប្រហារ?

អាន :	បាទ។

ដានី :	យ៉ាងម៉េចទៀត អ៊ីអាចរៀបរាប់ពេលដែលអ៊ីចាប់ផ្ដើមចេញតស៊ូ ហើយតស៊ូយ៉ាងម៉េច រៀបចំយ៉ាងម៉េច ហើយអ៊ីទៅតស៊ូកន្លែងណាខ្លះ?

អាន :	ខ្ញុំគេរៀបចំឲ្យខ្ញុំ ដំបូងគេហៅស្អីទេ រៀបចំឃោសនា ហៅថា លន្លាវុធ។ ពាក្យលន្លាវុធ មានកម្លាំង មានអាវុធស្ពាយដើរទៅឃោសនាទៅ ប្រមូលកម្លាំងទៅ។ ហ្នឹងហៅថា លន្លា វុធ ខ្ញុំហៅតាមគេ។ ហើយខ្ញុំមិនយល់ដែរ ហៅថា លន្លាវុធ។ លន្លា បែបនិយាយពី គ្រឿងមានអាវុធស្ពាយអីចឹងណា ហើយដើរអីចឹងទៅហើយឃោសនា ចូលភូមិនេះ ចូលភូមិនោះទៅ គឺដើរឃោសនាដោយមានប្រដាប់អាវុធទៅ។

ដារ៉ា :	អ៊ីពុកការឃោសនា ពុតាមរបៀបយ៉ាងម៉េច? ពុតាមវិទ្យុដែលបានស្ដាប់ ឬមានគ្នាគ្នាមក ប្រាប់អ៊ីអំពីការអំពាវនាវ?

អាន :	អំពាវនាវរបស់សម្ដេច? ស្ដាប់តាមវិទ្យុ។

ដារ៉ា :	អ៊ីស្ដាប់ដោយផ្ទាល់?

អាន :	វិទ្យុមាន, សម្ដេចផ្សាយអីចឹង។ ហើយដល់នេះ គេរៀបចំ មិនមែនខ្ញុំរៀបចំអីទេ។

ដានី :	ដូចថាមានការអំពាវនាវរបស់សម្ដេចហើយ មានគេអ្នកមករៀបចំទៀតអ៊ី?

អាន :	បាទ, ចូលមករៀបចំ ដូចខ្ញុំថា តា ១៥ នោះណា។

ដានី :	កាលណោះគឺក្នុងខេត្តកំពង់ឆ្នាំង នៅក្នុងស្រុកភូមិអ៊ី?

អាន :	បាទ, ប៉ុន្តែ គេមកមូលម្កាលទេណា។

ដានី :	កាលណោះគេរៀបចំកម្លាំងឃោសនា លន្លាវុធ កាលណោះ មានគ្នាប៉ុន្មាននាក់ ហើយពី ណាដឹកនាំ?

អាន :	គ្នា ១២នាក់ ហើយខ្ញុំមាក្រុមហ្នឹងគេដែរ។

ដានី :	អ៊ី ១២នាក់ដែរ?

អាន :	បាទ។

ដានី :	ហើយជាអ្នកដឹកនាំ១២នាក់?

អាន ៖ ដឹកនាំឃោសនា ទី១ វ៉ៃ លន់ នល់ ដែលធ្វើរដ្ឋប្រហារសម្តេច ។ ទី២ និយាយពីសម្តេចប្រកាសឲ្យយើងរួបរួមសាមគ្គីគ្នាដើម្បីធ្វើការតស៊ូទាមទារឲ្យសម្តេចនឹងវិលត្រឡប់ ។

ដានី ៖ កាលណោះ គ្នា១២នាក់ ឃោសនានៅកន្លែងណាខ្លះទៅ?

អាន ៖ នៅក្នុងស្រុកខត្តុង ។ ក្នុងស្រុកខត្តុងហ្នឹង មាន វាលពង់ ត្រាចទង វាលពន់ ក្នុងស្រុកខត្តុងកំពង់ស្ពឺ ។

ដានី ៖ ក្នុង១២នាក់ហ្នឹង អឺមានចាំខ្លះទេ?

អាន ៖ ដូចអស់ហើយ ។

ដានី ៖ ស្លាប់អស់ហើយ?

អាន ៖ បាទ ។

ដានី ៖ ឈ្មោះអីខ្លះទៅ?

អាន ៖ ឈួប ធ្វើឈួបកាលណោះវ៉ៃនៅម្តុំវាលពន់ហ្នឹង ស្លាប់ បើជម្រាបទៅដូចគ្មានបានការអីទេដឹង ស្លាប់បាត់អស់ហើយ ម៉ូត ហ៊ុយ យ៉ន អ្នកណាខ្លះទេស្លាប់អស់ហើយ ។ រួចខ្ញុំកាលណោះ ខ្ញុំហែលភក់ ។

ដានី ៖ ហែលយ៉ាងម៉េចអឺ?

អាន ៖ ចុះអារថពាសដែកវាមោនោះ រថពាសដែលវាមោ ខ្ញុំអន្តុយលើថ្នល់ ពីថ្ងៃវ៉ៃនៅសមរភូមិខាងហុងឈូក ខាងកំពង់ឆ្នាំងនេះ ដល់ថ្ងៃល្ងាចឡើងវាឆ្លងមកកំពង់ស្ពឺ វាលពន់ វាលអីនេះ ។ ដល់វាវ៉ៃហើយ វាចូលក្នុងវត្តហៅវត្តផ្លាចាស់ ។ ដល់ចូលហ្នឹង ខ្ញុំក៏ដាក់ផែនការដាក់ផែនការថា វើយល្ងាចនេះវ៉ៃវាឆាឆៅវារហូត កុំឲ្យវាពង្រឹងលេនដ្ឋានបាន ។ វ៉ៃឈួបកុំពង្រឹងលេនដ្ឋានបាន អីចឹងនាំគ្នាទៅវ៉ៃ ។ អត់ទាន់វ៉ៃទេ កំពុងតែនិយាយគ្នា ប្រជុំហ្នឹងផ្លូវអីចឹង ស្រាប់អានោះវាយកស្កុតមកដឹកខ្មោចដែលងាប់ពីថ្ងៃនោះ ដល់មកវាអត់បញ្ចេះទេវាឲ្យគ្នាវារុញព្រួគ្រឹកៗ កំពុងនិយាយគ្នាដាក់ផែនការអីចឹង និយាយកណ្តាលផ្លូវ កំពុងដាក់ផែនការ ក៏ឮសូរគ្រឹកៗ ។ ស្អីវ៉ៃ? ខ្លះថា ត្រាក់ទ័រដឹកធ្យូង ។ គ្រាន់តែថា អានោះដាក់ភ្លើងហ្វាក្វាប់ វាលេងអាដូសេតចេញពីអានោះមក ហើយស្រែនៅក្រោមនេះវារលួយនៅភក់លុក ហែលភក់ហ្នឹង ស្លាប់នៅហ្នឹង ។ ខ្ញុំហែលរួចទៅ ។

ដានី ៖ គ្នាប៉ុន្មាននាក់កាលណុង?

អាន ៖ គ្នាជិត ២០ នាក់ដែរ ។

ដានី ៖ រួចបានប៉ុន្មាននាក់ក្នុង២០នាក់ហ្នឹង?

អាន ៖ អត់ចាំទេ វែងពេកហើយ ។

ដានី ៖ ចុះអ៊ីតស៊ូយោនាលន្កាហ្នឹង ពីឆ្នាំណាដល់ឆ្នាំណាទៅ?

អាន ៖ ខ្ញុំនៅខត្តុងដល់ឆ្នាំ៧២, ហា ៧១ៗ សុំទោស ។

ដានី ៖ ខែណា?

អាន ៖ អត់ចាំទេ ។

ដានី ៖ ខែប្រាំង ឬខែវស្សា?

អាន ៖ មិនចាំទេ ។

ដានី ៖ ហើយយ៉ាំងម៉េចទៀតទៅ បន្ទាប់ពី៧១ទៅ?

អាន ៖ ដល់នេះទៅ គេផ្លាស់ខ្ញុំ ផ្លាស់ខ្ញុំទៅនៅត្បូងភ្នំពេញ ហៅស្រុកកណ្តាលស្ទឹង ក្នុង៧២-៧៣ នៅកណ្តាលស្ទឹង ។

ដានី ៖ អ៊ំទៅស្រុកកណ្តាលស្ទឹង គេផ្លាស់ពីហ្នឹងទៅឲ្យអ៊ំធ្វើអ្វី?

អាន ៖ ទៅនោះ ជាទិសដៅរបស់គេ ឲ្យខ្ញុំទៅគ្រប់គ្រងប្រជាជន ។ ក៏ប៉ុន្តែតំបន់នោះអត់មានប្រជាជនទេ ដូចតែទ័ពដដែល នៅបញ្ជាទ័ពដដែល ព្រោះប្រជាជនគេត្រូវដក់អស់រលីងទៅជាតំបន់ស ។ គេដកយកមកដាក់ខាងស្រុកបសែត កាត់ភ្លុកនេះ ហួសភ្នំស្រង់ ប្រជាជនគេឲ្យរស់នៅហ្នឹង ហើយខ្ញុំគេឲ្យរស់នៅនេះ ។ កម្លាំងកងទ័ពហៅថា កងពល១០១ ។

ដារ៉ា ៖ អីចឹងចាប់ផ្តើមមានជាកងពល កងអី មានអីអស់ហើយ?

អាន ៖ បាទ អាហ្នឹងខ្ញុំវ៉ៃ ចាប់ផ្តើមវ៉ៃហើយ ។

ដានី ៖ មើលក្នុងកងពល១០១ ហើយប្រធានកងពលអី អនុប្រធានកងពលអី?

អាន ៖ ខ្ញុំស្នងការនយោបាយ ។

ដារ៉ា ៖ ចុះប្រធានកងពល?

អាន ៖ អាណុងមោ ...ភ្លេចឈ្មោះហើយ ។

ដានី ៖ ចុះអ៊ំ ប្រធានស្នងការនយោបាយ ជាប្រធានកងពលឬ? យើងជាប្រធាននយោបាយអីចឹងបានន័យថា យើងជាប្រធានកងពល?

អាន ៖ បាទ ។

ដានី ៖ អ្នកទទួលយោធា?

អាន ៖ បញ្ជាការ ។

ដានី ៖ យោធាជាអនុ?

អាន ៖ បាទ ។

ដានី ៖ ខាងសេដ្ឋកិច្ចជាសមាជិក?

អាន ៖ បាទ ៗ

ដានី ៖ អីចឹងអ៊ីជាប្រធានកងពល១០១ហ្នឹងតែម្តង?

អាន ៖ បាទ ៗ

ដានី ៖ កាលអ៊ីផ្លាស់ទៅឆ្នាំ៧១ គេឲ្យអ៊ីទៅគ្រប់គ្រងប្រជាជននៅស្រុកកណ្តាលស្ទឹង ពីណាគេផ្លាស់អ៊ីទៅ?

អាន ៖ តា ម៉ុក ៗ

ដានី ៖ កាលហ្នឹងផ្លាស់អ៊ីទៅជាគណៈស្រុកកណ្តាលស្ទឹង?

អាន ៖ បាទ, ទៅក្នុងនាមថា ជាគណៈស្រុក ៗ ក៏ប៉ុន្តែអត់មានប្រជាជន អត់មានទេ ៗ គេហៅតំបន់ស តំបន់ប្រយុទ្ធខ្លាំង ៗ ប្រជាជនគេដកមកក្រោយ ៗ

ដារ៉ា ៖ ដល់អីចឹងទៅ អ៊ីជាកងទ័ពប្រធានកងពល១០១?

អាន ៖ បាទ ៗ ខ្ញុំនិយាយអាមូលហេតុហ្នឹងបន្តិចណា ព្រោះខ្ញុំនិយាយទៅវាស្មុគ ៗ មូលហេតុដែលយកខ្ញុំទៅ ទី១ឲ្យទៅគ្រប់គ្រងហ្នឹង នេះដោយសារអ្នកដែលគេគ្រប់គ្រងខាងដើមឈ្មោះគុណ មិនដឹងប្រព្រឹត្តសកម្មភាពអីទេ ដល់អីចឹងកូនទាហានចាប់ ៗ កូនទាហានបញ្ជូនមកក្រោយ កូនទាហានរបស់ខ្លួនឯងហ្នឹង ដល់គ្រប់គ្រងមិនបាន ក៏តា ម៉ុក ដកខ្ញុំយកមកគ្រប់គ្រង ៗ

ដារ៉ា ៖ ដោយសារ តា ម៉ុក គាត់ឃើញស្នាដៃអ៊ី?

អាន ៖ អត់ទេ ៗ គេដកណោះ ៗ កូនទាហានខ្លួនចាប់ ចាប់មេបញ្ជូនមកខាងក្រោម ដល់អីចឹងទៅការគ្រប់គ្រងអត់បាន ក៏យកខ្ញុំពីហ្នឹងទៅ ៗ

ដារ៉ា ៖ អីចឹង តា ម៉ុក ស្គាល់អ៊ី ចាត់តាំងអ៊ីតាំងពី?

អាន ៖ ស្គាល់អ៊ីតាំងពីមហាបាតុកម្មនោះ ៗ

ដានី ៖ ស្គាល់ពេលធ្វើមហាបាតុកម្ម?

អាន ៖ បាទ ៗ

ដានី ៖ ពេលអ៊ីទៅគ្រប់គ្រងប្រជាជន អត់មានប្រជាជន ហើយគ្រប់កងពល ១០១ ហ្នឹងកងពលរបស់អីគេទៅ?

អាន ៖ កងពលរបស់ភូមិភាគនិរតី ៗ ក្រោយមកបានចូលក្នុងកងពលភាគពិសេស ៗ

ដានី ៖ អ៊ីអាចរៀបរាប់កន្លែងហ្នឹងបន្តិចបានទេ ខ្ញុំអត់ទាន់យល់ច្បាស់ពីរចនាសម្ព័ន្ធកងទ័ពនិរតីពេលហ្នឹងអ៊ី? ដូចថា កាលណោះមានប៉ុន្មានកងពល? មានឈ្មោះអីខ្លះទៅ? ដូចអ៊ីកងពល ១០១?

អាន ៖ ១០១ នៅនិរតី ក្រោយមកនៅជាមួយកងពលភាគពិសេស គាត់ចូលភាគពិសេស ។

ដានី ៖ ចាប់ពីអន្លង់វែងមោដែលកងពល១០១គេចាត់ចូលជាកងពលពិសេស?

អាន ៖ តាំងពីខ្ញុំទៅនៅណោះ ។ នៅក្នុងភូមិភាគពិសេស ពេលដែលខ្ញុំផ្លាស់ទៅហ្នឹង ។ ខ្ញុំនិយាយសារឡើងវិញ ពិមុនមោកន្លែងខ្ញុំធ្វើការនៅខត្តុងហ្នឹង ជាភាគនិរតីទេ ។ ពេលដែលខ្ញុំដកខ្ញុំទៅទទួលនោះ ពេលនោះកាត់ចូលទៅក្នុងភូមិភាគពិសេសទាំងអស់ ទាំងម៉ាជ្ជាំងកាត់ទៅទាំងអស់ នៅឆ្នាំ៧២ ។ ចាំមិនប្រាកដណាក្នុយ ក្នុង៧២ ឬ៧៣ហ្នឹង ។ មានតែ២ ដូចនេះ អានេះចាំអត់ប្រាកដ ។

ដានី ៖ មិនដឹងពី៧២ ឬ៧៣ទេ គេពីភូមិភាគនិរតីមកភូមិភាគពិសេសវិញ?

អាន ៖ បាទ ។

ដានី ៖ អ៊ីចឹង ឆ្នាំ៧២-៧៣ ពីកន្លែងត្រឹមណាទៅដែលគេកាត់មកភូមិភាគពិសេសវិញ?

អាន ៖ ស្រុកខត្តុង ផ្នែកខាងជើងគឺស្រុកខត្តុងទាំងមូល ។

ដានី ៖ កន្លែងណាទៀត?

អាន ៖ នៅខាងត្បូងផ្លូវជាតិលេខ ៤ នៅជុំវិញភ្នំពេញយើងហ្នឹង ចាប់ពីស្រុកកណ្តាលស្ទឹង ស្រុកដង្កោរ អាណឹងភាគពិសេស ។ ចាប់ពីសំរោងទង គឺមកនិរតី ចាប់ពីសំរោងទងមោ ។

ដានី ៖ ភូមិភាគ មានស្រុកដង្កោរ ស្រុកកណ្តាលស្ទឹង ។ ចុះភ្នំស្រួច ខាងច្បារមន ខាងថ្ពង?

អាន ៖ អាណឹងនៅខាងជើងផ្លូវ ។

ដានី ៖ អាណឹងភូមិភាគពិសេស?

អាន ៖ បាទ, ភូមិភាគពិសេស ផ្លូវជាតិលេខ ៤ ។

ដានី ៖ ភូមិភាគពិសេស ពីណាគេដឹកនាំ?

អាន ៖ វ៉ន វ៉េត ។

ដានី ៖ បន្ទាប់ពី វ៉ន វ៉េត មានពីណាទៀត?

អាន ៖ អត់ចាំអស់ទេ ។ វ៉ន វ៉េត ឃើញតែម្តងអ្នកនេះ ម្តងអ្នកនោះ ឃើញតែរគាត់រគាយ មិនដឹងអ្នកណា ។

ដានី ៖ ចុះអ៊ីស្គាល់ ចេង អន ដែរ?

អាន ៖ ហ្នឹងហើយ ចេង អន ដែរ វ៉ន វ៉េត ស្ទីនែ៎ ចេង អន ហង្ស ។ ប៉ុន្តែដឹង ហង្ស ចេង អន

ដានី ៖ ហង្ស ណា? ប៊ូ ផាត់ ហៅ ហង្ស គាត់ទៅក្រោយទៅជាលេខាភូមិភាគ?

អាន ៖ ហង្ស ពុក្រោយមកថា ស្លាប់ ។

ដានី ៖ លេខភូមិភាគ១០៣?

អាន ៖ អត់ទេ, ក្រោយមកពួថា ស្លាប់ៗ

ដានី ៖ កងពលពិសេស មានប៉ុន្មានកងពល អឺថា កងពល១០១ អឺថា កាត់ពីភូមិភាគនិរតី មកភូមិភាគពសេសវិញ?

អាន ៖ កងពល ១២ ៗ ៩២០ ៗ

ដានី ៖ មានប៉ុន្មានទៀត?

អាន ៖ អត់ដឹងទេ ៗ

ដានី ៖ មាន ១២, ៩២០ និងកងពល ១០១ របស់អឺ?

អាន ៖ កងពល១០១... សុំទោសច្រឡំទេ ៗ ១១ មិនមែន១០១ទេ ៗ

ដានី ៖ កងពល១១?

អាន ៖ កងពល ១១ មិនមែន ១០១ទេ ៗ កងពល ១១ ៗ

ដានី ៖ កងពល ១១, ១២ និង ៩២០?

អាន ៖ បាទ ៗ កងពល១២ គឺណាត ៗ

ដានី ៖ កងពល ១២ ឈ្មោះ តា ណាត

អាន ៖ បាទ, អីចឹងណាក្ដួយ សុំទោស ៗ

ដាវ៉ា ៖ ចុះ ៩២០ អ្នកណាវិញ?

អាន ៖ ៩២០ ហ្នឹង រឿន ហៅ ០៥ ៗ

ដានី ៖ សូ សារឿន ហ្នឹងអឺ? រឿន ០៥?

អាន ៖ បាទ, នាមត្រកូលខ្ញុំអត់ដឹង ៗ

ដាវ៉ា ៖ ចុះណាត ហៅអីផ្សេងទេ?

អាន ៖ អត់ទេ ៗ

ដានី ៖ អីចឹងកងពល ១១ អឺប្រធាន ៗ ចុះបន្ទាប់ពីអឺ?

អាន ៖ អាណឹងគេយកមកពីភាគខាងជើងផង ៗ

ដានី ៖ ឈ្មោះអី?

អាន ៖ ឈ្មោះ ណន ៗ ណន ហ្នឹងសមាជិក ៗ ខ្ញុំភ្លេចច្រើនណាស់ ៗ អម្បាញ់មិញនឹកឃើញ ដល់មៅបាត់ទៅ មេបញ្ជាការ មើលនឹកឃើញភ្លាម បាត់ភ្លាម ៗ

ដានី ៖ ចុះតា សោម?

អាន ៖ ហ្នឹងហើយ ។ អាណឹងអនុប្រធានខ្ញុំទេ ។ សោម ក្រោយមកពេលឈ្មោះភ្នំពេញហើយ គេធ្វើស្អីទេ ។

ដារ៉ា ៖ ចុះ ណន កាន់កាប់ផ្នែកអីគេអ៊ី?

អាន ៖ ជា សេដ្ឋកិច្ច ។

ដារ៉ា ៖ ហើយ សោម នេះជាមេបញ្ជាការកងទ័ព ។

អាន ៖ បាទ, ក្មួយដឹងដែរ ។

ដារ៉ា ៖ ខ្ញុំបានអានឯកសារ ហើយក្នុងរចនាសម្ពន្ធ័កងពល័ ឲ្យតែប្រធានគឺទទួលខុសត្រូវផ្នែកនយោបាយ អនុប្រធានដែលកាន់សេដ្ឋកិច្ចមួយទៅ មានអនុប្រធានមួយទៀត កាន់ខាងកងទ័ព ។ អីចឹងអ៊ីបានខ្ញុំសួរបញ្ជាក់ហ្នឹង?

អាន ៖ បាទ ។

ដានី ៖ អីចឹងកងពល១១របស់អ៊ី ខាងមុខព្រៃញណាទៅ? នៅកណ្តាលស៊ីង?

អាន ៖ បាទ, នៅប្រចាំនៅហ្នឹង ។ ម៉ាដូរផ្សារកន្ទួត ទួលកីទៅ ។

ដានី ៖ អ៊ីស្គាល់តា វឿនដែរ? មាស វឿន, តា វឿន គាត់នៅកំពង់ស្ពឺ?

អាន ៖ អត់ទេ ។

ដារ៉ា ៖ នៅពេលដែលធ្វើប្រតិបត្តិការនៅក្នុងស្រុកទាំងប៉ុន្មានដែលរៀបរាប់មកហ្នឹង មុននឹងខ្មែរក្រហមបានជោគជ័យមក អ៊ីមានដែលឃើញជាជនបរទេស ដូចជាពួកស្បែកស ពួកប្រមុះស្រួចអីធ្វើដំណើរឆ្លងកាត់ទៅតាមតំបន់ ទៅស្រុកកន្លែងដែលអ៊ីប្រតិបត្តិការ តើអ៊ីធ្លាប់ជួបប្រទះទេ?

អាន ៖ មិនដែលទេ, តំបន់ស ។

ដារ៉ា ៖ តំបន់ស គឺមានន័យថា..

អាន ៖ ក្តៅ

ដារ៉ា ៖ ក្តៅ គឺថា សម្រាប់តែសមរភូមិរវាងចលនាខ្មែរក្រហមជាមួយ លន់ នល់ តែម្តង?

អាន ៖ បាទ ។

ដានី ៖ ក្រែងលោអ្នកកាសែតទៅយកព័ត៌មាន ហើយមានគេចាប់?

អាន ៖ អត់ដែលមាន ។

ដានី ៖ កាលជិតទាន់ហ្នឹងគេវៃជាមួយពួក លន់ នល់ ដូចថា មានអាមេរិកាំងគេមោ មានអ្នកកាសែតអីពេលវៃ?

អាន ៖ អត់ដែលឃើញទេ, និយាយតាមត្រង់ អត់ជួប ។

ដានី : កងពលអ៊ី បើសរុបទៅមានកងទ័ពចំនួនប៉ុន្មានដែរ?

អាន : ម៉ាអនុសេនាធំ វា ៣០០ ។ ....៣ វរសេនាតូច, កងពលតូច ។

ដានី : កាលណោះអត់មានវរសេនាធំទេ?

អាន : ម៉ាវរសេនាតូច ៣០០ ហើយម៉ាវរសេនាធំមាន៣អាណឹងទៀត ។

ដានី : អ៊ីចឹង ម៉ាកងពលតូច មានប៉ុន្មានវរសេនាធំ?

អាន : ៣

ដានី : អ៊ីចឹង ៩០០ បីដងវាឡើងដល់ទៅ ២៧០០

អាន : បាទ

ដានី : ចុះមានវរសេនាតូចឯករាជ ដែរអត់?

អាន : អាណឹងតាមកងពលទេក្មួយ ។ កងពលខ្លះមាន កងពលខ្លះអត់ ។

ដារ៉ា : អ៊ឹ, ខ្ញុំសុំបញ្ជាក់ម្តងទៀតកន្លែងកងពល១១ របស់អ៊ីហ្នឹង ។ អ៊ីថា មានតែ៣វរសេនាតូចទេ អ៊ីចឹងមានន័យថា ឡើងទៅកងពលម៉េចកើត បើមានតែ៣វរសេនាតូច?

អាន : ក្នុងម៉ាវរសេនាតូច មាន ៣០០ ដូច្នេះក្នុងម៉ាវរសេនាធំ វាមិន ៦០០ (អ្នកខាងក្រៅថា ៩០០)

ដារ៉ា : អ៊ីចឹងអ៊ឹមាន៣វរសេនាតូច បានតែ ៩០០ទេអ៊ីចឹង? អត់ទាន់ដល់ឡើងទៅកងពលទេ?

អាន : ទេ ឡើងហើយ ។ ខ្ញុំច្រឡំទេ ។ ខ្ញុំរាប់ច្រឡំទេ ។

ដានី : អ៊ីចឹងវាមាន៣វរសេនាធំ នៅកងពលអ៊ី?

អាន : បាទ, ៣ វរសេនាធំ ។

ដារ៉ា : អានេះបានបង្កើតជាកងពលបាន?

អាន : បាទ, វា៣វរសេនាធំ ។

ដារ៉ា : អ៊ឹមានចាំទេ ប្រធានវរសេនាធំមួយៗមានឈ្មោះអី?

អាន : ចាំ ប៉ុន្តែវាអស់ទៅហើយ ។

ដានី : គាត់ឈ្មោះអីខ្លះ?

អាន : សាយ ។

ដានី : វរសេនាធំលេខប៉ុន្មាន?

អាន : ឆ្នុន, ពិបាកចាំ ។

ដារ៉ា : សាយ មនុស្សមកពីខាងណា?

អាន : កណ្តាលស្ទឹង ។

ដារ៉ា : ធុន?

អាន : នៅហ្នឹងទាំងអស់ ។ ទាល់ស្រាវជ្រាវអត់ចាំទេក្មួយ ។

ដារ៉ា : ទាល់តែអ៊ំរលឹកឡើងវិញដែរណាអ៊ំ រឿងរ៉ាវវាកន្លងច្រើនឆ្នាំហើយអ៊ំ ។

អាន : ខ្ញុំអត់បានគិតអត់បានគូរអីទេ ។

ដានី : ចុះកាលហ្នឹង អ៊ំ ប៉ូច គាត់កាន់កងពលលេខប៉ុន្មាន?

អាន : អត់ទេ ។

ដានី : កងពល១១ ធ្វើប្រតិបត្តិការរហូតដល់ឆ្នាំណាទៅ នៅម្តុំកណ្តាលស៊ីង?

អាន : រហូតដល់ឈ្នះភ្នំពេញ ។

ដារ៉ា : អ៊ីចឹងមុខព្រួញកងពលអ៊ំ ពេលដែលវាយចូលភ្នំពេញ អ៊ំវាយចូលតាមទិសដៅមួយណាដែរ?

អាន : តាមមុខសញ្ញាឡើងតាម ទួលគីនោះ ។

ដារ៉ា : ទួល គី ម្តុំណាអ៊ំ?

អាន : ផ្លូវជាតិលេខ ៣ ។

ដារ៉ា : វាយមកតាមផ្លូវជាតិលេខ ៣ ចូលមកតាមពោធិ៍ចិនតុង?

អាន : ដែលម៉ាផ្លូវពោមពៅ ចំរុះ ។

ដារ៉ា : ពេលវាយចូលភ្នំពេញ តាមកងពលអីគេមានដឹងពីផែនការនៃការវាយឈ្នះដែរ? វាយឈ្នះទីក្រុងភ្នំពេញ ថ្ងៃ១៧ មេសា ថាមុននឹងបែក តាមកងពលនីមួយៗបានដឹងខ្លួនទេ ថាយើងពិតជាឈ្នះហើយយើងសម្រេចយកពេលណាអីពេលណា?

អាន : អាណឹងគោលការណ៍គេលើក ។ គេត្រៀមសម្ភារៈវាយផ្តាច់ ។ ត្រង់ថា ដាច់ឬមិនដាច់នោះយើងមិនអាចកំណត់បានទេ ។ ក៏ប៉ុន្តែជាផែនការយើងត្រៀមទាំងអស់ដើម្បីវាយផ្តាច់ ។ ហើយក្នុងគោលការណ៍វាយផ្តាច់ហ្នឹង វាពិបាកនិយាយណាស់ ។

ដារ៉ា : ចុះខាងទ័ពអីចឹង ដឹងតែវាយផ្តាច់អីចឹង ឬមានការទទួលខុសត្រូវអីផ្សេង ឬគិតតែពីការងារកងទ័ព?

អាន : មានអីចេះ?

ដារ៉ា : ខ្ញុំចង់សួរថា តើពេលវាយផ្តាច់ ខាងទ័ពមានបញ្ញាឲ្យវាយផ្តាច់ចូលក្រុងភ្នំពេញ ឬមានភារកិច្ចអីផ្សេងទៀត បើសិនជាវាយចូលភ្នំពេញជោគជ័យហើយមានភារកិច្ចអីផ្សេងទៀតអីចឹងណាអ៊ំ?

អាន : អត់ដឹងទេ ។

ដានី ៖ ចុះអ៊ឹ កាលណោះ មេបញ្ជាការដែលចុះមោតាមកងពល ដូចថា អ្នកណាគេជាអ្នករៀបចំកងទ័ព?

អាន ៖ ភាគពិសេស គឺ វ៉ន វ៉េត ។

ដានី ៖ អ៊ីចឹង វ៉ន វ៉េត ដាក់បញ្ជាមោកងពល ដូចថា កងពលអ៊ឹ ១១ កងពល១២ កងពល៩២០ វ៉ន វ៉េតគាត់អ្នកទទួលខុសត្រូវទាំងអស់?

អាន ៖ បាទ

ដានី ៖ មានអ្នកផ្សេងទៀតអត់?

អាន ៖ ខ្ញុំអត់ចាំ ខាងគណៈភូមិភាគគេ ។

ដាវ៉ា ៖ ចុះតា ម៉ុក គ្រប់គ្រងខាងណាវិញអ៊ឹ?

អាន ៖ តា ម៉ុក, និរតី ។

ដាវ៉ា ៖ ហើយដល់អ៊ឹមោភូមិភាគពិសេស មាន វ៉ន វ៉េត ហើយមានកងពល ១២ និង ៩២០ ។

អាន ៖ បាទ ។

ដានី ៖ ចុះតា សឿង?

អាន ៖ សឿង ណាទេ ។

ដានី ៖ ពេលអ៊ឹចូលភ្នំពេញតាមទួលគី ដល់ពេលយើងទទួលជោគជ័យ ១៧ មេសា កងពលអ៊ឹឈរជើងនៅទីណាទៅ?

អាន ៖ កម្លាំងត្រូវដកមកប្រចាំនៅមុខសញ្ញារបស់ខ្លួន ។ ឯខ្ញុំ ឯកឧត្តម សុន សេន ហៅទៅប្រជុំនៅសាលាខេត្តកណ្ដាលតាខ្មៅ ។ ចប់ហើយហៅទៅប្រជុំ ដល់ហៅទៅប្រជុំប្រាប់ថា មិត្តមិនបានទទួលខុសត្រូវខាងកងទ័ពទៀតទេ មិត្តត្រូវទៅទទួលខុសត្រូវខាងមូលដ្ឋាន គេដកខ្ញុំមកហើយ ។

ដាវ៉ា ៖ កាលហ្នឹងចាំជាថ្ងៃខែឆ្នាំដែរ ដែល សុន សេនហៅទៅប្រជុំ?

អាន ៖ អត់ចាំទេ ។ ក្រោយឈ្នះភ្នំពេញ ។

ដានី ៖ ក្រោយឈ្នះបានរយៈពេលប៉ុន្មាន?

អាន ៖ អត់បាន១ខែទេ ។

ដាវ៉ា ៖ អ៊ីចឹងនៅពេលដែល សុន សេន ប្រាប់ហើយប្រាប់ថា ទៅទទួលមូលដ្ឋានអ៊ីចឹងវិញ ភ្លាមៗអ៊ឹរៀបអ៊ីវ៉ាន់អីទៅកន្លែងមូលដ្ឋានតែម្ដង ឬយ៉ាងម៉េច? ហើយមូលដ្ឋានគឺសំដៅកន្លែងណា?

អាន ៖ បាទ, ដល់មកមូលដ្ឋានគេប្រគល់ឲ្យទទួលនៅខេត្តកណ្ដាល ។

ដាវ៉ា ៖ ខេត្តកណ្តាលទាំងមូលតែម្តង?

អាន ៖ មិនមែនមានតែខ្ញុំទេ គឺមាន ជា ប្រាក់ ស៊ាន ក្នុងគណៈកម្មការ ហើយខ្ញុំ ។

ដានី ៖ កាលណោះខេត្តកណ្តាលមានន័យថា តំបន់២៥អី?

អាន ៖ បាទ ។

ដានី ៖ កាលណោះចាប់ពី សុន សេនហៅអីទៅប្រជុំនៅសាលាខេត្តកណ្តាល បានន័យថា អីទៅប្រជុំនៅតំបន់ ២៥?

អាន ៖ អត់ទេ នៅសាលាខេត្តតែម្តង ។

ដានី ៖ កាល សុន សេន ហៅអីទៅមានគ្នាប៉ុន្មាននាក់?

អាន ៖ មានគ្នាដូចខ្ញុំរៀបរាប់អម្បាញ់មិញ ជា ប្រាក់ក៏ទ័ពដែរ ។

ដានី ៖ ឈ្មោះ ជា ប្រាក់ ស៊ាន ហើយអី?

អាន ៖ ស៊ាន ។

ដានី ៖ គ្នា ៤នាក់ហ្នឹង គេឲ្យទៅគ្រប់គ្រងតំបន់ ២៥?

អាន ៖ បាទ ។

ដានី ៖ មន្ទីរតំបន់២៥ នៅកន្លែងណាទៅ?

អាន ៖ នៅច្រើនកន្លែង ។ ខ្ញុំប្រចាំនៅកោះធំ ។ ប្រធានគេនៅសាលាខេត្ត ។

ដានី ៖ កាលណោះប្រធានឈ្មោះអីទៅ?

អាន ៖ ឈ្មោះ ជា ។

ដានី ៖ ប្រធានឈ្មោះ ជា?

អាន ៖ បាទ ។

ដានី ៖ គេហៅថា លេខាតំបន់?

អាន ៖ បាទ ។

ដានី ៖ ឈ្មោះ ជា ចុះឈ្មោះ ប្រាក់?

អាន ៖ ប្រាក់ អនុលេខា ។

ដានី ៖ ស៊ាន?

អាន ៖ សមាជិក ។

ដានី ៖ ចុះអី?

អាន ៖ ខ្ញុំសមាជិកដែរ ។

ដានី ៖ អីចឹងសមាជិក ៤នាក់?

អាន ៖ បាទ ។

ដានី ៖ ហើយមានអ្នកផ្សេងទៀតអី?

អាន ៖ អត់ទេ ។

ដានី ៖ កាលណោះ ជា គឺលេខា គាត់ទទួលខាងអីទៅ?

អាន ៖ នយោបាយ ។

ដានី ៖ ប្រាក់?

អាន ៖ អាណឹង ផ្នែកយោធា ។ សមាជិកទី១ ខាងសេដ្ឋកិច្ច ។

ដានី ៖ ចុះអ៊ំខាងអីទៅ?

អាន ៖ ខ្ញុំ កាលណោះ គេចាត់មោខាងស្រុកវិញមោ ។

ដានី ៖ អ៊ំជាសមាជិកតំបន់ ទទួលស្រុកណាខ្លះ?

អាន ៖ ខ្ញុំមោ ស្រុកកៀនស្វាយ, អូរ៉ាំង ស្អាង ។

ដានី ៖ អ៊ំជាលេខាស្រុកស្អាង?

អាន ៖ បាទ

ដានី ៖ លេខាស្រុកស្អាង តែតួនាទីជាសមាជិកគណៈ?

អាន ៖ ជាប់ជាសមាជិករបស់គណៈកម្មការ

ដារ៉ា ៖ ជាសមាជិករបស់គណៈកម្មការគេនោះ?

អាន ៖ បាទ ។

ដានី ៖ កាលណោះតំបន់២៥ មានប៉ុន្មានស្រុក?

អាន ៖ ចាំមើលខ្ញុំជម្រាបឲ្យច្បាស់ទៀតណា អាណឹងខ្ញុំនិយាយពីរយៈកាលនេះខ្វីណាស់ អត់ទាន់ទៅគ្រប់គ្រងអីបានត្រឹមត្រូវទេ ។ ៧៥ហ្នឹងដល់៧៦ ដកខ្ញុំបាត់ទៀតហើយ ដូច្នេះ ខ្ញុំអត់មានចាំអីច្បាស់លាស់ទេ ។ ក្នុងនាមដំណាក់កាលទីគឺអីចឹង អត់បានច្បាស់លាស់បញ្ហាអីទេ ។ ដល់អីចឹងបានដកខ្ញុំទៅទៀត មើលថ្ងៃប៉ុន្មានទេ ឈ្នះភ្នំពេញហើយ ចាត់តាំងខាងគណៈកម្មការខាង ២៥ ។ មិនបានប៉ុន្មានផង ៧៦ ដកយកទៅដាក់កំពតណោះ ។

ដានី ៖ ៧៦ ខែប៉ុន្មាន?

អាន ៖ ឆ្នាំ៧៦ ។

ដានី ៖ ខែប៉ុន្មាន?

អាន ៖ អាណឹង វាណាស់តែអីចឹង ។

ដានី ៈ ខែយើងដើមឆ្នាំ៧៦ ឬក៏ពាក់កណ្ដាល ឬចុងឆ្នាំ បើតាមអ៊ីចាំ? ឥឡូវអ៊ីចាំជាខែប្រាំង ឬខែវស្សា ឆ្នាំ៧៦ ដែលគេដកអ៊ីទៅកំពត?

អាន ៈ ចាំមើលខ្ញុំគិត ។ ៧៦ ខែប្រាំង ។

ដានី ៈ ខែប្រាំង ប្រហែលជាក្នុងខែប៉ុន្មានទៅ?

អាន ៈ ខែគេប្រមូលផលស្រូវហើយ ។

ដានី ៈ អាចខែ១ ខែ២ ឆ្នាំ៧៦?

អាន ៈ ប្រហែលខ្ទង់ប៉ុនណឹង ។ ព្រោះខ្ញុំទៅខាងណោះ ដែលខ្ញុំទៅសកម្មភាពទំបន់ប្រឡាយបណ្ដោយ ។

ដានី ៈ អ៊ីចឹងអ៊ី ខ្ញុំសុំបកទៅក្រោយបន្តិច ។ ដូចថា នៅតំបន់២៥ បើតាមខ្ញុំចាំ ដូចជាមានស្រុកកណ្ដាលស្ទឹង ស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ ស្រុកខ្សាច់កណ្ដាលដែរ?

អាន ៈ អត់ចាំទេ ។

ដានី ៈ ស្រុកខ្សាច់កណ្ដាល ហើយ?

អាន ៈ បើកណ្ដាលស្ទឹង ខ្ញុំធ្លាប់នៅ ។

ដានី ៈ កាលណោះ អ៊ីអត់មានធ្វើជាលេខាស្រុកកណ្ដាលស្ទឹងអីទៀតទេ?

អាន ៈ ពេលគេចាត់ទៅនឹង គឺលេខាស្រុកកណ្ដាលស្ទឹង ។ ប៉ុន្តែដល់ទៅ ទៅទទួលតែកងទ័ព វាអត់មានប្រជាជន ។

ដានី ៈ ពេលដែលប្រជុំនៅសាលាខេត្តជាមួយ សុន សេន ហើយ អ៊ីមានប្រសាសន៍ថា អ៊ីជាលេខាស្រុកស្អាង ចុះអ៊ីមានទទួលស្រុកកណ្ដាលស្ទឹងដែរទៀតអត់?

អាន ៈ កណ្ដាលស្ទឹង អត់ ប៉ុន្តែគេឲ្យស្អី គ្រួយឯណាណោះ ។

ដានី ៈ ចុះស្រុកខ្សាច់កណ្ដាល?

អាន ៈ អត់ដឹងទេ ។ ខ្ញីណាស់ អត់បានរៀបរយអី អត់បានចាំស្អីទេ ។ ដកព្រួយទៅ កំពត ។

ដានី ៈ ចុះក្នុងចំណោម៨នាក់ មានឈ្មោះ ជា ប្រាក់ ស៊ាន ?

អាន ៈ អាណឹង គេនៅហ្នឹង ។

ដានី ៈ ដកតែអ៊ីទៅម្នាក់ទេ?

អាន ៈ បាទ, ដកតែខ្ញុំ ។

ដានី ៈ មូលហេតុអីបានគេដកអ៊ីទៅកំពត?

អាន ៖ អត់មានមូលហេតុអីទេ។ គេយកទៅរៀបរយក្នុងគណៈកម្មការនោះ មាន កង ចាប មាន រឿន។ ពុថា ពីមុនមោ ក្នុងគណៈកម្មការហ្នឹង មាន រិន។ ដល់អីចឹង គេដក រិន អីទេ គេយកខ្ញុំទៅបញ្ចូល។

ដានី ៖ រិន មួយណា? ហេង រិន?

អាន ៖ រិន មាន២ ខ្ញុំពិបាកតាមឈ្មោះ។ មួយគេហៅ រិន ការ៉េ មួយ រិន ង៉ែវ អាម៉េចអាម៉ា ពិបាកហៅ។

ដានី ៖ ខ្ញុំស្គាល់ឈ្មោះពីរបីដែរ តែខ្ញុំអត់ស្គាល់មុខគាត់ ហើយនឹងតួនាទីរបស់គាត់។

អាន ៖ ហើយ រិន ដែលគេដកហ្នឹង រិន ង៉ែវ។ ដល់អីចឹងខ្ញុំពិបាកជម្រាបជូនណា។

ដានី ៖ ចុះអ៊ី ពេលដែលគេផ្លាស់អ៊ីពីកណ្តាលទៅកំពត កាលណោះពីណាគេអ្នកផ្លាស់ អ៊ីទៅ?

អាន ៖ តា ម៉ុក ហៅទៅ។

ដានី ៖ តា ម៉ុក ហៅទៅ?

អាន ៖ បាទ។

ដានី ៖ មិនមែន សុន សេន ទេ?

អាន ៖ មិនមែនទេ។ គេត្រូវគ្នាយ៉ាងណាលើ ដូច្នេះ អ្នកដកខ្ញុំទៅគឺ តា ម៉ុក។

ដានី ៖ អីចឹង ពេលដកទៅកំពតហ្នឹង អ៊ីទៅនៅជាមួយ កង ចាប?

អាន ៖ កង ចាប។

ដានី ៖ អ៊ី ហើយពីណាទៀត?

អាន ៖ កង ចាប ហើយ រឿន។ រឿន ជាអនុប្រធាន។

ដានី ៖ រឿន, ០៥ ហ្នឹង?

អាន ៖ មិនមែនទេ។

ដានី ៖ រឿន ណា?

អាន ៖ មិនដឹងទេ, ស្គាល់តែរឿន អីចឹង។

ដានី ៖ ស្គាល់តែ រឿន។ ហើយ កង ចាប គាត់ធ្វើប្រធាន?

អាន ៖ បាទ, រឿន អនុ។

ដានី ៖ ហើយ ចុះអ៊ី?

អាន ៖ ខ្ញុំ សមាជិក។

ដានី ៖ អីចឹង កាលអ៊ីទៅកំពត អ៊ីទៅទទួលតំបន់ដដែល?

អាន ៖ បាទ។

ដានី ៖ តំបន់ ៣៥?

អាន ៖ ៣៥ ។ អាណឹងបានមានការងារ ។

ដានី ៖ សំ ប៊ិតធ្វើអីទៅ?

អាន ៖ តា ប៊ិត, មើៗ ភ្លេច តា ប៊ិត (អាន សើច) ។ អត់ទេ តា ប៊ិត គាត់នៅនេះតើ ។

ដានី ៖ កងទ័ព?

អាន ៖ គាត់នៅខាងតាកែវ ១៣, អត់មាននៅខាងណុងទេ ថាភ្លេចតា ប៊ិត អីអត់ទេ ។

ដានី ៖ អត់ទេ?

អាន ៖ អត់ទេ, អត់មានរួមនៅខាង ៣៥ ទេ ។

ដានី ៖ អីចឹងអ៊ំអាចរៀបរាប់ពេលអ៊ំទៅដល់កំពត តំបន់ ៣៥ ជាមួយ កង ចាប?

អាន ៖ អាណឹងខ្ញុំទទួលមួយផ្នែក ខាងស្រុកឈូក ហើយស្រុកកោះស្លា និងស្រុកស្រែក្នុង ។

ដានី ៖ អីចឹង អ៊ំទៅកំពត, តំបន់ ៣៥ គឺទទួលស្រុកឈូក ស្រុកកោះស្លា និងស្រុកស្រែក្នុង?

អាន ៖ បាទ ។

ដានី ៖ ស្រុកស្រែក្នុង នៅជុំគិរី ហ្នឹងអ៊ំ?

អាន ៖ បាទ ។ ខ្ញុំនៅម៉ាជួរហ្នឹង ។

ដានី ៖ ចុះ កង ចាប គាត់ទទួលខាងអី?

អាន ៖ កង ចាប គាត់លេខា ។

ដានី ៖ គាត់លេខាតំបន់ ៣៥?

អាន ៖ បាទ, គាត់ប្រធាន ។

ដានី ៖ ចុះ រឿន?

អាន ៖ រឿន អនុប្រធាន ។ គេខាងយោធា ។

ដានី ៖ ចុះ រិន មួយទៀត?

អាន ៖ រិន គេដក ។

ដានី ៖ គេដកចេញ?

អាន ៖ ដក, យកខ្ញុំទៅដាក់ ។

ដានី ៖ រិន គេដកយកទៅណាទៅ?

អាន ៖ គេដកមកខាងភាគ, ការងារខាង តា ម៉ុក, ជាមួយ តា ម៉ុក ។ តែមិនដឹងគេធ្វើអីទេ ។

ដានី ៖ អ៊ំអត់ដឹងត្រកូលគាត់ទេឬ?

អាន ៖ អត់ទេ ។

ដានី ៖ មិនមែនឈ្មោះ ហេង រិន ទេឬ?

អាន ៖ អត់ដឹង ៗ តែគេហៅ រិន ង៉ើវ ៗ ។

ដានី ៖ ឈ្មោះ រិន ង៉ើវ?

អាន ៖ បាទ ៗ

ដានី ៖ គេដកគាត់មកភាគ គេដកអ៊ីមោ?

អាន ៖ យកទៅដាក់ជំនួស ។

ដានី ៖ តែជាសមាជិកតំបន់ ៣៥ តែអ៊ីមានតួនាទីជាលេខា ៣ស្រុក?

អាន ៖ មោទទួលស្រុកស្រែក្នុង ស្រុកឈូក ហើយនឹងស្រុកកោះស្លា, ហ្នឹងមួយចំណែក ។ មួយចំណែកខ្ញុំគឺទទួលខាងផ្នែកសេដ្ឋកិច្ច, សេដ្ឋកិច្ចហ្នឹងមិនមានអីទេ មានតែការធ្វើស្រែ ធ្វើទំនប់ធ្វើប្រឡាយ ។

ដានី ៖ អ៊ីអាចរៀបរាប់ការងារអ៊ីទៅកំពត ហ្នឹងចាប់ផ្តើមធ្វើការមែនទែន?

អាន ៖ បាទ ៗ

ដានី ៖ អីចឹងអ៊ីអាចរៀបរាប់ពីការងាររបស់អ៊ីពេលហ្នឹងណាអ៊ី? ដូចថាការងារយើងត្រូវទទួលផែនការអីពីខាងមជ្ឈិម ពីខាងភ្នំពេញមោយ៉ាងម៉េចខ្លះ យើងត្រូវធ្វើការ រៀបចំប្រជាជនយើងដឹកនាំ យើងដាក់ផែនការអីយ៉ាងម៉េច?

អាន ៖ ក្នុងពេលនោះគឺកំណត់គោលការណ៍ មានកិច្ចការពារប្រទេស និងការកសាងប្រទេស ។ ការពារ និងកសាង ។

ដារ៉ា ៖ ចុះការពារសំដៅលើកិច្ចការអីខ្លះទៅ?

អាន ៖ ការពារប្រទេស តាមព្រំដែន, យួន ។ អាណឹងហើយហៅការពារ ។ ការពារ ហើយកសាង ។ ហ្នឹងគឺជាគោលការណ៍ ។ ដល់ទៅកសាងប្រទេសឈរលើមូលដ្ឋានអី គឺសេដ្ឋកិច្ច ។ អីចឹងពង្រឹងខាងសេដ្ឋកិច្ចគឺមានមធ្យោបាយទឹក ប្រព័ន្ធភ្លឺ មធ្យោបាយទឹក ។ ធ្វើសម្បើមណាស់ក្មួយ ។ ម៉ាផែៗ រឹង, ធ្វើណាស់ ។ ទៅកំពត ចាំមើលខ្ញុំរៀបរាប់, រួចទំនប់នៅ ជាគឺ នៅកំពត ទំនប់រំលេច, ខ្ញុំនេះឯង ។ ទំនប់កោះស្លា ខ្ញុំនេះឯង ។ នៅស្រុកទូកមាស ស្តុកឈូក, ខ្ញុំ ។ ទំនប់ក្បាលរមាស ដែសមុទ្រ, ខ្ញុំ ។ ទំនប់ព្រែកគន់ហន់ព្រំប្រទល់ជាប់នឹងព្រែកវិញទេ បន្ទាយព្រៃតាមែង ស្រុកយួន ។ គោលការណ៍ដោះស្រាយខាងមធ្យោបាយទឹក ។ ទន្ទឹមនេះគឺប្រពន្ធភ្លឺ, ភ្លឺទោល ភ្លឺភ្លោះ, ធ្វើនោះមហាសែនធ្វើ ។

ដារ៉ា ៖ ចុះមានការចូលពីប្រជាជនយ៉ាងម៉េចដែរ?

អាន : ប្រជាជនចូលរួម, ខ្ញុំធ្វើទំនប់រំលេច អាត្រាក់មានតែ២គ្រឿង, អាឈូសមួយ អាមួយជីកដីមិនដឹងគេហៅវាអាស្អីទេ គេហៅវា អាឱបពោះៗនោះ, ទំលាក់អាប៉ែលទៅបរីទៅ បោសដីចូល, មានតែ២គ្រឿងទេ ធ្វើទំនប់នោះៗ ហើយឥឡូវនេះ ទឹកនៅសម្បើម (អានសើចកក្អឹក) ។

ដានី : ដែលអឺថាទទួលផែនការដូចថាចាប់ពីឆ្នាំរំដោះទៅ យើងទទួលផែនការកសាង និងការពារប្រទេស ។ អីចឹងទទួលផែនការហ្នឹងយើងទៅទទួលផែនការពីណាមោ?

អាន : ភាគ ។

ដានី : ពីភាគ?

អាន : បាទ

ដានី : យ៉ាងម៉េច? អឺអាចរៀបរាប់ពីកន្លែងហ្នឹង អឺទៅប្រជុំ ដូចថា យើងទៅទទួលផែនការយ៉ាងម៉េច?

អាន : ឥឡូវ ជាគោលការណ៍គេកំណត់អីចឹង ។ គោលការណ៍ធំគឺ២ហ្នឹង ។ កិច្ចការពារប្រទេស គឺផ្នែកយោធា ។ ផ្នែកការកសាងប្រទេស គឺឈរលើមូលដ្ឋានសេដ្ឋកិច្ច ។ ដូច្នេះមូលដ្ឋានសេដ្ឋកិច្ចវាមានអី គឺប្រភពទឹក ប្រពន្ធ័ភ្លឺ, ជាគោលការណ៍គឺដោះស្រាយជីវភាពប្រជាជន, ឈរលើមូលដ្ឋាននៃការដោះស្រាយ ។ អាណឹងទទួល ។

ដានី : ចុះអឺយើងទៅទទួលផែនការ យើងទៅហ្នឹង យើងទៅប្រជុំនៅភូមិភាគឬ?

អាន : នៅតាកែវ, តា ម៉ុក ហ្នឹងណា ។ តា ម៉ុក ហ្នឹងគណៈភាគ, គណៈភាគហ្នឹង វាមាន តា ម៉ុក, មាន កង ចាប, រួចមាន តា ប៊ិត ។ យល់អត់?

ដានី : បាទ ។ មាន៣នាក់ហ្នឹងឬ គណៈភូមិភាគនិរតី?

អាន : មានឈ្មោះ សោម មួយទៀត ។

ដានី : សោម ដែលជាអនុកងពលកាលនៅជាមួយអឺ?

អាន : មិនមែនទេ ។ តែ សោម នោះមិនដឹងស្លាប់ហើយឬនៅទេ ។

ដានី : គណៈតំបន់ ១៣ ដែរ សោម នោះ?

អាន : ១៣, ជាគណៈតំបន់ ១៣ តែគាត់គណៈកម្មាធិការភាគ ។ ដូចជា កង ចាប អីចឹង ។ កង ចាប ជាអនុប្រធាន តា ម៉ុក នៃគណៈកម្មាធិការភូមិភាគ, គាត់ជាលេខាតំបន់ ៣៥ ជាមួយខ្ញុំ ដែលគេយកខ្ញុំទៅដាក់នោះ ។

ដារ៉ា : អីចឹង នៅក្នុងគណៈកម្មាធិការ មានគណៈកម្មាធិការហើយអនុប្រធានមួយៗហ្នឹងទទួលតំបន់មួយអីចឹងទៅ?

អាន ៖ បាទ, ហើយ សោម គាត់នៅក្នុងគណៈកម្មាធិការភាគ គាត់ជាលេខ ១៣ ។

ដានី ៖ តា ប៉ិត គាត់អត់ទេ?

អាន ៖ តា ប៉ិត គាត់អនុ ។

ដានី ៖ តែ តា ប៉ិត គាត់ទទួលលេខាតំបន់?

អាន ៖ យោធា ។

ដានី ៖ អម្បាញ់អ៊ីរៀបរាប់ពីខាងកសាង ខាងការពារ យោធាជាអ្នកការពារ, តែខាងកសាងគឺខាងជនបទ..

អាន ៖ មូលដ្ឋាន

ដានី ៖ អ៊ីអាចមានប្រសាសន៍ថា ពេលដែលភូមិភាគដាក់យ៉ាំងម៉េច? យើងត្រូវកសាងអ៊ីខ្លះ ហើយប្រជាជនចូលរួមយ៉ាំងម៉េចខ្លះ?

អាន ៖ បាទ, គេឲ្យមានប្រជាជនចូលរួមហ្នឹងឯង, តែប្រជាជនចូលរួមពេលនោះក្នុងស្រុកនីមួយៗ តំបន់នីមួយៗគេរៀបចំ សូម្បីតែនៅក្នុងខេត្តក៏គេមានកងចល័តរបស់ខេត្តដែរ ។ ភាគក៏គេមានកងចល័តរបស់ភាគ ។ ស្រុកគេមានកងចល័តរបស់ស្រុក ។ កងចល័តនេះគឺសុទ្ធតែយុវជន យុវនារី, អ្នកដែលលីវៗ ។ ហើយដល់ធ្វើហ្នឹង ដូចជានៅក្នុងក្របខណ្ឌស្រុកមួយជួនកាល អ៊ីចឹងទៅគេមើលភូមិសាស្ត្រដែលត្រូវដោះស្រាយទៅធ្វើអីណឹង វាទំហំ គិតគូរមនុស្ស គិតគូរខាងមធ្យោបាយ គ្រឿងចក្រ មនុស្សរួមផ្សំអ៊ីចឹងទៅ គេត្រូវការអ៊ីចឹងចំនួនជាមនុស្សអី គេត្រូវការប៉ុន្មានប្រមាណមនុស្សអ៊ីចឹងទៅ អាណឹងគេស្នើទៅតាមស្រុកមួយៗអ៊ីចឹងមោ ដើម្បីយកកម្លាំងជំនួយ អាណឹងគេធ្វើអ៊ីចឹង ។

ដានី ៖ ចុះផែនការ ដូចអ៊ីមានប្រសាសន៍អម្បាញ់មិញលើកទំនប់ ដូចថាទំនប់មួយៗយើងត្រូវគិតគូរយ៉ាំងម៉េច ត្រូវការកម្លាំងមនុស្សប៉ុន្មាន មនុស្សត្រូវចែកយ៉ាំងម៉េច ត្រូវលើប៉ុន្មានម៉ែត្រគូបអ៊ីក្នុងមួយថ្ងៃ ហើយហូបចុកយ៉ាំងម៉េច អាណឹងគេ?

អាន ៖ គេចែកមុខសញ្ញា មុខព្រួញ ។

ដានី ៖ អ៊ីមានចាំទេ គេចែកយ៉ាំងម៉េចទៅ, អ៊ីមានប្រសាសន៍អ៊ីគ្រប់គ្រងទំនប់នោះ?

អាន ៖ ចែកផ្នែកកម្លាំង ឧទាហរណ៍ថា ទំនប់មានបណ្ដោយប៉ុណ្ណា ហើយអាចប្រើកម្ពស់ប៉ុណ្ណាដល់អ៊ីចឹងមួយអាគ្រឿងចក្រនេះជួយបានគីឡូតប៉ុណ្ណា ។ អ៊ីចឹងទៅគេចែកជាមុខសញ្ញាវាស់ម៉ែត្រចែកអ៊ីចឹងទៅ, ចែកតាមកម្លាំង ឧទាហរណ៍ថា មួយស្រុកទទួលប៉ុន្មានរយម៉ែត្រកម្លាំងប៉ុណ្ណា អាណឹងនិយាយពីកម្លាំងគេចែកអ៊ីចឹងហើយ ។ និយាយពីការផ្គត់ផ្គង់, ការផ្គត់ផ្គង់គឺដោះស្រាយតាមស្រុកនីមួយៗ ។ តាមស្រុកនីមួយៗគឺដោះស្រាយផ្គត់ផ្គង់ជីវភាព

ជាអង្គរ ជាបន្លែ ជាម្ហូបដោះស្រាយ ។ នៅខាងកំពតអត់ចោទទេ ។ បានថា ម្ហូបមិនចោទ ព្រោះដោយសារសមុទ្រ ។

ដានី : ដូចថា ខាងគណៈអចិន្ត្រៃយ៍ មជ្ឈិមភ្នំពេញចុះទៅកន្លែង ចុះទៅមើល ណែនាំទៅតាមទំនប់ តាមការដ្ឋានមួយៗ ?

អាន : គណៈអចិន្ត្រៃយ៍មជ្ឈិមគឺ តា ម៉ុក ហ្នឹងនហើយ ។ ម៉ាផ្នែកខាងហ្នឹងគឺ តា ម៉ុក ។

ដារ៉ា : អត់មានខាងគណៈមជ្ឈិមផ្សេងទៀត អ្នកផ្សេងទៀតដែលចុះមកមើល?

អាន : ទៅខាងណោះ ឃើញតែ តា ម៉ុក ។

ដារ៉ា : អឺ, ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់កន្លែងនេះ កន្លែងដែលអឺបែងចែកការងារនៅកន្លែងការដ្ឋាន ទាំងអស់ហ្នឹងគឺសុទ្ធតែចេញមកពីប្រធានតំបន់កន្លែងហ្នឹងផ្ទាល់ជាអ្នកបែងចែក រួចហើយដាក់ចុះមកខាងក្រោមអីចឹងឬ?

អាន : ខាងលើគេគ្រាន់តែថា ទឹកសំខាន់ធំ យើងខាងក្រោមទេ ធ្វើសេចក្ដីរាយការណ៍តែប៉ុណ្ណឹង ។ ឧទាហរណ៍ថា ទំនប់យើងប្រុងធ្វើមធ្យោបាយទឹកហ្នឹង យើងប្រុងធ្វើម្ដុំណាអីចឹងណា អាណឹងយើងពិគ្រោះជាមួយនឹងភូមិ ជាមួយនឹងឃុំអីចឹងទៅ ស្រុកអីចឹងទៅ ឧទាហរណ៍ថា ស្រុកស្រែក្នុងយើងធ្វើម្ដុំណាអីម្ដុំណាអីចឹងទៅ យើងពិនិត្យទៅ យើងឯកភាពពីភូមិ ពីឃុំ ហើយស្រុកយើងឯកភាពគ្នាថាដោយស្រាយនៅម្ដុំហ្នឹងហើយ បានយើងចាប់ផ្ដើមវាស់វែងទៅ ។ យើងផ្ដើមរៀបចំការវាស់វែង ហើយគូរជាប្លង់ ។ គូរជាប្លង់ហើយ ដល់ពេលយើងឡើងទៅប្រជុំនៅតំបន់ បានយើងយកប្លង់នីមួយៗទៅឆ្លងនឹងគេនោះ, ទៅឆ្លង ។ បើគេពិនិត្យទៅត្រឹមត្រូវហើយអីហើយអាណឹងគេស៊ីញ៉េឲ្យយើង, យើងយកមករៀបចំខ្លួនយើង ។

ដានី : អីចឹង ប្លង់ដែលលើទំនប់អីណឹងគណៈ..

អាន : ភូមិ ឃុំ ស្រុក

ដានី : យើងគូរប្លង់ខ្លួនយើង?

អាន : បាទ ។

ដានី : គូរប្លងលហើយបានយកទៅឆ្លង?

អាន : ទៅឆ្លង ។

ដានី : ឆ្លងត្រឹមតំបន់?

អាន : តំបន់

ដានី : អត់មានចាំបាច់ឆ្លងដល់ភូមិភាគទេ?

អាន ៖ តំបន់, បើកន្លែងរបស់តំបន់ បើគេគិតកន្លែងមួយអាណឹងគេយកទៅឆ្លងភាគ ។

ដានី ៖ បានន័យថា ការដ្ឋានណាមួយដែលគេចាត់ទុកជារបស់តំបន់បានគេយកទៅឆ្លងភាគ?

អាន ៖ ឆ្លងភាគ ។

ដានី ៖ បើសិនរបស់ឃុំស្រុកអី ឆ្លងត្រឹមតំបន់ទេ?

អាន ៖ ឆ្លងត្រឹមតំបន់ ។

ដានី ៖ អីចឹងការដ្ឋានណាខ្លះដែលគេចាត់ទុកថា ជារបស់ស្រុក តំបន់?

អាន ៖ នៅខាងកំពត មានតែត្រើយកោះមួយទេ ដែលគេចាត់ទុកជារបស់តំបន់ ។ អាណោះគេដោះស្រាយអំបិល ដៃសមុទ្រ ។

ដានី ៖ ក្រៅពីណោះសុទ្ធតែរបស់ស្រុកទេ?

អាន ៖ បាទ, ត្រង់នោះវាទាក់ទងស្រែអំបិល, ខេត្តកំពតនោះវាឆ្លងទៅអត់រួច អានោះវាកន្លែងស្រែអំបិល ដល់អីចឹងគេធ្វើទំនប់មួយ ត្រើយកោះ គេយកអាដីកោះនេះធ្វើស្រែអំបិល ។ អីចឹងគេធ្វើតែមួយនឹងទេ ។

ដានី ៖ចុះអ៊ី កាលណោះរបៀបយើងបែងចែកប្រជាជនយ៉ាងម៉េចទៅ បើកាលណោះមានប្រជាជនជម្លៀស និងប្រជាជនមូលដ្ឋាន? យើងបែងចែករបៀបធ្វើការងាររអីយ៉ាងម៉េចទៅ?

អាន ៖ ដូចតែគ្នា, អត់មានបែងចែកទេ គ្រាន់តែវាឈ្មោះហ្នឹងប្រជាជន១៧អីទៅ តែការងារដូចតែគ្នា ។ ធ្វើដូចតែគ្នា មូលដ្ឋានក៏ធ្វើ ប្រជាជនជម្លៀសទៅក៏ធ្វើ គឺធ្វើជាទូទៅ ។

ដានី ៖ ប៉ុន្តែមួយទៀត ដូចថាយើងដាក់ប្រជាជន ១៧ មេសា មោធ្មី ដូចថា បក្សអត់សូវទុកចិត្តយើងត្រូវមានវិធានការអីដើម្បីទប់?

អាន ៖ ត្រង់នេះពិបាកនិយាយណាស់ក្មួយ ព្រោះគ្មានបក្សណាមិនទុកចិត្តទេ វាគ្រាន់តែកំណត់ថាមិនថា១៧ មិនថាមូលដ្ឋានទេ គេកំណត់គោលការណ៍លើសកម្មភាព ។ ជនណាដែលមានសកម្មភាពប្រឆាំង ជនណាដែលមិនមានសកម្មភាពប្រឆាំង, គេកំណត់តែប៉ុណ្ណឹងទេ ។

ដានី ៖ គោលការណ៍សកម្មភាពកំណត់ចេញពីណាមោ?

អាន ៖ ឧទាហរណ៍ថា ឈ្មោះ ក ហ្នឹងធ្វើសកម្មភាពប្រឆាំងជាន័យនយោបាយក្តី ជាន័យចាត់តាំងក្តី អាណឹងឈ្មោះថា អ្នកធ្វើសកម្មភាពប្រឆាំង ។ អាណឹងមានន័យ១ថា មិនថា១៧ ឬមិន១៧ទេ, គេកំណត់ច្បាស់ ។

ដានី ៖ គេកំណត់ហ្នឹងមានជាឯកសារ ជាសៀវភៅ ឬពេលសន្និបាត?

អាន ៖ ពេលសន្និបាត ដកពិសោធន៍ សន្និបាតរបស់តំបន់គេលើកច្បាស់, ចុះ១៧ បើគ្នាមិនមានសកម្មភាពប្រឆាំងអី រួចកំណត់ថាយ៉ាងម៉េច? រួចយកគ្នាទៅធ្វើអាម៉េច, អាណឹងវា

អីចឹង ។ ចុះឧទាហរណ៍ថា ប្រជាជននៅមូលដ្ឋានហ្នឹងទេ ក៏ប៉ុន្តែមានការទាក់ទងអីណាអីនៃមកធ្វើសកម្មភាពប្រឆាំង អត់យកទោសឬ?

ដានី ៖ ដូចថា កាលណោះ យើងរបបការងាររមួយថ្ងៃដូចជាការងារលើកទំនប់អីក្នុងម្នាក់យើងអាចបែងចែកឲ្យលើប៉ុន្មាន? ហូបចុកអីយ៉ាងម៉េច? កាលណឹងយ៉ាងម៉េចដែរអ៊ី?

អាន ៖ ការលើកយើងកំណត់ពេល, ឧទាហរណ៍ថា ពេលព្រឹកយើងធ្វើទៅ ម៉ោង ១០, ១១ អីយើងសំរាកទៅ, សំរាកហូបចុកទៅ ។ រួចដល់ពេលល្ងាចម៉ោង២ យើងចុះធ្វើការទៅដល់ម៉ោង៥ល្ងាច យើងឈប់ទៅ, វាមានពេលអីចឹង ។ រីឯការហូបចុកគឺមួយថ្ងៃ៣ពេល ។

ដានី ៖ ហូបយើង២ពេល?

អាន ៖ បី ។

ដានី ៖ អីចឹងមានពេលព្រឹក ពេលថ្ងៃត្រង់ និងពេលល្ងាច?

អាន ៖ បាទ ។

ដានី ៖ អីចឹង ហូបអីទៅ?

អាន ៖ បាយព្រឹក ថ្ងៃ ល្ងាច, អានេះខ្ញុំនិយាយដោយឡែកនៅកំពតទេណា ។ ព្រោះកំពតអត់ចោទបញ្ហាទេ កាលខ្ញុំរស់នៅ ។

ដានី ៖ ប៉ុន្តែកាលណឹងដូចថាយើងមានរបបហូបមួយចាន ឬហូប?

អាន ៖ ហូបមាំឆ្អែតហ្នឹង, មិនមែនមួយចានឯណា ។

ដានី ៖ ដូចជាការងារយើងកំណត់ថា ក្នុងម្នាក់លើប៉ុន្មានម៉ែត្រគូប១ គេមានកំណត់អីចឹងដែរឬអត់?

អាន ៖ អាណឹងជារួម គេវាស់ម៉ែត្រ ។ ឧទាហរណ៍ថា ទំនប់អីចឹងគេដាក់មុខសញ្ញា ឧទាហរណ៍ថាឃុំនេះចំនួនប៉ុននេះម៉ែត្រ កំពស់ប៉ុននេះ, ឃុំនោះប៉ុននេះម៉ែក្រ កំពស់គេដាក់ប៉ុណ្ណោះ, ជារួមអត់មានបុគ្គលណាទេ, ទៅជារួមតែម្តង ។ ទៅបុគ្គលទៅលេងម៉ែត្រគូបណាទៅរួច, អត់រួចទេ ។

ដានី ៖ អឺមានប្រសាសន៍ថា បុគ្គលយ៉ាងម៉េច?

អាន ៖ ឧទាហរណ៍ថា ម្នាក់ហ្នឹង១០០ម៉ែត្រគូប (អាន សើច) អាណឹងវាអីចឹងណា ។ ដូច្នេះអត់ទេ បើធ្វើការដ្ឋាន វាជារួមរបស់ឃុំ មុខសញ្ញារបស់ឃុំ ។

ដានី ៖ ចុះអឺកាលណោះនៅភូមិភាគនិរតីមានប៉ុន្មានតំបន់, តំបន់ ២៥, ១៣, ៣៥?

អាន ៖ ភូមិភាគនិរតី មាន កំពត តាកែវ កំពង់ស្ពឺ ។

ដារ៉ា ៖ មិនមែនទាំងអស់ទេឬ?

ដានី ៖ ក្រែងកំពង់ស្ពឺមួយចំនួននៅក្នុងភូមិបស្ទឹម?

អាន ៖ បស្ទឹម, កពង់ឆ្នាំង ។

ដានី ៖ កាលណោះច្បារមនអី នៅភូមិភាគបស្ទឹមតើ?

អាន ៖ អត់ដឹងច្បាស់ទេ ។

ដានី ៖ ប៉ុន្តែតំបន់មានជាលេខ ដូចថា កំពត, តំបន់ ៣៥ ហើយតំបន់ខេត្តកណ្តាលនេះ គឺតំបន់ ២៥, តំបន់តាកែវ តំបន់ ១៣, ចុះមានតំបន់មួយទៀត តំបន់អីគេ?

អាន ៖ ឯណា?

ដានី ៖ កំពង់ស្ពឺដែលអ៊ំថាអម្បាញ់មិញនោះ ។

អាន ៖ ៣២

ដានី ៖ ៣២ ឬ ៣៣ អ៊ំ?

អាន ៖ ៣២

ដានី ៖ កាលណោះឈ្មោះអីគេទៅ គណៈតំបន់?

អាន ៖ តំបន់ ៣២ ហ៎, មិនដឹងឈ្មោះអីទេ ។

ដានី ៖ អ៊ំទទួលគ្រប់គ្រងនៅខាងកំពត, ខាងតំបន់ ៣៥ ដល់ឆ្នាំណាទៅអ៊ំ?

អាន ៖ ខ្ញុំថាមើល រិតតែបន្តុបអីចឹង, ទទួលនៅកំពត ៧៦, ៧៧ កំពង់ចាម ។

ដានី ៖ ៧៧ មកកំពង់ចាមវិញ?

អាន ៖ បាទ ។

ដានី ៖ អ៊ំមានចាំថ្ងៃខែអីដែលយើងផ្លាស់ចេញពីកំពត មកកំពង់ចាមដែរទេ?

អាន ៖ សុទ្ធតែអត់ ។

ដានី ៖ ៧៧ អ៊ំចាំខែទេ ខែណាទៅ?

អាន ៖ អត់ទេ ។

ដានី ៖ ដូចជាខែប្រាំង ឬនៅក្នុងខែវស្សាក្នុងឆ្នាំ៧៧ ដែលអ៊ំផ្លាស់ទៅកំពង់ចាម?

អាន ៖ មិនដឹងខែណាទេ ។

ដានី ៖ អ៊ំរកគិតមើល ពេលដែលអ៊ំផ្លាស់ទៅនឹងពេលដែលមានភ្លៀង ឬខែប្រាំង?

អាន ៖ ៧៧ ... អត់ចាំទេ ។

ដារ៉ា ៖ ឥឡូវអ៊ំត្រូវផ្លាស់ទៅកំពង់ចាមវិញ ។ មានមូលហេតុបានត្រូវផ្លាស់ទៅកំពង់ចាមវិញអ៊ំ?

អាន ៖ ហ៊ឺ, ពិបាកនិយាយណាស់អាណឹង ។

ដារ៉ា ៖ ជាផែនការបុយ៉ាងម៉េច?

អាន ៖ ហ្នឹងក៏នៅលើ តា ម៉ុក ។

ដារ៉ា ៖ ដោយសារខាងកំពង់ចាមមានបាតុភាពយ៉ាងម៉េចបានគេដកអីទៅ?

អាន ៖ គេថា កំពង់ចាមហ្នឹងក្បត់, ថ្នាក់ដឹកនាំកំពង់ចាមហ្នឹងក្បត់អស់ហើយ បានយកខ្ញុំទៅ ។

ដានី ៖ កាលណោះពីណាអ្នកនិយាយ?

អាន ៖ តា ម៉ុក ហ្នឹងហើយ ។

ដានី ៖ ដែលថាមានក្បត់មានអីហ្នឹង កាលហ្នឹងអ្នកណាជាអ្នកគ្រប់គ្រងជាលេខាតំបន់ឬក៏ភូមិភាគអី?

អាន ៖ ស្គាល់វាមិនអស់ផង ។

ដានី ៖ អ៊ឺ, កាលហ្នឹងកំពង់ចាម គេហៅភូមិភាគអីគេ?

អាន ៖ ភូមិភាគឧត្តរ ។

ដានី ៖ កាលហ្នុងភូមិភាគឧត្តរកំពង់ចាម?

អាន ៖ បាទ!

ដានី ៖ ចុះលេខាភូមិភាគឧត្តរពីណាគេ?

អាន ៖ ឧត្តរហ្នុងវាមានសៀមរាប តាំងពីព្រះវិហារណុះ សៀមរាបឧត្តរមានជ័យណា កំពង់ធំ កំពង់ចាមហ្នឹងហៅភូមិភាគឧត្តរ បាទខ្ញុំណោះទៅដឹងអី ទៅដល់ គេយកទៅគេថាអស់ហើយ ក្បត់អស់ហើយ ក៏យកខ្ញុំទៅ យកទៅវាអស់មែន វាមានសិទ្ធិអី គេរៀបទៅតាំងកំភ្លៅៗ ទៅតាម៉ុក ដល់ស្រុកគេយកទៅដាក់ ដូចនេះអីណា ហ្នឹងគេយកទៅដាក់នៅបារាយ ។

ដារ៉ា ៖ តាប៉ូចនេះឬ?

អាន ៖ បាទ! ពុកគាត់ថាម៉េច?

ដានី ៖ បាទ! គាត់ទៅស្រុកពី បី ណុះ មុនដំបូងគាត់ទៅ ស្រុកបារាយផង ស្រុកអីទេដំបូង គាត់ផ្លាស់ពី បីស្រុក ។

ដារ៉ា ៖ អីចឹងអ៊ីពេលដែលអ៊ីទៅដល់កំពង់ចាមហ្នឹង គណៈគ្រប់គ្រងគេនៅហ្នុងត្រូវបានចាប់យកទៅអស់ហើយ?

អាន ៖ អស់អាលីញអាលាត់ហើយ នៅតែ កែ ពកមួយទេ ។

ដារ៉ា ៖ អីចឹងពេលអ៊ីទៅដល់ហ្នុងត្រូវឡូ កាន់...

អាន ៖ កែ ពក ហ្នឹងអ្នកគ្រប់គ្រង បាទ!ឃើញតែ កែ ពក ទេថ្នាក់ភាគនោះណា ដូច្នេះខ្ញុំអត់ស្គាល់ទេ អត់ស្គាល់ថាពីណាថាថ្នាក់អីៗនោះអត់ដឹងទេ ព្រោះអត់មានទេ ។

ដានី ៖ ចុះពីដំបូងឋានៈដូចថាលេខាភូមិភាគឧត្តរម៉ងពីណាគេ?

អាន ៖ មិនដឹងជា ស្រេង មិនដឹងជាស្អី ឮតែគេនិយាយ ស្រេង ផងនិយាយពីស្អីអត់ដឹងទេ ដឹងតែ តំបន់ ៤១ ហ្នឹងគេនិយាយថា តាំង រួចវាមិនដែលឃើញមុខ តាំង មុខស្អីឯណា បើវាអត់មានអាលីញអាលាត់បាទ!

ដានី ៖ កាលអ៊ីទៅហ្នុង តាំង លេខាតំបន់៤១ហ្នុង អត់ឃើញទេ?

អាន ៖ គេដកបាត់អស់រលីញរលាត់ហើយ ។

ដារ៉ា ៖ ចុះពេលអ៊ីដកទៅកាន់ខាងកំពង់ចាមហ្នុង អ៊ីកាន់ខាងតំបន់អីវិញ?

អាន ៖ ៤១ ។

ដារ៉ា ៖ កាន់តំបន់ ៤១ គឺជំនួស តាំង ហ្នឹងឯង!

អាន ៖ បាទ! ជំនួសស្អីគេ តាំង ។ តាំង ហ្នុងគេដកបាត់ហើយ ។

ដានី ៖ ប៉ុន្តែអ៊ីកាលហ្នុង អ៊ីមានតួនាទីជាគណៈភូមិភាគដែរ?

អាន ៖ ទៅដល់ហ្នឹងបានគេប្រាប់ ទៅហ្នឹងមាន ស៊ុម មាន ជឹម មានខ្ញុំ មាន កេត ។ ស៊ុម នេះជាក្មួយរបស់តាម៉ុក ក្មួយប្រសារ ដូច្នេះគេរៀបរយគណៈកម្មាធិការហ្នឹង គេមានចំហរ និងមានសម្ងាត់ រួចខ្ញុំនេះចំហរ ចម្ងាត់ផ្ទៃក្នុងហ្នុងគឺ ស៊ុម ។ អ៊ុំ ស៊ុម នៅក្នុងតំបន់៤១ហ្នឹង

ដានី ៖ គាត់ឈ្មោះ អ៊ុំ ស៊ុម?

អាន ៖ បាទ!

ដានី ៖ កាលហ្នុងគេហៅភូមិភាគអីទៅ ភូមិភាគឧត្តរ ឬក៏ភូមិភាគកណ្តាល?

អាន ៖ ផ្លូវដល់រៀបរយហ្នុងគេដាក់ថាភូមិភាគកណ្តាល គេកាត់ចេញពីឧត្តរហើយ ។

ដានី ៖ អីចឹងអ៊ី! អ៊ីអាចរៀបរាប់មួយសារទៀត ដូចថាភូមិភាគកណ្តាលហ្នឹងគណៈកម្មាធិការចំហរមានពីណាខ្លះទៅ ឈ្មោះអីខ្លះ គណៈកម្មាធិការដែរចំហរ?

អាន ៖ ភូមិភាគកណ្តាលហ្នឹង មាន កែ ពក លេខា រួចមានកាលណុះខាងកំពង់ធំហ្នឹង ឈ្មោះ ចន លេខាខាងកំពង់ធំ រួចបានមក ស៊ុម មកខ្ញុំ មកជឹម មកកេត ។

ដានី ៖ បាទ! អ៊ីអីចឹង ឈ្មោះ ចន លេខាខាងស្អីគេ?

អាន ៖ ខាងកំពង់ធំ ។

ដានី ៖ លេខាខាងតំបន់ប៉ុន្មានខាងកំពង់ធំហ្នុង?

អាន ៖ កំពង់ធំ៤៣ ។

ដានី ៖ តំបន់៤៣ ឈ្មោះ ចន!

អាន ៖ បាទ!

ដានី ៖ ចុះឈ្មោះ ស៊ីម?

អាន ៖ ស៊ីម នៅជាមួយខ្ញុំហ្នឹង ៤១ ។

ដានី ៖ អីចឹង ស៊ីម នៅជាមួយអ៊ំទេ?

អាន ៖ បាទ!

ដានី ៖ ៤១ នៅកន្លែងណាទៅ?

អាន ៖ នៅព្រៃទទឹង ។

ដានី ៖ ព្រៃទទឹង ព្រៃឈរណាអ៊ំ?

អាន ៖ បាទ! ស្រុកព្រៃឈរ ។

ដានី ៖ អីចឹងអ៊ំជាលេខា ៤១ ហើយ ស៊ីម គាត់ជាស្អីវិញ?

អាន ៖ ជាផ្ទៃក្នុង ។

ដានី ៖ ផ្ទៃក្នុងយ៉ាងម៉េចអាហ្នឹង?

អាន ៖ គេហៅផ្ទៃក្នុងបក្ស ។

ដារ៉ា ៖ មានឋានៈជាលេខាដែរអាហ្នឹងអ៊ំ?

អាន ៖ លេខាបក្ស ស្មើរនឹងលេខា គេខាងការងារបក្ស ។

ដារ៉ា ៖ ហើអ៊ំខាងការងារ...

អាន ៖ ខ្ញុំការងារខាងរដ្ឋបាល ។

ដារ៉ា ៖ ជាការងារមហាជនអីចឹងណាអ៊ំ?

អាន ៖ បាទ!

ដារ៉ា ៖ អីចឹងរវាងការងាររដ្ឋបាល និងការងារបក្សហ្នឹងវាមានការខុសគ្នាយ៉ាងម៉េចទៅអ៊ំ?

អាន ៖ ខុសគ្នាយ៉ាងម៉េចទៅ!

ដារ៉ា ៖ ខុសគ្នាជាសិទ្ធិអំណាចក្នុងការសម្រេច នៅក្នុងការដាក់ផែនការយ៉ាងម៉េចទៅអ៊ំ?

អាន ៖ អត់ខុសគ្នាទេ! តែនេះខាងផ្ទៃក្នុងតែគេមិនសម្រេចរឿងអី យើងអត់សម្រេចបានទេ ។

ដារ៉ា ៖ អីចឹងបានខ្ញុំសួរអំពីការខុសគ្នាហ្នឹងណាអ៊ំ?

អាន ៖ បាទ! ខុសគ្នាសិទ្ធិណា ។

ដារ៉ា ៖ ខាងរដ្ឋបាល មួយខាងបក្សអីចឹង?

អាន ៖ បាទ!

ដារ៉ា ៖ សិទ្ធិនៅក្នុងការសម្រេចអីខុសគ្នាដែរអ៊ំ?

អាន ៖ ខុសត្រង់ថា បើគេអត់យល់ស្របរឿងការងារអី យើងអត់សម្រេចបានទេខាងរដ្ឋបាល ។

ដារ៉ា ៖ អ៊ីចឹងបើខាងបក្សអីសម្រេច ខាងរដ្ឋបាលអត់មានសិទ្ធិជំទាស់អីបានទេ?

អាន ៖ មានដែរ! អាចជំទាស់បានខ្លះ ប៉ុន្តែវាមិនដូចគេទេ អ៊ីដែលយើងអាចជំទាស់បានដូចជាការងារស្រាលៗណា យើងអាចជំទាស់បាន គេអាចអនុលោមតាមយើងបាន ។

ដារ៉ា ៖ ជាករណី ឧទាហរណ៍មួយមើលអឹអារឿងការងារស្រាលហ្នឹង?

អាន ៖ ឧទាហរណ៍ដូចជាការធ្វើការងារខាងសំណង់ទំនប់ទឹក ប្រព័ន្ធភ្លឺ ប្រឡាយអីនេះ អាហ្នឹងយើងអាចជំទាស់បាន ប៉ុន្តែជានយោបាយយើងអត់អាចជំទាស់គេបានទេ ។

ដានី ៖ ប៉ុន្តែជាទូទៅ កាលហ្នុងអឹជាលេខាតំបន់ ៤១?

អាន ៖ ៤១ ។

ដានី ៖ ស៊ីម ជាទូទៅគាត់ជាស្អីគេ?

អាន ៖ ផ្ទៃក្នុងបក្ស ហើយគេក្តោបស្តាប់ព្រៃឈរមួយទាំងមូលខ្លួនគេទៀត ។

ដានី ៖ ក្តាប់ស្រុកព្រៃឈរ?

អាន ៖ ស្រុកព្រៃឈមួយទាំងមូលទៀត ។

ដានី ៖ អ៊ីចឹងអឹក្នុងតំបន់៤១អឹជាលេខា ចុះខាងបន្ទាប់ៗពីអឹទៀតឈ្មោះអី?

អាន ៖ បន្ទាប់ពីខ្ញុំប្រចាំស្រុកឬ?

ដានី ៖ គណៈតំបន់ដែរ គណៈតំបន់៤១ មានអឹជាលេខាតំបន់ ដូចជាខាងបញ្ជាការ ខាងសេដ្ឋកិច្ចខាងអីណា?

អាន ៖ មានខ្ញុំ មាន ភឹម ។

ដានី ៖ ភឹម គាត់នៅឯណា?

អាន ៖ គាត់លេខា កាលនោះរៀបចំស្រុកមួយនៅស្រុកបាធាយ ក្បែរភ្នំបាធាយ មានស្រុកជើងព្រៃ ស្រុកបាធាយ អ៊ីចឹងគាត់ជាលេខាទទួលស្រុកបាធាយ អាហ្នឹងជាសមាជិករបស់តំបន់ ។

ដានី ៖ ជាសមាជិករបស់តំបន់?

អាន ៖ បាទ! នៅក្នុងហ្នឹងមាន ស៊ីម មានខ្ញុំ មានភឹម មានម៉ុន ។

ដានី ៖ ម៉ុន គាត់អ្នកស្រុកណា គាត់ទទួលស្រុកណា?

អាន ៖ ស្រុកជើងព្រៃ ។ កាន កងមាស ។

ដានី ៖ តែគាត់ក៏ជាសមាជិករបស់តំបន់ដែរ?

អាន ៖ បាទ! លេខាៗ ។

ដានី ៖ ចុះ ស៊ីម សព្វថ្ងៃគាត់នៅឯណាដែរ?

អាន ៖ ស្លាប់ហើយ ។

ដានី ៖ ចុះ ភីម?

អាន ៖ អត់ដឹងទេ ។

ដានី ៖ គាត់នៅរស់ទេឬ?

អាន ៖ អត់ដឹងទេ ។

ដានី ៖ ចុះឈ្មោះ ម៉ុន?

អាន ៖ ម៉ុន ស្លាប់ ។

ដានី ៖ ចុះឈ្មោះ កាន?

អាន ៖ កាន ក៏អត់ដឹង ព្ធថាស្លាប់ អត់ច្បាស់ទេ ។ បើ ម៉ុន ហ្នុងស្លាប់នៅ៧៩ ស្លាប់នៅព្រៃគប់ ស្រុកជើងព្រៃហ្នុង ព្រៃគប់មួយអាដូវទៅព្រែកក្ដាមហ្នុង កាត់ទៅនៅក្នុងព្រៃហ្នុងហើយ គេព័ទ្ធវ៉ៃសាប់នៅហ្នុងទៅ ។

ដានី ៖ ពីណាគេ ម៉ុន ហ្នឹង?

អាន ៖ បាទ! អាហ្នឹងស្រុកជើងព្រៃ ។

ដានី ៖ ស៊ីមគាត់អ្នកស្រុកនៅឯណាដែរ?

អាន ៖ ស៊ីម នៅកំពង់ឆ្នាំង ។

ដានី ៖ នៅភូមិអីអឹ?

អាន ៖ នៅចន្លាររៀល ។

ដានី ៖ ចុះភីម?

អាន ៖ កំពតក៏មិនដឹង តាកែវក៏មិនដឹងទេ កាលហ្នុងសុទ្ធតែកម្លាំងហ្នឹង ពេលដែលបញ្ជូនខ្ញុំទៅហ្នឹង សុទ្ធតែរៀបចំអីចឹងទៅ ។

ដានី ៖ ចុះម៉ុន គាត់នៅឯណា?

អាន ៖ សុត្ធតែរៀបចំពីតាកែវក៏មិនដឹង កំពតក៏មិនដឹង អត់ច្បាស់ទេ ។

ដារ៉ា ៖ អីចឹងចូលមកដល់អំពីការធ្វើការងារ ក្រោមការគ្រប់គ្រងរបស់អ៊ំនៅក្នុងតំបន់៤១នេះ តើការដ្ឋានការងារអីនៅកន្លែងណាខ្លះអី ធ្វើអីខ្លះទៅអ៊ំ?

អាន ៖ ក្មួយអើយ! ធ្វើការច្រើនណាស់ កាលទៅហ្នឹងគោលការសំខាន់គឺដោះស្រាយតែជីវភាព ប្រជាជនហ្នឹង ការពារ បើនិយាយពីទៅហ្នុងទៅទៀតសុទ្ធតែទំនប់ប្រឡាយហើយ ។

ដានី ៖ អ៊ំកាលហ្នុងទំនប់ប្រឡាយណាខ្លះទៅ ដូចជាទៅកសាង?

អាន ៖ ទំនប់ហ្នឹងសុទ្ធតែដាក់ឈ្មោះតាមនេះគេហ្នឹងណា ដូចជា ១មករា ៦មករា ខ្ទប១៧មេសា ពាមដាំង ភ្នំញោ សុទ្ធតែទទួលហើយ ។

ដានី ៖ កាលហ្នឹងអ៊ំ ១មករា អ៊ំទៅទទួលផែនការ អ៊ំនៅគ្រប់គ្រងនៅហ្នឹងដែរ?

អាន ៖ ខ្ញុំទៅធ្វើហ្នឹង ហ្នឹងគឺភាគ ។

ដានី ៖ របស់ភាគឬ?

អាន ៖ របស់ភាគ ប៉ុន្តែខ្ញុំទៅធ្វើនៅហ្នឹង ។

ដានី ៖ អ៊ំទៅទទួលខុសត្រូវ?

អាន ៖ ធ្វើតែទាំងអស់ហ្នឹង ១មករា ៦មករា ។

ដានី ៖ បានន័យថា អ៊ំទៅដឹកនាំកម្លាំងធ្វើទៅ...

អាន ៖ បាទ! គេយកតាមតំបន់ តំបន់៤១ តំបន់៤២ តំបន់៤៣អីចឹងទៅ គេយកតាមតំបន់ អីចឹងទៅកងចល័តនោះ កងចល័តរបស់តំបន់ណា ទទួលមុខសញ្ញាណាៗ អាហ្នឹងរបស់ភាគណាបាទ!

ដារ៉ា ៖ អីចឹងទំនប់ទាំងប៉ុន្មានដែលអ៊ំរៀបមក ដូចថា ១មករា ៦មករា ខ្ទប១៧ ទំនប់ ពាមដាំង ហ្នឹភ្នំញោ ហ្នឹងសុទ្ធតែអ៊ំបានដឹកនាំកម្លាំងក្នុងតំបន់៤១ ចូលទៅរួមទៅធ្វើការនៅហ្នឹងទាំងអស់?

អាន ៖ ធ្វើ!

ដារ៉ា ៖ មានប្រជាជនមានអីច្រើនទេអ៊ំ ចូលរួមក្នុងការលើកទំនប់ទាំងអស់ហ្នឹង?

អាន ៖ ចូលរួមធ្វើកងចល័ត ។

ដារ៉ា ៖ ការហូបចុក ហូបអីយ៉ាងម៉េចដែរពេលហ្នឹង?

អាន ៖ ហូបចុកអត់ចោតទេ វាហូប ជីវភាពវាខ្វះដាងនៅភូមិ ។

ដារ៉ា ៖ អ្នកដែលមកធ្វើការតាមការដ្ឋាន?

អាន ៖ បាទ! អ្នកដែលពលកម្ម ជីវភាពវាខ្វះដាង អត់មានកង្វះទេ ។

ដានី ៖ ចុះអ៊ំ ទំនប់ ១មករា ពីកន្លែងណា ទៅកន្លែងណាដែរ?

អាន ៖ ស្ទឹងជីនិត ។

ដានី ៖ ចាប់ពីស្រុកណា ទៅស្រុកណាទៅ?

អាន ៖ ស្ទឹងជីនិតហ្នឹង កំពង់ធំ ។

ដានី ៖ នៅកំពង់ធំហ្នឹង?

អាន ៖ បាទ!

ដានី : ប៉ុន្តែអ៊ំទៅគ្រប់គ្រងនៅហ្នុងដែរ?

អាន : ទៅនៅហ្នុងឯង ។

ដានី : ទំនប់ហ្នុង បើតាមអ៊ំចាំ....

អាន : បើកការដ្ឋានហើយ ទៅនៅនឹងការដ្ឋានហ្នុងទៅ បាទ! រួចដល់អាប្រឡាយហ្នុង អនាម័យស្អី អីចឹងទៅ អាម៉ែខ្ញូទៅកាយវែងជាចំអូរអីចឹងទៅធ្វើបគ្គន់មានបន្ទប់ៗនៅហ្នុងទៅ ។

ដានី : កម្លាំងច្រើនដែលទៅធ្វើ!

អាន : កម្លាំងរាប់ពាន់ណុះ!

ដានី : អ៊ំដូចថា ទំនប់១មករាហ្នុង ដូចថាគេចាប់ផ្ដើមកសាងតាំងពីឆ្នាំណាទៅ ហើយដល់ឆ្នាំណាទៅ បានចប់?

អាន : ទំនប់នេះ ដើមកំណើតវាខ្ញុំអត់ដឹងទេ ប៉ុន្តែដល់ពេលអាធ្វើហ្នឹងគឺឆ្នាំ៧៧ហ្នឹង ប៉ុន្តែមានគេធ្វើ កន្លងខ្លះមកហើយ ដល់ព្រឹត្តិការណ៍យ៉ាងនេះ យ៉ាងនោះទៅ បែបវាមេម៉ាយយ៉ាងណាក៏ ខ្ញុំមិនដឹងទេ ប៉ុន្តែដែលទៅធ្វើ ខ្ញុំទៅមានគេធ្វើខ្លះហើយ បាទ! គ្រាន់តែយកទៅធ្វើ ។

ដារ៉ា : នៅពេលដែលអ៊ំទៅដល់ហ្នុង ម៉ារយៈកាលដែលអ៊ំស្នាក់នៅទីហ្នុង អាចធ្វើទំនប់ទាំងអស់ហ្នុង ចប់សព្វគ្រប់ទេអ៊ំ កសាងហ្នុង?

អាន : អើ! ប៉ុនខ្ញុំអត់ចាំទេ ហើយឆ្នាំណាៗ ភ្លេចអស់ហើយ ។

ដារ៉ា : ប៉ុន្តែខ្ញុំគ្រាន់តែចង់សួរថា អ៊ំបានចូលរួមលើកចប់សព្វគ្រប់ទំនប់ហ្នុងទេ?

អាន : ចប់ៗ បាទ!

ដារ៉ា : ដល់ចប់បានឈប់ឬ?

អាន : បាទ!

ដារ៉ា : ចប់ហើយមានការដាក់សម្ពោធន៍ឲ្យប្រើប្រាស់ ឬក៏មានអី..

អាន : ចប់ហើយប្រើ អត់មានពិធីសំភីសម្ពោធន៍អីទេ ។

ដារ៉ា : ក្រែងលោមានខាងមជ្ឈិមគេចុះទៅ!

អាន : អត់ទេ! អត់មានសម្ពោធន៍មានអីទេ ។

ដារ៉ា : មានដប់លៀង មានអីទេអ៊ំ?

អាន : អត់ទេ!

ដានី : ចុះអ៊ំ មានពីខាងភ្នំពេញ ថ្នាក់ដឹកនាំភ្នំពេញអីចុះទៅទស្សនៈកិច្ចអី ចុះទៅមើល ទៅសួរសុខ ទុក្ខអីអ្នកលើកទំនប់អីដែរអត់?

អាន : កាលហ្នឹង ភាគច្រើនគេទៅតាមភាគ ។

ដានី ៖ តាមភាគមាន ដូចអ៊ីមានប្រសាទន៍មិញ ដូចកែ ពក អីហ្នឹងគាត់ចុះទៅ?

អាន ៖ បាទ! ដូចជា កែ ពក ហ្នឹងគេអ្នកគិតផ្ទាល់ហើយបាទ! ប៉ុន្តែបើនិយាយពីអ្នកខាងលើៗអី ខាងមជ្ឈិមអី ទល់តែឆ្លងទៅតាមរយៈ កែ ពក ។

ដានី ៖ ប៉ុន្តែ ពួកគាត់ធ្លាប់ចុះទៅដែរ?

អាន ៖ ទៅ!

ដានី ៖ កាលហ្នុងពីណាខ្លះដែលចុះទៅខាងទំនប់១មករា?

អាន ៖ ចុះទៅ ប៉ុល ពត អីហ្នឹង ។

ដានី ៖ ប៉ុល ពត គាត់ធ្លាប់ចុះទៅដល់ហ្នុងដែរ?

អាន ៖ ទៅ!

ដានី ៖ ទៅច្រើនដងទេ?

អាន ៖ ទេ! មិនដឹងប៉ុន្មានដងទេ ។

ដានី ៖ ទៅឆ្នាំណាអីចាំទេ?

អាន ៖ អូ! អត់ដឹងទេ ។

ដារ៉ា ៖ ទៅម្តងៗអីចឹង មានប្រមូលប្រធានតំបន់អី អនុប្រធានអីប្រជុំដែរអត់អឺ?

អាន ៖ អត់ទេ! គេទៅតាមរយៈភាគ កាលណាគេទៅដល់ គេមកវិញបាត់មក យើងមិនទៅដឹងអី ផង ។

ដានី ៖ គេអត់មានហៅអីទៅជួប ទៅរាយការណ៍ថាទំនប់នេះយើងត្រូវធ្វើយ៉ាងម៉េច!

អាន ៖ អត់ទេៗ!

ដានី ៖ ចុះក្រៅពីប៉ុល ពត មានអ្នកផ្សេងទៅទៀតដែរអត់?

អាន ៖ អត់ទេ! មិនដឹងពីណា អត់មានទេ មានតែភាគ ការងាររបស់ភាគ បច្ចេកទេសរបស់ភាគ ធ្វើដល់ពេលអាសម្រេចហើយក៏អីចឹងដែរ អត់មានសំភីសម្ពោធន៍ស្អីណា បើកសម្ពោធន៍ បើកអីទេ អត់ទេ ចប់ហើយប្រកាសបិទការដ្ឋានហ្នឹងកងចល័តទៅតាមកន្លែងទៅ តំបន់ណា ទៅតំបន់ហ្នឹងទៅ ។

ដារ៉ា ៖ គេជប់លៀង កាប់គោ កាប់អីទេអឺ?

អាន ៖ អត់មានទេ!

ដានី ៖ គេអត់មាន ដូចថាយើងចប់ទៅថានេះជាស្នាដៃរបស់យើង យើងបានធ្វើមកនេះ យើង ជប់លៀងឲ្យទាំងអស់គ្នា កាប់គោ កាប់ក្របី រាំវែកអី?

អាន ៖ អត់មានទេ!

ដានី ៖ ចុះកម្លាំងដែលទៅលើកទំនប់១មករាហ្នឹងគឺកម្លាំងមកពីគ្រប់តំបន់?

អាន ៖ គ្រប់តំបន់!

ដានី ៖ មានប៉ុន្មានតំបន់កាលហ្នុង?

អាន ៖ បាទ! ៤១, ៤២, ៤៣ ។

ដានី ៖ មាន ៣ តំបន់!

អាន ៖ បាទ!

ដានី ៖ អ៊ំមានប្រសាសន៍មិញថា ចន គាត់តំបន់ ៤៣ អ៊ំ ៤១ ចុះ ៤២ ពីណាគេ?

អាន ៖ ប្អូន កែ ពក ឈ្មោះ អឿន ។

ដានី ៖ ៤២ ប្អូន កែ ពក ឈ្មោះ អឿន?

អាន ៖ បាទ! ប្អូនថ្លៃ ។

ដានី ៖ ៤២ នៅម្តំណាទៅ?

អាន ៖ ម៉ាជួរចំការលើ ស្រុកចំការលើ ទីតាំងនៅហ្នុង ។

ដានី ៖ ចុះអ៊ំមានប្រសាសន៍ថាទៅជាមួយឈ្មោះ កេត ឈ្មោះ ជឹម នោះគាត់ទៅនៅឯណាវិញ?

អាន ៖ នៅក្នុងគណៈកម្មាធិការភាគហ្នឹងឯង ។

ដានី ៖ នៅក្នុងគណៈកម្មាធិការភាគ! គាត់អត់មានគ្រប់គ្រងតំបន់ទេ?

អាន ៖ កេត គេទៅទទួលខាងចំការកៅស៊ូបឹងកេត ហើយ ជឹម គេទៅទទួលចំការកៅស៊ូផ្នែកខាង ណុះទន្លេណុះ ។

ដានី ៖ ខាងណា?

អាន ៖ អូ! មិនដឹងស្អីទេ ។

ដានី ៖ ខាង ជប់ មេមត់ ខាងក្រែក អីហ្នឹង?

អាន ៖ បាទៗ! ទៅខាងហ្នុង ចំការកៅស៊ូបារាំង ខ្ញុំអត់មានការងារ អត់ដែលទៅផង ។

ដានី ៖ ចុះអីចឹងអ៊ំទំនប់ ១មករា លើកចប់យូ ឬក៏ឆាប់ពេលយើងបែកឆ្នាំ៧៩ ពេលយួនចូលណា ចប់មុនហ្នឹងយូ?

អាន ៖ ចប់មុន ។

ដានី ៖ មុនហ្នឹងយូដែរ?

អាន ៖ ចប់មុនប្រហែលខ្ទង់ ៧៧ហ្នឹងចប់ ។

ដានី ៖ ៧៧ ក្រែងអ៊ំទើបនឹងផ្លាស់ទៅតើសប្ត?

អាន ៖ អូ! ៧៨! ៧៨ហ្នឹង ចប់ហើយ ។

ដានី ៖ ចប់ខែណាអ៊ឹ?

អាន ៖ អត់ដឹងទេ ។

ដានី ៖ ខែប្រាំង ឬក៏ខែវស្សា?

អាន ៖ ហ្អឹងហើយ ជិត៧៩ ។

ដានី ៖ អ៊ឹអត់ចាំពេលដែលគេផ្លាស់អ៊ឹពីកំពតទៅកំពង់ចាមហ្នុង ខែប៉ុន្មានទេអ៊ឹន៎?

អាន ៖ អត់ដឹង ។

ដានី ៖ ប៉ុន្តែដឹងថាសខែប្រាំង ឬខែវស្សា ខែភ្លៀង ឬក៏ខែប្រាំងពេលដែលអ៊ឹទៅកំពង់ចាមហ្នុង?

អាន ៖ ខ្ញុំកំណត់ថាខែប្រាំងចុះ ព្រោះដកខ្ញុំទៅ ខ្ញុំកំពុងតែធ្វើទំនប់ បើអីចឹងប្រាំងហើយ ខ្ញុំនៅធ្វើទំនប់ព្រៃដែនយួនណោះ ។

ដានី ៖ ទំនប់ទន់ហាន់?

អាន ៖ ទំនប់ទន់ហាន់ អីចឹងគេឲ្យឡានទៅយកពីទំនប់មកទេ ខ្ញុំនៅទំនប់ទន់ហាន់ ជិតព្រែកវិញគេ នៅណោះ អីចឹងកំណត់ថាខែប្រាំងចុះក្មួយ ប៉ុនមិនដឹងថាខែណាទេ ខ្ញុំអត់ចាំទេ ។

ដារ៉ា ៖ ចុះអ៊ឹមកនៅតំបន់៤១ មកលើក ទំនប់៦ មករា ១ មករា ហ្អឹងអ៊ឹនៅរហូតដល់ឆ្នាំណាពេលណាទៅអ៊ឹ?

អាន ៖ ខ្ញុំនៅរហូតទល់ឆ្នាំ៧៩ ដែលរាជរដ្ឋាភិបាលវៃខ្ញុំរត់ទៅ ។

ដារ៉ា ៖ វៀតណាម វៃ!

អាន ៖ បាទ!

ដានី ៖ វៀតណាម វៃ! ពេលដែលយួនចូលហ្អឹងឬ?

អាន ៖ បាទ! រត់ពេលនោះឯង ។

ដារ៉ា ៖ អីចឹងមុនពេលដែលទ័ពវៀតណាម និងទ័ពខ្មែរ ទ័ពរណសិរ្សអីចូលមក គឺទំនប់អីអស់ហ្អឹងរួចរាល់អស់ហើយ?

អាន ៖ បាទ!

ដារ៉ា ៖ ពេលមកហ្នុងគឺរត់តែម្តង!

អាន ៖ រត់!

ដារ៉ា ៖ រត់ទៅខាងណាវិញ?

អាន ៖ ខ្ញុំរត់ឆ្ពាយមកភ្នំដងរែកនេះឯង រត់មករត់ទៅដំបូងខ្ញុំនៅស៊ឹងជីនិត ម៉ាជួរស៊ឹងជីនិត ស៊ឹងជីនិតហ្អឹងម៉ាជួរទឹកដីស្រុកស៊ឹងត្រង់ ហ្អឹងនៅ៧៩ខ្ញុំនៅហ្នុង ។

ដានី ៖ នៅខាងចំការកៅស៊ូខាងបិតធ្នូ ខាងអូរប្រាំអី?

អាន ៖ បាទ!

ដានី ៖ ទឹកដីកំពង់ចាម មានតែនៅខាង...

អាន ៖ ស្ទឹងត្រង់ៗ!

ដានី ៖ នៅលើភ្នំហ្នឹងម៉ង?

អាន ៖ បាទ! ខ្ញុំនៅម៉ាជួរអន្លែ បូសពកជាប់ស្ទឹងជីនិត មកដល់ឆ្នាំ៨០ ខ្ញុំឡើងមកដងវែកហ្នឹង ឆ្នាំ៨០ឡើងមកតាមដូវរូងមកចូលនៅហ្នឹងមុំបី ។

ដានី ៖ អឺបកមកក្រោយបន្តិច កន្លែងទំនប់៦មករា នៅកន្លែងណាទៅ?

អាន ៖ នៅកំពង់ធំដូចគ្នា ។

ដានី ៖ ទំនប់៦មករានៅកំពង់ធំដែរ?

អាន ៖ បាទ!

ដានី ៖ ពីត្រង់ណាទៅត្រង់ណាទៅ?

អាន ៖ ពីបាកប្រាប់ណាស់ នៅកំពង់ធំ ស្រុកកំពង់ធំ ខេត្តកំពង់ធំដូចគ្នា ម៉ាជួរអាហ្នុងគេហៅស្រុកសន្ទុក ។

ដានី ៖ អាហ្នឹងវាតគ្នាពីទំនប់១មករាតមកទំនប់៦មករា?

អាន ៖ ឆ្ងាយៗ! ឆ្ងាយពីគ្នា ។

ដានី ៖ ទំនប់ហ្នុងជាទំនប់របស់ភាគដែរ ឬក៏...

អាន ៖ អត់ទេ! របស់ស្រុក ។

ដានី ៖ ស្រុកអីគេហ្នុង?

អាន ៖ ស្រុកសន្ទុក ។

ដានី ៖ តែអឺបានចូលរួមលើកហ្នុងដែរ?

អាន ៖ ចូល!

ដានី ៖ ម៉េចបានអឺទៅចូលរួម អឺនៅខាងកំពង់ចាម នៅខាង៤១ ម៉េចបានទៅលើកទំនប់ហ្នុងដែរ?

អាន ៖ ក្នុងឋានៈភាគតែមួយ ។

ដានី ៖ អូ! បានន័យថាអឺនៅក្នុងគណៈកម្មាធិការភាគ?

អាន ៖ បាទ! ដល់នេះទៅគេយកកកម្លាំង ។

អ្នកជិតខាង៖ សមាជិកអចិន្ត្រៃយ៍ភាគឬ?

អាន ៖ បាទ! សមាជិក ។

អ្នកជិតខាង ៖ ត្រូវការកម្លាំងអីគេប្រមូលតាមតំបន់មួយៗហ្នុងទៅ ។

ដានី ៖ អីចឹងអ៊ីចូលរួមលើកទំនប់៦មករាហ្នឹងដែរ?

អាន ៖ បាទ!

ដានី ៖ ចុះទំនប់ខ្ទប១៧មេសានៅឯណាទៅ?

អាន ៖ អាហ្នឹងនៅ៤១ ជាប់ផ្លូវជាតិលេខ៧ ខាងកើតផ្សារស្គន់ ។

ដានី ៖ អាហ្នឹងមិនមែនទំនប់៧មករាទេ?

អាន ៖ ខ្ទប១៧ អាហ្នឹងគេនិយាយពីកំណើតបក្សកុម្មុយនិស្តគេនោះណា អាហ្នុងគេដាក់ខ្ទបទី១៧ ។

ដានី ៖ នៅក្នុងស្រុកអីទេទៅ?

អាន ៖ ស្រុកជើងព្រៃ និងស្រុកព្រៃឈរ ជាប់គ្នាហ្នឹង ។

ដានី ៖ អ៊ីក៏ចូលរួមលើកនៅហ្នឹងដែរ?

អាន ៖ បាទ!

ដានី ៖ ចុះកាលទំនប់ ៦មករា ចប់ឆ្នាំណាទៅ?

អាន ៖ បន្ទាប់ពីអា១មករាហ្នុងមកបានមកបង្ហើយអាទំនប់៦មករា រួចបានមកអាទំនប់ខ្ទប១៧នេះ ហើយបានទៅចាក់សំណង់ទ្វារទេ សំណង់ទ្វារទឹក សំណង់ទ្វាហ្នឹង គ្រាន់អាសន្នះបិទបើកអី រៀបចំអត់បានស្រួលទេ វ៉ៃប្រាំ រត់ចោលទៅ ។

ដានី ៖ ចុះដូចជាទំនប់ផ្សេងទៀត ទំនប់ពាមជាំង?

អាន ៖ ពាមជាំងហើយ ក្នុង៧៨ ។

ដានី ៖ ទំនប់ពាមជាំងនៅឯណាទៅ?

អាន ៖ ទំនប់ពាមជាំងនៅស្រុកកងមាស ។

ដានី ៖ ក្នុងតំបន់៤១ដែរ?

អាន ៖ បាទ! ភ្នំញ៉ោនៅស្រុកបាធាយ ហៅភ្នំញ៉ោ ។

ដានី ៖ និយាយទៅទំនប់ទាំង៥ហ្នឹងអ៊ីចូលរួមទាំងអស់?

អាន ៖ ចូលរួមទាំងអស់!

ដារ៉ា ៖ ចូលរួមហ្នុង ក្នុងនាមជាអ្នកគ្រប់គ្រងនៅក្នុងតំបន់៤១ អីចឹងឬអ៊ឹ?

អាន ៖ បាទ!

ដានី ៖ ជាសមាជិកអចិន្ត្រៃយ៍ភូមិភាគដែរ!

អាន ៖ មិនមែនគ្រាន់តែចូលទេក្អួយអើយ វែកដូចតែគេ ។

ដារ៉ា ៖ វែកដូចគេទៀត!

អាន ៖ ទៅបាយមួយស្រាក់ ជួនកាលយកមកហូបនៅផ្ទះវិញ ប៉ុណ្ណឹងហើយណាក្មួយណា!

ដានី ៖ បាទ!អ៊ឹ ខ្ញុំសុំនេះបន្តិច ខ្ញុំធ្លាប់បានអាននេះ សៀវភៅ អានឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាណាអ៊ឹ អានក្នុងហ្នឹង អានចម្លើយសារភាពរបស់ចននេះ គាំ ចាន់ ហៅ ចនគាត់លេខាតំបន់៤៣ហ្នឹងណាអ៊ឹ ក្នុងហ្នុងគេមានឆ្លើយដាក់ឈ្មោះអ៊ីដែរ ឈ្មោះអ៊ី និងឈ្មោះអ៊ឹ ប៉ូច មានចម្លើយមួយឃ្លាហ្នុងគេដាក់ថាខាងភូមិឧត្តរ ខាងកម្មាភិបាលចាស់ហ្នឹងណា គេមានផែនការមួយដើម្បីកម្ទេចកម្មាភិបាលមកពីភូមិភាគនិរតី មានឈ្មោះអ៊ីបងអាន ហីនិងឈ្មោះ ប៉ូច ដែលជាគណៈស្រុកបារាយ អីចឹងណាអ៊ឹ កាលហ្នុងអ៊ឹមានដឹងទំនាក់ទំនង ដូចថារបៀបកម្មាភិបាលចាស់របស់ភូមិភាគកណ្តាល ហីយើងកម្មាភិបាលមកពីនិរតីមក យើងចូលទៅគ្រប់គ្រងនៅភូមិកណ្តាលហ្នឹងណា ដូចថាយើងមានទំនាស់អីគ្នាយ៉ាងម៉េចដែរកាលហ្នុង?

អាន ៖ អត់មានទំនាស់អីផង! អត់មានជំនាស់អីទេ ក៏ប៉ុន្តែអាត្រង់ហ្នឹងខ្ញុំទទួលស្គាល់វាអីចឹងមែនព្រោះពេលធ្វើសន្និបាត អាពេលធ្វើសន្និបាតហ្នឹង ខ្ញុំដេកនៅក្នុងបន្ទប់បិទអីចឹង ដល់ពេលយប់មានគេលបរកចាក់មែន ប៉ុន្មានគ្នាខ្ញុំនៅដេកម៉ាបន្ទប់កាលហ្នុងភាគគេបើកធ្វើសន្និបាតរួចទៅស្នាក់នៅលើផ្ទះមួយ ហើយខ្ញុំគេចរួច ។

ដារ៉ា ៖ មានការចាប់ដែរអ៊ឹ?

អាន ៖ បាទ!

ដារ៉ា ៖ មានការចាប់មែនឬ?

អាន ៖ អត់ទេ! គេរកចាក់ខ្ញុំ ។

ដារ៉ា ៖ អ្នកដែររកចាក់អ៊ឹ?

អាន ៖ មិនដឹងដែរ គ្រាន់តែឮសូរថ្មើរជើងឡើង ដល់ពេលឡើងមកអីចឹង ដល់ពេលឡើងមក ខ្ញុំទ្វារអីចេះពេលខ្ញុំដេកខ្ញុំប្រយ័ត ខ្ញុំរាំងអីចឹង ទ្វារវាអត់មានគន្លឹសគន្លឹសអីត្រឹមត្រូវទេ អើវាទើបច្បាំងហើយនោះ ដល់អីចឹងខ្ញុំយកខ្សែភ្លើងព័ទ្ធលើអីចឹង ពេលខ្ញុំដេកខ្ញុំព័ទ្ធអីចឹងនឹកថាចងនេះមិនជាប់ទេ បើអីចឹងផាកលិច ផាកកើតទៅឃើញអាដែកគោល១២ សង់ទីម៉ែត្រមួយដើមនៅដេក ហើយខ្ញុំយកអាដែកគោលនោះមកដាក់អីចឹង ថាបើគេប្រានទ្វារមកវាច្បាស់ជាធ្លាក់ដែកគោលហ្នុង ច្បាស់ជាខ្ញុំឮហើយ ខ្ញុំដាក់អីចឹង ម៉ោង១២យប់ ឮតែគ្រាំង! ឆឹង ខ្ញុំផ្ទុកក្រោមគ្រែ មានអាបន្ទប់មួយទៀតខ្ញុំរមៀលខ្លួនចេញទៅ ចាក់ឮសូរតែភឹប ចាក់ត្រូវខ្នើយខ្ញុំរមៀលចេញបាត់ហើយ បែបអីចឹងឬរឿងមិញនោះ ក្មួយមានប្រសាសន៍មិញនោះណា ។

ដានី ៖ ក្នុងចម្លើយសារភាពហ្នុង ខ្ញុំអានទៅមានមួយឃ្លាហ្នុង ដូចថា គាំ ចាន់ ហៅ ចន គាត់និយាយថា កម្មាភិបាលខាងភូមិភាគឧត្តរចាស់ហ្នឹងណាគេមានផែនការមួយដើម្បីកម្មេច ដូចថាគេដាក់ឈ្មោះអ៊ី គេដាក់ឈ្មោះបងអាន ហីហ្នឹងមិត្តប៉ូច អីចឹងណា អាហ្នឹងដូចជាអ៊ីមានប្រសាសន៍មិញថា អ៊ីទទួលស្គាល់ថាមានគេ...

អាន ៖ បាទ! មានមែនៗ

ដានី ៖ ហើយក្រោយមក ចន ហ្នុងយ៉ាងម៉េចដែរ គេ...

អាន ៖ ចន ហ្នឹងមិនដឹងទេ ក្រោយមក គេចាប់បាត់ទៅ ចាប់ហ្នុងមិនមែនរឿងរ៉ាវទំនាសជាមួយខ្ញុំជាមួយអី អត់មានទេ អត់ទេ មិនមែនទំនាស់ជាមួយ ប៉ូច ជាមួយខ្ញុំ ជាមួយ ស៊ីម អីមិនមែនទេ អត់ទេ ផែនការគេខាងលើទេ ព្រោះលេខាកំពង់ធំហ្នុងនៅ ហីគណៈភាគជាមួយ កែ ពក ឃើញនៅ ចន ហ្នឹងមួយ នៅតែមួយហ្នឹងទេ នៅ ចន និង កែ ពក ៗ

ដារ៉ា ៖ នៅពេលដែលថាចាប់លើកមុនទៅហ្នុង..

អាន ៖ ដែលថាអស់ហើយហ្នុង នៅកែ ពក នៅចន ហ្នឹងមួយគណៈភាគ បាទ! រួចដូច្នេះមិនមែនទំនាស់រឿងរ៉ាវមកពីខ្ញុំប្តឹង ខ្ញុំផ្តល់អីមិនមែនទេ គឺខាងលើទេ ៗ

ដានី ៖ ចុះអ៊ីមានដឹងផែនការអីខ្លះទាក់ទងពីការចាប់ពួកកម្មាភិបាលចាស់ហ្នឹងណា អ៊ីមានដឹងផែនការអីខ្លះដែរ ទាក់ទងហ្នឹង?

អាន ៖ អត់ដឹងទេក្មួយ! ដូចខ្ញុំជម្រាបថាគេចាប់អស់រលីញរលត់ហើយ នៅសល់តែ២នាក់ហ្នឹង អូ! ៤១ នៅសល់មួយឈ្មោះ សុប តំបន់ ៤១ នោះណា នៅសល់មួយ រួចអ្នកភាគហ្នឹងនៅសល់២ហ្នឹង រួចដល់ហ្នឹងទៅគេមកយកអស់ដដែល មិនមែនរឿងខ្ញុំទេ អត់ទេ ចេញសេក្តីសម្រេចមក ឡានគូជសមកយកទេ ខ្ញុំមិនដឹងទេ អត់ទេ អត់មានរឿងរ៉ាវទាក់ទិនអីទេបាទ!

ដារ៉ា ៖ អាហ្នឹងវាមានសភាពការណ៍យ៉ាងម៉េចបានឈានទៅដល់...

អាន ៖ គេថាក្បត់ ចុះខ្ញុំដឹងអី គេថាសុទ្ធតែក្បត់ៗ ខ្ញុំឯណោះក៏ មកទទួលខុសត្រូវមួយថ្ងៃៗ ធ្វើតែស្រែ ធ្វើតែទំនប់ ខ្វាចស្រែហ្នឹងវាទុំបាក់កួរ ខ្វាចស្អីឯណាវារលួយ កណ្តុរស៊ី ភ័យតែអានោះទេ បើលេងតែអីចឹងទៅអាកណ្តុរស៊ីអស់ ចាប់ស៊ីអស់ វាមិនរឿង ភ័យតែអានោះទេ បានមួយថ្ងៃៗសព្វដីតែទាំងអស់ស្រែ បើមិនសព្វ មិនដឹងថាត្រង់ណាវាយ៉ាងម៉េច ត្រង់ណាវាខូចស្អី ត្រង់ណាវារលួយស្អី ត្រង់ណាវាកណ្តុរស៊ី ត្រង់ណាវាចាប ត្រង់ណាវាទុំស្រួយបាក់ក ៗ

ដានី :	ចុះអ៊ឹ មួយទៀតពេលដែលថាអ៊ឹត្រូវគេលួចធ្វើឃាតអ៊ឹ អ៊ឹគេចរួចខ្លួនដូចអ៊ឹមានប្រសាសន៍មិញហ្នឹង ចុះពេលរួចហ្នឹងហើយ អ៊ឹមានប្រជុំអីដាក់ផែនការអីយ៉ាងម៉េចដែរ នៅពេលដែលគេលួចធ្វើឃាតអ៊ឹហើយនោះ?

អាន :	អត់ទេ! អត់មាត់រលីង ក្នុងតំបន់ ៤១ ប៉ុន្មានស្រុក គ្នាប៉ុន្មាននាក់ហ្នឹង អត់មាត់រលីងស្ងាត់ឈឹងរហូត អត់មាត់ទេ គ្រាន់តែប្រាប់ថា ប្រយ័តយើងដេក ដេកឲ្យប្រយ័ត ចប់អង្គប្រជុំភ្លាមប្រ៉ុចមក អត់មាត់ អត់កអីទេ ។

ដានី :	ប្រជុំនៅឯណាហ្នឹង?

អាន :	ប្រជុំនៅកំពង់ចាម ។

ដានី :	ប្រជុំស្អីគេ?

អាន :	ភូមិភាគ ។

ដារ៉ា :	អីចឹងមានន័យថារឿងហ្នឹងឡើងទៅដល់ភូមិភាគដែរ រឿងដែលថាគេធ្វើឃាតអ៊ីណា?

អាន :	អត់ទេ!

ដារ៉ា :	ចុះម៉េច អ៊ឹថាប្រជុំនៅភាគនោះ?

អាន :	ប្រជុំធ្វើសន្និបាតភាគ ប៉ុន្តែគេលបរកសម្លាប់ហ្នឹង ខ្ញុំគេលបរកសម្លាប់នោះ ប៉ុន្មាននាក់ណុះដេកនោះ ។

ដានី :	កាលប្រជុំភូមិភាគហ្នឹងមាន ចន គាត់ចូលរួមដែរ?

អាន :	ចូល!

ដានី :	ចន, កែ ពក, អ៊ឹ...

អាន :	បាទ!

ដានី :	ប៉ុន្តែអ៊ឹកាលហ្នឹងតមានរាយការណ៍ប្រាប់ កែ ពក, ចន អី ទាក់ទងពីការគេធ្វើឃាតទេ?

អាន :	អត់ទេ! ខ្ញុំអត់ឲ្យសៅហ្នឹងទេ ។

ដារ៉ា :	ចុះក្រោយមករហូតដល់បែក៧៩ ឬក៏មកដល់ឥឡូវហ្នឹងក៏ដោយ អ៊ឹដឹងពីមូលហេតុនៃការដែលគេធ្វើលបធ្វើឃាតអ៊ឹដែរទេ?

អាន :	អត់ដឹងទេ! មិនដឹងជាមូលហេតុអី ឬក៏គេប្រណែនវែនជនអីក៏មិនដឹង ព្រោះវាអត់ដែលមានទំនាស់អី មានតែទំនាស់រឿងផ្លាស់ទៅទទួលហើយក្នុងឋានៈនោះគេនៅជាភាគដដែល រួចមិនដឹងជាទំនាស់រឿងអី ក៏អត់ដឹងផងបាទ!

ដានី :	ចុះកាលហ្នឹងអ៊ឹ តំបន់៤១ អ៊ឹ មានស្រុកព្រៃឈរ ស្រុកកងមាស ស្រុកជើងព្រៃស្រុកបាធាយ..

អាន ៖ បាទ! ស្រុកកំពង់សៀមមួយទៀត ។

ដានី ៖ កំពង់សៀមមួយទៀត?

អាន ៖ បាទ!

ដានី ៖ អីចឹងភ្នំប្រុសភ្នំស្រី នៅក្នុងតំបន់៤១ដែរ?

អាន ៖ ភ្នំប្រុសភ្នំស្រី កាត់ទៅចំការលើ តំបន់៤២ ។

ដានី ៖ ភ្នំប្រុសភ្នំស្រីហ្នឹងប៉ុ?

អាន ៖ បាទ!

ដានី ៖ អាកន្លែងផ្លូវមានភ្នំខ្ពស់ពីរជិតដល់ទីរួមខេត្តកំពង់ចាមណាអ៊ំ?

អាន ៖ បាទ! អាហ្នឹងទៅ ៤២ ។

ដានី ៖ អាហ្នឹងចូល៤២ វិញណាអ៊ំ?

អាន ៖ បាទ! ខាងអឿន បួន កែ ពក ។

ដានី ៖ អ៊ំ! នៅខាងកងមាស ខ្ញុំធ្លាប់ទៅកងមាសអី អ៊ំកន្លែងអូតាកួនណា អ៊ំស្គាល់វត្តអូរតាកួន?

អាន ៖ អត់ស្គាល់ផង ។ អូរតាកួន!

ដានី ៖ កន្លែងហ្នឹងក្នុងស្រុកកងមាស កន្លែងហ្នុងគេហៅថាមន្ទីរសន្តិសុខវត្តអូតាកួន អ៊ំដែលឮអាហ្នឹងដែរអត់?

អាន ៖ អត់ដឹងទេ ក្រែងមន្ទីរសន្តិសុខអីគេពីមុនមក អត់ដឹងទេបាទ!

ដានី ៖ ចុះទៅតំបន់ ៤១ មន្ទីរសន្តិសុខនៅឯណាទៅ មន្ទីរសន្តិសុខតំបន់?

អាន ៖ មន្ទីរសន្តិសុខហ្នុងមិនមានផង វាមានតាំងពីមុនមក គឺនៅនឹងស្រុកព្រៃឈរ នៅឃុំគរ នៅខាងជើង បើថាអូតាកួនឯណានោះមិនដឹងទេ ។

ដានី ៖ ចុះអ៊ំកាលហ្នុងធ្វើការផ្សារអីជាមួយ កែ ពក អីអ៊ំធ្វើការរលូនដែរឬមិនសូវទេ?

អាន ៖ អត់អីទេបាទ!

ដានី ៖ ចុះកាលហ្នុង ចន អីអ្នកផ្សេងៗអីទៀតធ្វើការជាមួយគ្នាអត់ដែលមានបញ្ហាអី ដូចថាមើលគ្នា ដូចថានិយាយចុងមាត់ចុងករអី ឬក៏យើងគ្នាមិនចំអី?

អាន ៖ អត់ទេក្មួយ អត់មានអីផង អីចឹងបានខ្ញុំថាវាមិនដឹងរឿងរ៉ាវអី ។

ដានី ៖ ចុះតាម៉ុកអីគាត់មានដែលធ្លាប់ចុះទៅខាងភូមិភាគកណ្តាលហ្នឹងទេ?

អាន ៖ អត់ដែលទេ! ដល់ពេលនោះអត់ដែលទេ ។

ដានី ៖ ចុះអ៊ំមានដែលធ្លាប់ឡើងមកប្រជុំនៅខាងភ្នំពេញ
យើងនៅខាងមជ្ឈិមនៅភ្នំពេញអីមានទេ?

អាន ៖ ទៅ! ក្នុងឋានៈតំបន់ ក្នុងឋានៈអីៗសុទ្ធតែទៅហើយ ។

ដានី ៖ យើងដូចថាឡើងទៅប្រជុំនៅភ្នំពេញហ្នុង យើងយ៉ាងម៉េច ដូចថារៀងរាល់ខែ រៀងរាល់ត្រីមាស ឬក៏ឆ្នាំអីយ៉ាងម៉េចដែរអ៊ំ ពេលដែលយើងឡើងមកប្រជុំនៅភ្នំពេញ?

អាន ៖ ប្រជុំនៅភ្នំពេញទាល់តែគេហៅ បើលេខាភាគអាហ្នឹងគេមានកម្មវិធីគេ បើដូចខ្ញុំ ដូចអីហ្នឹងត្រូវហៅ ឧទាហរណ៍ថាការធ្វើសន្និបាត ធ្វើអី ពេលហ្នឹងត្រូវហៅទៅហើយ សន្និបាទ វាមានសន្និបាតរបស់ភាគ មុនហ្នឹងធ្វើសន្និបាតរួមទូទាំងប្រទេសហ្នុង ភាគគេធ្វើសន្និបាតហើយ ឧទាហណ៍ថានិយាយពីការអនុវត្ត ដូចខ្ញុំថាអីចឹងណា ក្នុងគោលការណ៍ ផែនការដែលថា ការពារ និងកសាង ដូច្នេះពេលគេធ្វើសន្និបាតហ្នឹងគេលើកគោលការណ៍មកពិសោធន៍ ដូចជាផែនការប្រចាំឆ្នាំ ផែនការអីទាំងអស់ សរុបមកធ្វើអីបាន បានស្អី មិនបានស្អី បើឧទាហរណ៍ថា ការអ្នកធ្វើការខាងអ្នកគ្រប់គ្រងផ្ទៃក្នុងអីចឹងទៅ ទី១គោលការណ៍របស់គេផ្នែកគេខាងកសាងកម្លាំង ពង្រឹងកម្លាំង ពង្រីកកម្លាំង អីៗទៅអាហ្នឹងកិច្ចការខាងផ្ទៃក្នុងរបស់គេ អីចឹងគេធ្វើសន្និបាតហ្នឹងពិសោធន៍ ហីខាងផ្នែកសេដកិច្ចហ្នឹងក៏សាកគិតជាមួយគ្នាហ្នឹងឯង គិតជាមួយគ្នាអីចឹងទៅ ទូទាត់ផែនការចាស់ ហីលើកផែនការថ្មីទៅ ហីការកសាងផែនការផ្ទៃក្នុងអី ការកសាងផែនការផ្ទៃក្នុង និយាយពីការអនុវត្តផែនការចាស់អីចឹងទៅ ហីលើកផែនការថ្មីអីចឹងទៅ ស្អីក៏វាអីចឹងដែរ ពិនិត្យចាស់លើកផែនការថ្មីអីចឹងទៅ បានលើកអីចឹងហើយ បានគេយកគោលការណ៍ហ្នឹងទៅឆ្លងមជ្ឈឹមទៅ ដល់ឆ្លងជាមួយមជ្ឈឹមហើយ បានមជ្ឈឹមកោះហៅទៅធ្វើសន្និបាតជាមួយមជ្ឈឹមទៅបាទ ។

ដានី ៖ ចុះអ៊ំកាលហ្នឹងយើង ដូចថាគណៈអធិបតីនៅក្នុងសន្និបាតពេលហ្នុងពីណាខ្លះទៅអ៊ំចាំទេ?

អាន ៖ គណៈអធីបតីខាងលើឬ?

ដានី ៖ បាទ! ខាងលើ!

អាន ៖ មានប៉ុល ពត, នួន ជា, សោ ភឹម, តាម៉ុក ។

ដានី ៖ អ្នកណាទៀត?

អាន ៖ អៀង សារី បាទ!

ដានី ៖ ដូចថាអ៊ំមកពីតំបន់មួយៗណាយើងត្រូវរាយការណ៍ទៅខាងគណៈអធិបតី យើងឡើងរាយការណ៍នៅក្នុងអង្គប្រជុំហ្នុង អង្គសន្និបាតហ្នឹង ឬក៏យើងទៅរាយការណ៍ផ្ទាល់ៗ...

អាន ៖ ពេលសន្តិបាតហ្នឹងខាងគេនៅអីចឹងទៅ យើងនៅអីចឹង យើងធ្វើសេចក្តីរាយការណ៍នៅខាងក្រោមហ្នឹង មីក្រូគេហ្នុងនៅក្នុងស្តាតម៉ង ពហុកីឡាដ្ឋានជាតិ ស្តាតអូឡាំពិកហ្នុង

ដានី ៖ អ៊ីប៉ាន់ស្មានមើល អ៊ីមកកំពង់ចាមឆ្នាំ៧៧ រហូតដល់ឆ្នាំ៧៩ អ៊ីមកភ្នំពេញបានប៉ុន្មានដងដែរ មកមហាសន្និបាត ឬក៏មករាយការណ៍ជូនបក្សអីចឹងណា ច្រើនដងដែរអត់?

អាន ៖ អត់ចាំទេ ។

ដានី ៖ ញឹកញាប់ទេ?

អាន ៖ ធ្លាប់ដែរនៅខាងកំពត មកខាងកំពង់ចាម នៅកំពង់ចាមដូចមិនបានញឹកណាទេ បើកំពតញឹកញាប់ដែរ ។

ដានី ៖ អាហ្នឹងយើងមកច្រើនមកជាសន្និបាត ជាមួយរួម ជាទូទាំងប្រទេស?

អាន ៖ បាទ! ជារួម ។

ដានី ៖ ចុះដូចថាយើងមកជា...

អាន ៖ ជាបុគ្គលឬ!

ដានី ៖ ជាបុគ្គល ជាអី?

អាន ៖ អត់ទេ!

ដានី ៖ ចុះអ៊ីមួយទៀត អ៊ីមានប្រសាសន៍មិញថាគណៈភូមិភាគ លេខាភូមិភាគណា គាត់ជាសមាជិកអចិន្ត្រៃយ៍របស់បក្សកុម្មុយនិស្តកម្ពុជា អីចឹងឬអ៊ី?

អាន ៖ បាទ!

ដានី ៖ អ៊ីមានប្រសាសន៍មិញថា តាម៉ុកអីគាត់ជាសមាជិកអចិន្ត្រៃយ៍?

អាន ៖ បាទ!

ដានី ៖ ចុះយើងជាគណៈតំបន់ យើងជាសមាជិកអីដែរក្នុងហ្នឹង ដូចថាជួរជាគណៈតំបន់ណា?

អាន ៖ សមាជិកភាគ ។

ដានី ៖ ជាសមាជិកមជ្ឈឹមអីដែរ?

អាន ៖ អត់ទេ! គណៈកម្មាធិការភូមិភាគ ។

ដានី ៖ ប៉ុន្តែតួនាទីក្នុងបក្សណា?

អាន ៖ តួនាទីដោយបុគ្គល បុគ្គលខ្លះគេលេខាតំបន់ គេរហូតដល់សមាជិកមជ្ឈឹមរបស់គេ ប៉ុន្តែខ្លះអត់ ដូចខ្ញុំអ៊ីអត់មានទេ ។

ដារ៉ា ៖ ឧទាហរណ៍មួយមើលអ៊ីថាអ្នកណាដែលត្រឹមតែជាលេខាតំបន់ ហើយទៅជាសមាជិកមជ្ឈឹម?

អាន ៖ អាហ្នឹងគេហៅអី តំបន់ស្វាយយ័ត ។

ដារ៉ា ៖ អូ!

អាន ៖ អាហ្នឹងគេឡើងទៅមជ្ឈិមហើយ

ដារ៉ា ៖ អ៊ីចឹងលេខាតំបន់ស្វាយយ័តគឺជាសមាជិករបស់មជ្ឈិមផ្ទាល់តែម្តង?

អាន ៖ បាទ!

ដានី ៖ អ៊ំប្រទ្បំបន្តិច អាកន្ទែងហ្នឹង ដូចថាបុគ្គលយើង ដែលយើងកសាងក្នុងបក្សណា ដូចជាយើងឡើងជាសម្ព័ន្ធ ជាបក្សជន ដល់ក្រោយមកយើងឡើងទៅជាសមាជិកមជ្ឈិមរបស់បក្សកុម្មុយនិស្តកម្ពុជា អាហ្នឹងយើងជាលេខាតំបន់ អាហ្នឹងបានន័យថាយើងមានឋានានុក្រមយើង ឋានៈយើងជាសមាជិករបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ឬក៏យ៉ាងម៉េចអ៊ំ?

អាន ៖ ដូចខ្ញុំជម្រាបថាដោយបុគ្គល បុគ្គលគេខ្លះ គេរហូតទៅដល់សមាជិកពេញសិទ្ធ បុគ្គលគេខ្លះខ្លះជាសមាជិកត្រៀមអ៊ីចឹងទៅ ក៏ប៉ុន្តែខ្លះអត់ៗ

ដានី ៖ ចុះអ៊ំក្នុងឋានៈជាស្អី?

អាន ៖ ខ្ញុំអត់មានទេ!

ដារ៉ា ៖ ត្រឹមតែជាលេខាតំបន់?

អាន ៖ បាទ! តំបន់ខាងជើង ភាគៗ

ដារ៉ា ៖ អត់ចូលទៅដល់...

អាន ៖ អត់មានទេ!

ដានី ៖ ពេលអ៊ំទៅកំពង់ចាមហ្នុង ភូមិភាគឧត្តរគេបំបែកហើយកាលហ្នុង?

អាន ៖ បាទ!

ដានី ៖ ខាងសៀមរាប ខាងព្រះវិហារគេបំបែកជាភូមិភាគថ្មីមួយទៀតឬអ៊ំ?

អាន ៖ ខ្ញុំទៅ ខ្ញុំដឹងថាភូមិភាគកណ្តាលហ្នឹងមានតែកំពង់ធំ និងកំពង់ចាមទេណា តែពីមុន កែ ពក គាត់ថាភូមិភាគឧត្តរមានទាំងព្រះវិហារ ឧត្តរមានជ័យ សៀមរាប ផង កំពង់ធំ ផង ដល់ក្រោយមកគឺមានតែ២ខេត្តទេ កំពង់ធំ និងកំពង់ចាម ដល់អ៊ីចឹងទៅហៅថាភូមិកណ្តាលមាន កែ ពក ជាប្រធានៗ

ដានី ៖ ចុះខាងសៀមរាប ឧត្តរមានជ័យ ហីហ្នឹងព្រះវិហារ?

អាន ៖ កាលហ្នុងឃើញគេយក កង ចាប ទៅ ប៉ុន្តែមិនដឹងជាជើងគេប៉ុន្មានអីប៉ុន្មាន ខ្ញុំអត់ដឹងទេៗ

ដានី ៖ អ៊ីចឹង កង ចាប គាត់ទៅកាន់ខាង សៀមរាប ព្រះវិហារវិញ?

អាន ៖ ខាងសៀមរាបៗ

ដានី ៖ គាត់មានតួនាទីជាស្អីទៅ កង ចាប?

អាន ៖ ខាងភាគ ជាលេខភាគ ប៉ុន្តែដើងគេប៉ុន្មានៗនោះខ្ញុំអត់ដឹងទេ ។

ដាវ៉ា ៖ ដើងហ្នុង អ៊ឹចង់និយាយថា សិទ្ធអំណាចគាត់ទៅដល់ណាទៀតអ៊ឹណ៎?

អាន ៖ ទេ! និយាយពីគណៈកម្មាធិការភាគគេនោះ អត់ស្គាល់ទេ ។

ដានី ៖ ស្គាល់តែ កង ចាប មួយទេ!

អាន ៖ បាទ! កង ចាប ខ្ញុំធ្លាប់នៅជាមួយ ។

ដានី ៖ ភូមិភាគអីគេទៅ?

អាន ៖ នៅឯណាទៅ!

ដានី ៖ ភូមិភាគដែល កង ចាប គាត់ទៅកាន់នៅសៀមរាបហ្នុង?

អាន ៖ កាលហ្នុងខ្ញុំអត់ដឹងទេ កាលហ្នុងគេថាឲ្យទៅសៀមរាប គេថាឲ្យទៅទទួលខុសត្រូវនៅសៀមរាប ។

ដានី ៖ គេដកពីកំពតទៅដែរ?

អាន ៖ បាទ!

ដានី ៖ ដកទៅជាមួយអ៊ីដែរ ឬយ៉ាងម៉េច?

អាន ៖ អត់ទេ! ដកក្រោយខ្ញុំទេ ។

ដានី ៖ អ៊ឹច្បាស់ទេកាលហ្នុង កាលគាត់ទៅខាងសៀមរាបអីហ្នុង?

អាន ៖ បាទ! អត់ទេ ។ ហ៊ីភូមិភាគអីៗ ខ្ញុំអត់ដឹងទេ ។

ដានី ៖ ចុះអ៊ឹកាលហ្នុងអ៊ឹរៀបការនៅ កាលអ៊ឹនៅកំពត នៅកំពង់ចាមអី?

អាន ៖ ខ្ញុំការហើយ! ប្រពន្ធមុននោះ ។

ដានី ៖ អ៊ឹការតាំងពីអង្គាលប្រពន្ធមុននោះ?

អាន ៖ ខ្ញុំការឆ្នាំ៧៦ ។

ដានី ៖ កាលហ្នុងអ៊ឹអាយុប៉ុន្មានហើយ កាលការឆ្នាំ៧៦?

អាន ៖ អត់ចាំទេ!

ដានី ៖ អ៊ឹការឆ្នាំ៧៦ហ្នុងអ៊ឹការនៅឯណាទៅ?

អាន ៖ ខ្ញុំការនៅកំពត នៅការដ្ឋានធ្វើទំនប់ ។

ដានី ៖ ទំនប់ណាទៅអ៊ឹ?

អាន ៖ ទំនប់រំលេច ។

ដានី ៖ កាលហ្នុងការនៅឆ្នាំ៧៦នៅការដ្ឋានទំនប់រំលេច?

អាន ៖ បាទ!

ដានី ៖ ចុះប្រពន្ធគាត់ធ្វើអីកាលហ្នឹង?

អាន ៖ ប្រធានកងចល័ត ហើខ្ញុំប្រធានកងចល័តដែរ ។

ដានី ៖ ប្រធានអីគាត់ប្រធានកងចល័តអីគេ?

អាន ៖ ចល័តស្រុកឈូក ។

ដានី ៖ ប្រធានកងចល័តស្រុកឈូក?

អាន ៖ បាទ!

ដារ៉ា ៖ គាត់ឈ្មោះអីអ៊ី?

អាន ៖ កាន ។

ដានី ៖ អីចឹងដល់ពេលគាត់រៀបការហើយគាត់ធ្វើអីវិញទៅ?

អាន ៖ គាត់នៅទទួលកងចល័តស្រុកឈូកហ្នឹងដដែល ។

ដានី ៖ ចុះពេលដែលអីផ្លាស់មកកំពង់ចាម គាត់ផ្លាស់មកជាមួយដែរទេ?

អាន ៖ គាត់មក! មកលែងធ្វើអីទៅ ។

ដានី ៖ គាត់មកកំពង់ចាម មកជាមួយអ៊ីគាត់អត់ធ្វើអីទៀតទេ?

អាន ៖ នៅមន្ទីរ ។

ដានី ៖ មន្ទីរណាទៅ?

អាន ៖ មន្ទីរខ្ញុំ ៤១ នៅព្រៃទទឹង ។

ដានី ៖ នៅម្ដុំណា មន្ទីរតំបន់ ៤១?

អាន ៖ មានធ្វើស្អីឯណា មានតែផ្ទះមួយប្រហែលប៉ុណ្ណឹងណា ។

ដានី ៖ នៅកន្លែងផ្សារព្រៃទទឹងហ្នឹងម៉ង?

អាន ៖ បាទ! នៅផ្សារព្រៃទទឹងហ្នឹង ។ ផ្ទះហ្នឹង ផ្ទះគណៈតំបន់គេចាស់គេនៅ ខ្ញុំមិនមែនទៅធ្វើទៅអីទេ ទៅនៅផ្ទះហ្នឹង អាគេដកទៅណាបាត់ទៅ ខ្ញុំទៅនៅផ្ទះហ្នឹង ។

ដានី ៖ អីចឹងប្រពន្ធអ៊ីគាត់មិនមែនគណៈស្រុកកងមាសទេ?

អាន ៖ អត់ទេ! អត់មានស្រុកកងមាសអីទេ ។

ដានី ៖ ក្រែងគាត់ឈ្មោះ កាន!

អាន ៖ កាន ហ្នឹងប្រុសតើស ។

ដានី ៖ ខ្ញុំស្មានតែឈ្មោះកានហ្នឹង ជាគ្រួសាររបស់អ៊ីឈ្មោះកានហ្នឹងគាត់គណៈស្រុកកងមាស?

អាន ៖ អត់ទេ!

ដានី ៖ អីចឹងប្រពន្ធអ៊ីគាត់នៅមន្ទីរតំបន់?

អាន ៖ បាទ!

ដានី ៖ គាត់ធ្វើអី?

អាន ៖ បើខ្ញុំទៅធ្វើទំនប់វាទៅវែកដីទំនប់ដូចតែគ្នា ។

ដានី ៖ តែអ៊ំអត់មានកូនចៅទេតាំងពីរៀបការជាមួយគាត់?

អាន ៖ វែកដីទំនប់ហ្នឹងវាជ្រុះអាកូនហ្នុងបាត់រហូតទៅ ។

ដានី ៖ អ៊ំមានកូនដែរ ប៉ុន្តែគាត់...

អាន ៖ វាជ្រុះនឹងវែកដី ។

ដារ៉ា ៖ គេអត់មានផ្តល់ជាសិទ្ធអីថាប្រពន្ធលេខាតំបន់៤១អី គេអត់មានលើកលែងទេអ៊ំកាលហ្នុង?

អាន ៖ អត់ទេ! ធ្វើដូចតែគ្នា លើកលែងឯណា បើខ្ញុំអត់លើកលែងផង ។

ដារ៉ា ៖ អ៊ំអត់មានប្រើសិទ្ធិរបស់អ៊ំផ្ទាល់ជាលេខាតំបន៤១ហ្នឹង ទុកប្រពន្ធរបស់អ៊ំកុំឲ្យទៅធ្វើការងារដើម្បីឲ្យបានកូនចៅអី?

អាន ៖ អត់ទេ! អត់មានទុកផង ។

ដារ៉ា ៖ ស្មើភាពម៉ង អ៊ំលេងមួយស្មើភាពម៉ងអ៊ំ!

អាន ៖ បាទ! គ្រួសារនិយម ។

ដានី ៖ ចុះបងប្អូនអ៊ំដូចអ៊ំរៀបរាបមានបងប្អូន៥នាក់អីចឹង បងប្អូនអ៊ំគាត់ទៅខាងកំពង់ចាមជាមួយអ៊ំដែរ?

អាន ៖ អត់ទេ! បែកគ្នារហូត អត់នៅជាមួយគ្នាទេ សម័យខ្មែរក្រហមយើងមានការងារផ្សេងៗពីគ្នា ទីទៃពីគ្នា អត់ដែរមានទេ ទើបមានជួបជុំគ្នាឥឡូវហ្នឹងខ្លះ ពីដើមអត់ទេ ខ្ញុំដោយខ្ញុំ គេដោយគេ ។

ដារ៉ា ៖ អីចឹងនៅទៅមករកគ្នាដែរបងប្អូនអ៊ំ?

អាន ៖ យូរទៅជួបគ្នាម្តងទៅ ឥឡូវមួយនៅអន្លង់វែងនោះខ្ញុំអត់ដែរបានជួបទេ នៅជិតប៉ូចនោះ ។

ដារ៉ា ៖ មានបងប្អូននៅស្រុកកំណើតអីដែរទេ?

អាន ៖ សុទ្ធតែក្មួយ ។

ដារ៉ា ៖ អ៊ំមានដែលបានទៅលេងស្រុកកំណើតរបស់លអ៊ំដែរ?

អាន ៖ ទៅ! ទៅម្តងដែរ ។

ដារ៉ា ៖ ម្តងគត់តាំងពីមុនមក?

អាន ៖ បាទ! បើមនុស្សលែងដើរចាស់ហើយ គេហៅការ អត់ទៅ ។ ពិបាកណាស់ក្មួយប្រុសរឿងប្រវត្តិខ្ញុំនេះ គណៈតំបន់គេ គេឡើងទៅស្រុក ផ្ទះគេអីចឹង របងខ្ញាត់ខ្វែង ខ្ញុំមើល ដល់ខ្ញុំ

វិញអត់មានរបេងរបង រនីញរនាំងឯណាទេ នរណាចូលអីចូលទៅ រហូតទៅដល់គេថាអ្នកដឹកនាំ មិនដឹងស្អីទេ ថាអីថាទៅ ខ្ញុំដឹងតែពីធ្វើ ធ្វើស្រែធ្វើចំការ ធ្វើប្រពន្ធភ្លឺ ធ្វើស្ពានីយ បូមទឹក បូមណា ខ្ញុំដឹងតែពីធ្វើ សម្លរនេះ ត្រីសង្ការនេះសម្លម្ជូរស្លឹកអំពិលបង់ម្អមបាទ អីចឹង អត់របៀបរបបឯណា ឲ្យតំកើងខ្លួនវ៉ាយរ៉ឹកពា ខ្ញុំជម្រាប់ដោយត្រង់ថាអត់ទេ គ្មានទេ គ្រាន់តែឃើញគេ ថាឱ៊ន អញ់តំបន់ គេស្រុក មិញក៏ធំម្ល៉េះ ពិចារណាអីចឹងជម្រាបត្រង់ហើយនេះ ។

ដានី : ចុះអ៊ី អ៊ីប៉ូចគាត់ទៅតាមរយៈអ៊ីដែរ ឬក៏គាត់ទៅតាមរយៈផ្សេង?

អាន : អត់ទេ! តាម៉ុកទាំងអស់ ។

ដានី : អីចឹងកាលពីអ៊ីនៅស្រុក នៅអីស្គាល់គាត់ច្បាស់ដែរ ឬក៏អត់ស្គាល់ទេ?

អាន : ស្គាល់! បាទស្គាល់គ្នាតាំងពីស្រុក ពីព្រោះគាត់នៅកំពង់ស្ពឺ ហីកំពង់ឆ្នាំងហ្នុងខ័ណ្ឌគ្នានឹងស៊ីង អីចឹងទេ ។

ដានី : តែដល់ពេលអ៊ីទៅដល់កំពង់ចាម គាត់ទៅកំពង់ធំអី មានទំនាក់ទំនងគ្នា មានអីទេ...

អាន : គាត់ទៅក្រោយ!

ដានី : គាត់មានទៅទាក់ទងអ៊ីដែរអត់?

អាន : អត់ទេ! ទៅជួបពេលប្រជុំ ។ គេនៅជាមួយ អឿន ៤២ កំពង់ធំហ្នឹងតំបន់ ស្រុកបារាយ កាលណុះគេកាត់កំពង់ធំ បង្កើតតំបន់មួយ នៅជាតំបន់៤២ អីចឹងគេកាត់ស្រុកបារាយមក ៤២ នៅជាមួយ អឿន ។

ដានី : អីចឹង អឿន ហ្នឹងគាត់នៅរហូតដល់យួនចូលដែរ?

អាន : បាទ!

ដានី : ចុះចននេះ មិនគេចាប់ទៅ ចុះគេតំឡើងពីណាឲ្យទៅជាលេខាតំបន់៤៣?

អាន : ផែន! បាទ ផែន មកពីកំពត ស្រុកកំណើតគាត់នៅស្រែក្នុង ។

ដានី : ឈ្មោះអីផែន?

អាន : មិនដឹងទេត្រកូល ។

ដានី : មិនមែនឈ្មោះ បែ ផែន ទេឬ?

អាន : អត់ដឹងទេ ។ ដឹងតែឈ្មោះ ផែន ។

ដានី : ផែន មកពីស្រែក្នុង?

អាន : កំពត! មកនៅបានប៉ុន្មានមកនៅកំពង់ធំហ្នឹង នៅបានប៉ុន្មានទេ ស្រាប់តែឮថា អូ!មិនល្អទៀត ហើយគេយកគាត់ទៅ បាត់ពីនេះទៅមិនដឹងពីណាទៀត ។

ដារ៉ា ៖ ឈ្មោះអឹសរសេរអក្សរ ឪ ឬក៏ អោ?

អាន ៖ ខ្ញុំពីដើម ខ្ញុំ ស្រះពេញតួ ឪ នោះណា ។

ដារ៉ា ៖ ចុះដល់ឥឡូវ?

អាន ៖ ដល់ឥឡូវឃើញគេសរសេរអក្សរ អោ ហ្នឹងឯង ។

ដានី ៖ ក្នុងអត្តសញ្ញាណប័ណ្ណរបស់អឹសរសេរថាម៉េច?

អាន ៖ អត់បានមើលផង ដឹងគេដាក់ថាម៉េច ប៉ុនដែលខ្ញុំសរសេរអោពេញតួ ឪម ហ្នឹងបែប អោ មិនដឹង អោហើយ ។

ដារ៉ា ៖ ពីដើមស្រះពេញតួ?

អាន ៖ ស្រះពេញតួ ។

ដារ៉ា ៖ ដល់ពេលមកឥឡូវសរសេរនឹង អោម ស្រះរាយវិញ?

អាន ៖ បាទ!

ដារ៉ា ៖ គេសរសេរឲ្យវិញ?

អាន ៖ បាទ!

ដារ៉ា ៖ ក្នុងចិត្តអឹ អឹចង់ប្រើឪ ពេញតួជាង?

អាន ៖ បាទ! ព្រោះនឹងត្រូវ ព្រោះស្រះ ដល់ឥឡូវហ្នឹងក៏ខ្ញុំមិនហ៊ានថាម៉េចដែរ ថាខុសថាត្រូវអី ដែរ ខ្ញុំអត់មែនអ្នកប្រាជ្ញ កវីបណ្ឌិតអីផង ។

ដានី ៖ អីចឹងអឹ ពេលដែលឃួនចូលឆ្នាំ៧៩ អឹមានប្រសាសន៍មិញនេះថា អឹទៅរហូតដល់កន្លែង មុំបី?

អាន ៖ បាទ!

ដានី ៖ អឹទៅយ៉ាងម៉េចទៅ កន្លែងមុំបីហ្នុង?

អាន ៖ រត់! ដើរច្រើរដើងហ្នឹងឯង ហើមដើងសឹងទក់អស់ហើយ រួចទៅនៅជាមួយឯកឧត្តម សុន សេន នៅជាមួយឯកឧត្តម សុន សេន រហូតតាំងពីឆ្នាំ៧៩ នៅស៊ីងជីនិត ក៏នៅជាមួយ ឯកឧត្តម សុន សេន ដែរ ។

ដានី ៖ ចុះអឹពេលហ្នុង កម្លាំងខាងខ្មែរក្រហមគេមិនតស៊ូវៃជាមួយខាងក្នុង ជាមួយខាងរដ្ឋាភិបាល ខាងក្នុងវិញ?

អាន ៖ វៃតប ។

ដានី ៖ ខាងក្នុង កែ ពក គាត់ទទួលខាងទិសតំបន់ខគ្គរ កាលហ្នុងគាត់ទទួលខាងកងទ័ពវៃវិញ?

អាន ៖ បាទ!

ដានី ៖ ចុះអ៊ីមានទទួលអីជាមួយ កែ ពក វ៉ៃវិញហីក៏អត់ទេ?

អាន ៖ អត់! ខ្ញុំឈប់រហូត ។

ដានី ៖ ម៉េចអីចឹងកាលហ្នុង?

អាន ៖ ម៉ាដំណាក់កាលវ៉ៃនេះខ្ញុំអត់ទេ ខ្ញុំចាស់ហើយ ខ្ញុំអត់ធ្វើទេ គេឲ្យទទួលនៅខាងក្រោយ ។ ទទួលនៅខាងក្រោយហ្នឹង គឺពួកមីងៗប៉ុន្មានកងពលឯណោះ ខ្ញុំទទួលគ្រប់គ្រងមីងៗហ្នឹង ។

ដានី ៖ គេហៅមន្ទីរអីគេហ្នឹង គ្រប់គ្រងហ្នឹង?

អាន ៖ គេហៅ គ៧ ។

ដានី ៖ មន្ទីររបស់តា សុន សេន?

អាន ៖ បាទ!

ដានី ៖ នៅកន្លែងមុំបី?

អាន ៖ បាទ! នៅមុំបីរហូតដល់ចុះមកនៅដីថៃ គេហៅជំរុំស៊ីងចាន់ មកពីជំរុំស៊ីងចាន់មក អន្លង់វែង ។

ដានី ៖ អ៊ីមកអន្លង់វែងឆ្នាំណា?

អាន ៖ សួរអីចឹង អត់ចាំទេ ។

ដានី ៖ បាទអ៊ី ម៉េចបានមកនៅអន្លង់វែងកាលហ្នុង?

អាន ៖ មកនៅអន្លង់វែងក្រោយយួនដក សម័យ អ៊ុន តាក់ ។

ដានី ៖ អ៊ីពេលហ្នុង អ៊ី ពូមីងមួយចំនួនពេលនៅអន្លុងវែងបានប្រហែលមួយឆ្នាំ ពួកបានផ្លាស់មក នេះទៀត ផ្លាស់មកខាងហ្នឹងណា កាលហ្នុងអ្នកនៅមន្ទីររបស់ សុន សេន គាត់បានផ្លាស់ មកខាងកំរៀងយើងហ្នឹង ប៉ុន្តែអ៊ីអត់មានផ្លាស់មកជាមួយគេណា?

អាន ៖ អត់ទេ! ខ្ញុំនៅណោះ ។

ដានី ៖ ម៉េចបានអ៊ីអត់ផ្លាស់មក?

អាន ៖ កាលហ្នុងខ្ញុំគេអត់ឲ្យមក កាលហ្នុងឯកឧត្តម សុន សេន គាត់ថាមិត្តអត់ត្រូវមកទេ ឥឡូវ នៅជាមួយតាម៉ុកហ្នុងទៅ ហីនៅជាមួយតាម៉ុក ហ្នុងខ្ញុំមានទៅធ្វើស្អីខ្ញុំ នៅភូមិមួយរហូត ទល់តែភូមិហ្នុងឈ្មោះភូមិតាអាននៅរាល់តែថ្ងៃហ្នឹង ។

ដានី ៖ ភូមិហ្នុងឈ្មោះរបស់អ៊ី?

អាន ៖ ដែលខ្ញុំនៅហ្នុង រួចមានប្រជាជនម៉ាចំនួនគេនៅហ្នុងម៉ាភូមិនៅហ្នុង គេហៅថាភូមិតាអាន ។

ដានី ៖ នៅក្នុងឃុំអីហ្នុង?

អ្នកជិតខាង៖ ឥឡូវភូមិសន្តិភាព ឃុំត្រពាំងប្រៃយ៍ ។

អាន ៖ ឃុំត្រពាំងប្រៃយ៍ ។

ដានី ៖ ឥឡូវភូមិដែលឈ្មោះតាអានហ្នឹង គេដូរមកដាក់ភូមិសន្តិភាពវិញ?

អ្នកជិតខាងៈ អ្នកដែលនៅហ្នឹងចេះតែហៅឈ្មោះអីទៅ ប៉ុន្តែឈ្មោះភូមិគេមានហើយណា ។

ដានី ៖ អាហ្នឹងនៅក្នុងភូមិសន្តិភាព ក្នុងឃុំសន្តិភាព ស្រុកអន្លង់វែង?

អាន ៖ បាទ!

ដានី ៖ ចុះអ៊ីពេលយើងធ្វើសមាហរណកម្មហើយអ៊ីមានតួនាទីអី ពីមុនដូចថាយើងប្រវត្តិមកណា ដល់ពេលយើងធ្វើសមាហរណកម្មហើយ ម៉េចបានអ៊ីអត់មានតួនាទី ឋានៈអី?

អាន ៖ ខ្ញុំមកណេះមក ខ្ញុំមកនៅណេះ ។ កាលនោះគេឲ្យខ្ញុំធ្វើចៅហ្វាយស្រុកនៅអន្លង់វែង ហីខ្ញុំប្រកែក នៅអន្លង់វែងហ្នឹងខ្ញុំប្រកែក មានសាច់សន្តានឆ្ងាយហើយ ដុំ នោះគេថា បងទៅធ្វើហ្វាយស្រុកនៅត្រពាំងប្រាសាទ ប៉ុនសាច់សន្តានខ្ញុំ ខ្ញុំមានដែលនិយាយស្រួលបួលអី ខ្ញុំថាអាដុំ! អញធ្វើសមាហរណកម្មរួចអស់ហើយអា អាយុអញមិនមែន១០០ឆ្នាំទេ អញអត់ធ្វើទេ មិនមែនបានន័យថាអញស្អប់រាជរដ្ឋាភិបាលទេ អញរស់នៅក្រោមស្លាបចំអេងរបស់រដ្ឋាភិបាល អញសុំធ្វើជាពលរដ្ឋ អញអត់ធ្វើទេ ហ្អែងថាអញអាយុ១០០ម៉ឹងអី! អញមិនបាន១០០ឆ្នាំទេ ដូច្នេះអញមិនធ្វើទេ អញរកផ្លូវអញមួយដើរ ព្រោះផ្លូវអញទៅតែឯងមិនដែលមានគ្នា ដូច្នេះមានតែផ្លូវហ្នឹងទេ ដូច្នេះអញគិតគួរខាងត្រៃយ៍សារណៈគម អញមិនទៅគិតអីទៀតទេ ហ្អែងគិតទៅ ហ្អែងនៅក្មេង ហ្អែងធ្វើទៅ អញអត់ធ្វើទេ ហ្អែងស្តាប់បានទេ អញអាយុ១០០ឆ្នាំម៉ឹងអី! អត់បានទេ ។ ដល់មកនៅនេះក៏ខ្ញុំអត់ធ្វើអីទេ ព្រោះវប្បធម៌សម្ព័ន្ធមានគ្រប់សព្វអស់ហើយ ទោះបីជាឲ្យក៏ខ្ញុំនៅតែអត់ធ្វើអីចឹង អត់ធ្វើទេ ហីក៏មិនមែនស្អប់ទេ លោកព្រះម្ចាស់ថ្លៃអើយអត់ស្អប់ទេ ។

ដានី ៖ ចុះអ៊ីមូលហេតុអីបានជាអ៊ីផ្លាស់ពីអន្លង់វែងមករស់នៅទីនេះណា មូលហេតុអីបានជាអ៊ីផ្លាស់មកហ្នឹង?

អាន ៖ ខ្ញុំស្តាប់សេចក្តីប្រកាសពេលនោះ ថាពេលធ្វើសមាហរណកម្មហើយ មានសិទ្ធិដើរហើរស្នាក់នៅផ្លាស់ទីលំនៅដ្ឋាន ចង់ទៅស្រុកខាងកើតក៏បាន ទៅខាងណាក៏បាន ដល់អីចឹងទៅខ្ញុំមានសាច់សន្តានខ្ញុំនៅខាងនេះ ក្មួយៗអីនៅខាងនេះក៏ខ្ញុំមកៗ បាទអីចឹងទេ មិនមែនទៅគេចស្អីទេ អត់ទេ ។

ដារ៉ា ៖ អ៊ឺ! ឥឡូវមករស់នៅដូចថា សមាហរណកម្មចូលក្នុងសង្គមវិញហើយអ៊ី អាចថាអ៊ីក្រឡេកមើលថយក្រោយវិញ នៅសម័យខ្មែរក្រហម នៅសម័យដែលអ៊ីបានចូលរួមអីដែរអ៊ីមានអារម្មណ៍ម៉េចទៅ?

អាន ៖ ពីមុននោះ អត់មានអារម្មណ៍ម៉េចទេក្មួយ ខ្ញុំឃើញសព្វថ្ងៃនេះស្អាតក្នុងការកសាងអី គួរឲ្យខ្ញុំមានការសង្ឃឹម គួរឲ្យខ្ញុំមានសេចក្ដីទុកចិត្ត ព្រោះចិត្តសប្បុរសធម៌របស់រាជរដ្ឋាភិបាល ខ្ញុំឃើញមានច្រើនណាស់ ។

ដារ៉ា ៖ ចុះបើធៀបទៅហ្នឹងជំនាន់ដែលអ៊ំចូលទៅតស៊ូតាមការអំពាវនាវរបស់សម្ដេចអី រហូតមកដល់អ៊ំធ្វើការងារនៅក្នុងរដ្ឋាភិបាលខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យហ្នឹងណាអ៊ំ អាហ្នឹងវាយ៉ាងម៉េចវិញអ៊ំ ខុសគ្នាយ៉ាងម៉េចទៅអ៊ំ?

អាន ៖ ចង់សួរថាម៉េចហ្នឹង!

ដារ៉ា ៖ អ៊ំថាឥឡូវសប្បាយ សន្តិភាពអីហើយ អីចឹងណាអ៊ំណា តែបើប្រៀបធៀបទៅហ្នឹងជំនាន់អ៊ំធ្វើជាលេខា ធ្វើជាអីកន្លងមកហ្នុង វាមានការខុសគ្នាយ៉ាងម៉េចដែរ?

អាន ៖ ខ្ញុំពេញចិត្តហ្នឹងរាជរដ្ឋាភិបាលសព្វថ្ងៃនេះ ខ្ញុំឃើញមានទស្សនៈដូចខ្ញុំដែរ ពេលដែលខ្ញុំធ្វើការតស៊ូគឺដើម្បីអី ពិសេសគឺរដ្ឋប្រហារក្បត់របស់ លន់ ណុល ផ្ដួលរំលំព្រះមហាក្សត្រអីចឹងក្រោយរដ្ឋប្រហារនេះទេ ដែលខ្ញុំបានចូលរួម ហ្នឹងជាឧត្តមគតិ ជាជំហរ ជាទស្សនៈរបស់ខ្ញុំ តែមកដល់ពេលនេះខ្ញុំឃើញថា សម្ដេចនាយកលើកតម្កើងខាងព្រះមហាក្សត្រ ព្រះមហាក្សត្រសើយរាជ្យ ទន្ទឹមនឹងអភិវឌ្ឍន៍ប្រទេសបានរីកចំរើន បំបាត់សង្គ្រាមបង្ហូរឈាម ចប់សព្វគ្រប់ បាទ!នេះជាទស្សនៈមួយ បើខ្ញុំថាស្របនឹងខ្ញុំ ហាក់ដូចខ្ញុំនឹងវាខ្ពស់ពេក ប៉ុន្តែខ្ញុំថាជំហររបស់ខ្ញុំគឺអីចឹង ឥឡូវខ្ញុំឃើញអីចឹងដែលខ្ញុំពេញចិត្ត មួយគាំពារព្រះមហាក្សត្រ ព្រះមហាក្សត្រសើយរាជ្យ ។

ដានី ៖ ចុះកាលពីសម័យពីឆ្នាំ១៩៧៥ ដល់៧៩ កាលហ្នុងអ៊ំធ្លាប់ធ្វើការដែរ អ៊ំយល់ឃើញយ៉ាងម៉េចដែរកាលពីសម័យហ្នឹង?

អាន ៖ ពីសម័យ៧៥ - ៧៩!

ដានី ៖ បាទ! កម្ពុជាប្រជាធិបតេយ្យហ្នឹងណាអ៊ំ!

អាន ៖ ខ្ញុំឃើញកាលណុះ កម្ពុជាប្រជាធិតេយ្យ ក្រោយពីបានធ្វើប្រកាសអ្នកដឹកនាំមកណា ហ៊ីខ្ញុំក៏ពេញចិត្តពេញថ្លើម ត្រង់ថាការពារហើយខំកសាងប្រទេស ហើយស្ដារប្រទេសឡើងវិញ រួចឃើញគោលការណ៍កសាង និងស្ដារប្រទេស ស្ដារប្រទេសណាដូចខ្ញុំបានជម្រាបជាហូរហែរ កន្លងមកហើយថា ខ្លួនខ្ញុំផ្ទាល់ហ្នឹងក៏សុទ្ធតែចុះប្រឡូកហើយមានពាក្យស្លោកមួយថាកម្មាភិបាល គឺកម្មសិទ្ធិមួយសមរម្យ គឺស្បោងមួយតូច ខ្ញុំមានតែសំពាយមួយប៉ុណ្ណឹង ហ៊ីអង្រឹងមួយ មុងមួយ ភួយសន្ទប់មួយ អត់មានអីទេ មកទល់នឹងពេលសព្វថ្ងៃនេះក៏អត់មានអីដែរ មើលផ្ទះសម្បែងក្មួយទៅឃើញហើយ យ៉ាងម៉េច ។

ដានី : អឺ! អីចឹងអឺមានប្រសាសន៍ហ្នឹង អឺពេញចិត្តនឹងរបបដែលពីឆ្នាំ១៩៧៥ ដល់៧៩ អឺពេញចិត្ត!

អាន : បាទ!

ដានី : អឺមានប្រសាសន៍មិញ អឺពេញចិត្តនឹងរបបកម្ពុជាប្រជាធិតេយ្យពីឆ្នាំ១៩៧៥ ដល់៧៩ អឺពេញចិត្តរបបហ្នឹងដែរ?

អាន : បាទ! ខ្ញុំនិយាយហ្នឹងញែកជាពីរណា ពេញចិត្តនឹងការកសាង និងការធ្វើ ដល់ទៅអាពេលរង្គោះរង្គើរ ខ្ញុំអត់យល់ទេ លែងយល់ហើយ អត់យល់ទេ បាទ!ការបាក់បែក ប្រកាប់ប្រចាក់យ៉ាងណាៗនោះ ខ្ញុំលែងយល់អស់ហើយ អត់យល់ទេ។

ដារ៉ា : ចុះអឺនៅក្នុងហ្នឹង...

អាន : ដំបូងឡើយនិយាយពីការនែនាំណា ដេសម៉ាសរសៃរ ម្ហូរម៉ាដើម កម្មាភិបាលទាំងអស់ល្អណាស់ ចង់អង្រ្គឹងអីចឹង ស្រីម្នាង ប្រុសម្នាង ដេកឱបដៃខ្លាចលក់ទៅប៉ះ ល្អណាស់ ប៉ុន្តែដល់ក្រោយមកប្រែប្រួលបែកបាក់គ្នាខាងលើៗ ខ្ញុំអត់ដឹងទេ ដូចជាថ្នាក់ដឹកនាំខាងលើដូចជា តាម៉ុក ប៉ុល ពត អៀង សារី អីណាៗខ្ញុំអត់ដឹងទេ លែងដឹងហើយ វង្វេងវង្វាន់អត់ដឹងអីទេ គិតស្អីក៏មិនធុះ ពិចារណាអីក៏មិនបានដែរ ហ្នឹងជម្រាបត្រង់អីចឹងហើយ។

ដារ៉ា : អឺពី ៧៥-៧៩ អឺទទួលស្គាល់ថាមានការសម្លាប់មនុស្សទេអឺ?

អាន : ខ្ញុំមិនដឹងទេត្រង់ហ្នឹង ៧៥-៧៩ ការកាប់សម្លាប់អីដូចខ្ញុំជម្រាបអីចឹងថានៅកំពង់ចាមដូចខ្ញុំទៅនោះ ខ្ញុំអត់ដឹងរឿងអីទេ គឺស្អាតអត់មានទេ អ្នកដឹកនាំចាស់អត់មានទេ រីឯការកាប់សម្លាប់អីដូចខ្ញុំជម្រាបថានៅបឹងក្រកួនអីណានោះខ្ញុំមិនដឹងទេ ហើយចំពោះអ្នកចាស់នោះប៉ះពាល់យ៉ាងម៉េចៗនោះខ្ញុំអត់ដឹងទេ តែចំពោះខ្លួនខ្ញុំអត់មានទេ។

ដានី : ចុះអឺ អឺមានប្រសាសន៍លើកមុននេះ អឺថាឈ្មោះ ម៉ុន ដែលជាគណៈស្រុកជើងព្រៃ ហើយដល់ពេល៧៩មក ហើយត្រូវប្រជាជនព័ទ្ធវ៉ៃគាត់ស្លាប់ទៅនៅក្នុងព្រៃគប់ហ្នុងអាហ្នឹងមូលហេតុអី?

អាន : អាហ្នឹងមិនមែនប្រជាជនទេក្មួយ! កងទ័ពយួន គាត់ទៅធ្វើការងារប្រជាជន គាត់ទៅបង្កប់ខ្លួននៅក្នុងព្រៃកុងហ្នុង ដល់នេះទៅយួនព័ទ្ធបាញ់ស្លាប់នៅហ្នុង ច្បាស់ហើយ!

ដានី : បាទ! អឺពួកខ្ញុំដូចជាអស់សំណួរអីត្រូវសួរនាំទៀតហើយអឺ!

អាន : បាទ!

ដានី : អីចឹងអឺ ពួកខ្ញុំអរគុណអឺច្រើន ដែលចំណាយពេលផ្តល់បទសម្ភាសន៍ជាមួយពួកខ្ញុំ២ម៉ោងជាងនេះអឺ!

អាន ៖ បាទ!

ដានី ៖ ខ្ញុំអរគុណអ៊ំច្រើន!

អាន ៖ បាទ!

«ចប់»